ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Dec-2015, 08:50
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៣៤៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

លោកស្រី អេវេលីន ខាំផូស សង់ចេស
*(Mrs. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក អ៊ុំ ស៊ន់ (2-TCW-949) | ខ្មែរ |
| លោកស្រី អ៊ុង សំអ៊ាន (2-TCW-805) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុំ ស៊ន់** (2-TCW-949)

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.......... ទំព័រ ៣

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្ដើមពី.......... ទំព័រ ២៤

**ការសួរសំណួរទៅសាក្សី៖ លោកស្រី អ៊ុំ សំអ៊ាន** (2-TCW-805)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី .......... ទំព័រ ២៥

សួរដោយលោក ស្រ៊ា រតនៈ ផ្ដើមពី .......... ទំព័រ ២៨

សួរដោយវាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី.......... ទំព័រ ៣៤

សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្ដើមពី.......... ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:១០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី អ៊ុំ ស៊ន់ បញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សាក្សីដែលមានរហស្សនាម 2-TCW-805។ ហើយដូចអង្គជំនុំជម្រះបានជម្រាបជូនភាគីកាលពីម្សិលមិញតាមរយៈមន្ត្រីច្បាប់ ដោយសារសាក្សីដែលបានកំណត់កាលពីថ្ងៃមុននោះ គាត់មានបញ្ហាផ្ទាល់ខ្លួន ហើយលទ្ធភាពនៃការផ្លាស់ប្តូរជំនួសនូវសវនាការបន្តនៅថ្ងៃនេះ គឺជំនួសដោយសាក្សី 2-TCW-805។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោកមេធាវី គង់ សំអុន អវត្តមានដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោក អ៊ុំ ស៊ន់ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

[០៩:០៣:១៥]

នៅថ្ងៃនេះផងដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-805។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណី-

វេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ុយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់ ចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈវិលមុខ ឈឺក្បាល និងឈឺចង្កេះខ្លាំងពេលធ្វើចលនា និងផ្ដល់អនុសាសន៍ថា សុំអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោយសាលសវនាការនេះ។

[០៩:០៥:៤៨]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេល នៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំសួរលោកបន្តទៅទៀត កាលពីថ្ងៃពុធ ខ្ញុំបានប្រាប់លោកហើយថា សូមឲ្យលោកឆ្លើយទៅនឹងអ្វីដែលខ្ញុំសួរ។ កាលពីថ្ងៃពុធ លោកបានឆ្លើយថា លោកធ្វើការពេលថ្ងៃផង និងពេលយប់ផង ហើយពេលយប់នោះគឺលោកយាមផ្លូវ។ ហើយពេលយប់ហ្នឹងអ្នកនៅសហករណ៍ គេមិនត្រូវបានគេអនុញ្ញាតឲ្យទៅការដ្ឋានទេ។ ដូច្នេះខ្ញុំចង់ដឹងថា ជាទូទៅនោះលោកចាប់ផ្តើមយាម ចាប់ពីម៉ោងប៉ុន្មានទៅ?

[០៩:០៦:៣៥]

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ដែលគេចាត់តាំងយាម ឲ្យយាមចាប់តាំងពីម៉ោងប្រាំពីរទៅ។

**ស៖** ដូច្នេះលោកចាប់ផ្តើមយាមពីម៉ោងប្រាំពីរយប់ អ៊ីចឹងបញ្ចប់ទៅវិញនៅម៉ោងប៉ុន្មានដែរ?

**ឆ៖** បាទ បញ្ចប់ទៅវិញនៅម៉ោងប្រាំបួន។

**ស៖** អ៊ីចឹងគឺលោកយាមតែពីម៉ោងប្រាំពីរ ដល់ម៉ោងប្រាំបួនយប់ទេ។ អ៊ីចឹងចាប់ពីម៉ោងប្រាំបួនយប់ទៅ គឺអត់មានអ្នកណាយាមអីទៀតទេ មែនទេ?

**ឆ៖** អត់មានអ្នកណាយាមទៀតទេ គេចែកវេនយាមគ្នារួចអស់ហើយ។

**ស៖** ដូច្នេះមានន័យថា លោកយាមជារៀងរាល់ថ្ងៃហ្នឹង គឺត្រឹមតែពីម៉ោងប្រាំពីរដល់ម៉ោងប្រាំបួនទេ មិនដែលយាមលើសពីម៉ោងប្រាំបួនយប់ទេ។ មែនទេ?

**ឆ៖** អត់ទេ។ អត់មានយាមតទៅទៀតទេ។ ដល់តែពីម៉ោងប្រាំពីរទៅប្រាំបួន ខ្ញុំឈប់យាមហ្នឹង គេឲ្យខ្ញុំឈប់យាម។

**ស៖** ចុះ ស៊ាន ស៊ង់ ជាមិត្តរបស់លោកនោះ គាត់ត្រូវយាមដូចជាលោកអ៊ីចឹងដែរ មែនទេ?

**ឆ៖** គេអត់ឲ្យយាមទេ ស៊ាន ស៊ង់។ គេចាត់តាំងតែខ្ញុំទេ ឲ្យយាមនោះ។ ស៊ាន ស៊ង់ គេមុខលុកផ្នែកការងារគេផ្សេងទេ។ ខាងកាប់ដី កាប់ទន្ទ្រានខេត្ត ធ្វើដីកំប៉ុសគេនោះ។ មុខក្រសួងខុសគ្នា។

[០៩:០៩:០៨]

**ស៖** លោកសាក្សីខ្ញុំសូមឲ្យលោកឆ្លើយនឹងអ្វីដែលខ្ញុំសួរ ខ្ញុំសួរអីឆ្លើយហ្នឹង។ នេះជាសំណួរចុងក្រោយពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំសួរម្តងទៀត លោកយាមពីម៉ោងប្រាំពីរទៅដល់ម៉ោងប្រាំបួនយប់ហ្នឹង

គឺរៀងរាល់ថ្ងៃ មែនទេ?

**ធ៖** បាទ រៀងរាល់ថ្ងៃ។

**ស៖** ឥឡូវនេះ ខ្ញុំទៅនិយាយអំពីថ្ងៃដែលលោកឃើញគេសម្លាប់មនុស្សនៅវត្តខ្សាច់។ ខ្ញុំដឹងថា លោកមិនចាំច្បាស់លាស់អំពីកាលបរិច្ឆេទទេ ក៏ប៉ុន្តែលោកចាំអំពីរដូវទេ? លោកនឹកឃើញទេថា ពេលដែលលោកឃើញគេសម្លាប់មនុស្សហ្នឹងនៅក្នុងរដូវប្រាំង ឬក៏រដូវវស្សា?

**ធ៖** បាទ កាលនោះ មិនទាន់មានភ្លៀងខ្លាំងទេ។ រដូវវស្សាចូលមក ប៉ុន្តែមិនទាន់មានធ្លាក់ភ្លៀងខ្លាំងទេ។ នៅវាំងនៅឡើយ ទឹកមិនទាន់មានដក់តាមកន្ទុកនៅឡើយទេ។

**ស៖** លោកចាំទេថា ក្រោយពីលោកឃើញគេសម្លាប់មនុស្សហើយហ្នឹង លោកនៅតែបន្តធ្វើការនៅក្នុងកងរបស់លោកដដែល ឬក៏យ៉ាងម៉េច?

**ធ៖** បាទ ខ្ញុំនៅធ្វើការនៅកងដដែលវិញដូចដើម នៅតាមមូលដ្ឋានវិញដូចដើម។

**ស៖** អ៊ីចឹង លោកនៅក្នុងកងហ្នឹងរហូតដល់កងទ័ពវៀតណាមវាយចូលមកនៅឆ្នាំ៧៩ មែនទេ?

**ធ៖** បាទ នៅរហូតដល់ឆ្នាំ៧៩។

[០៩:១១:៥៧]

**ស៖** លោកអាចប៉ាន់ស្មានមើលទេ តើក្រោយពីពេលសម្លាប់មនុស្សហ្នឹងប៉ុន្មានខែទើបវៀតណាមវាយចូល?

**ធ៖** ប៉ុន្មានទេ ខ្ញុំដូចជាមិនសូវចាំផង ភ្លេចភ្លាំង។

**ស៖** ខ្ញុំនឹងរំឭកការចងចាំរបស់លោកតាមរបៀបផ្សេង។ លោកគិតមើលថាតើយូរ ឬក៏ឆាប់ពេលដែលលោកឃើញគេសម្លាប់មនុស្សហ្នឹងហើយ ប៉ុន្មានខែមក ដូចថារាប់ខែមកទើបវៀតណាមវ៉ៃចូល ឬក៏ត្រឹមតែមួយខែពីរខែទេ?

**ធ៖** វ៉ៃរួចប្រហែលជារយៈប្រហែលជា យើងថាវាកន្លះខែ និងមួយខែហ្នឹងគឺជាមួយគ្នាហ្នឹងឯងវៀតណាមចូលមកដល់។

**ស៖** ដូច្នេះហេតុការណ៍នៃការសម្លាប់មនុស្សនៅក្នុងវត្តខ្សាច់នេះ គឺនៅចុងឆ្នាំ៧៨ បើយើងគិតថាវៀតណាមវាយចូលនៅដើមឆ្នាំ៧៩ ខែមករា។ អ៊ីចឹងមានន័យថា ការសម្លាប់នៅវត្តហ្នឹងគឺប្រហែលជានៅចុងឆ្នាំ៧៨ មែនទេ?

**ធ៖** បាទ ប្រហែលនៅចុង៧៨ នុះឯង។

**ស៖** ឥឡូវនេះ ខ្ញុំសុំនិយាយអំពីពេលដែលលោកបាននិយាយថា លោកបានឃើញគេសម្លាប់មនុស្សនៅវត្តខ្សាច់។ នៅម៉ោង០៣:៤៧ និងម៉ោង ទៅដល់ម៉ោង០៣:៥២នាទី លោកបាននិយាយអំពីពេលម៉ោងដែលលោកធ្វើការប្រចាំថ្ងៃ។ លោកចាំទេ ពេលណាដែលលោកត្រឡប់ទៅសហករណ៍វិញ? ហើយលោកចាំទេថា នៅថ្ងៃដែលលោកឃើញគេសម្លាបមនុស្សហ្នឹង លោកធ្វើអ្វីដែរ?

[០៩:១៤:៤៧]

**ឆ៖** បាទ កាលដែលខ្ញុំបានឃើញនោះ ពេលនោះវាមិនទាន់មាន វាមិនទាន់ដល់យប់ងងឹតទេ នៅភ្លឺឡើយទេ។ ស្រាប់តែដល់ថ្ងៃបាក់រសៀលៗ ព្រះអាទិត្យចូលអស្ដង្គតទៅ ស្រាប់តែខ្ញុំឮស្នូរស្រែកទេ ឮស្នូរស្រែកហើយ បានខ្ញុំនឹកឃើញថា យី! សម្រែកអី វាស្រែកឮស្នូរមិនដាច់អ៊ីចេះនេះ។ ខ្ញុំក៏លបលួនលបលួចមើល ហើយក៏បានឃើញ។

**ស៖** សូមអភ័យទោសលោកសាក្សី។ ខ្ញុំនឹងត្រឡប់មកសួរអំពីចំណុចនេះនៅពេលក្រោយ ប៉ុន្តែអ្វីដែលខ្ញុំសួរអម្បាញ់មិញ មិនមែនអ៊ីចឹងទេ។ ខ្ញុំនិយាយថា មុនពេលដែលលោកទៅលបមើលគេសម្លាប់មនុស្សនោះ លោកធ្វើការអី? ហើយលោកត្រឡប់មកការដ្ឋានហ្នឹងនៅម៉ោងប៉ុន្មាននៅថ្ងៃនុ៎ង? លោកថាលោកធ្វើការទៅរកត្រី ធ្វើជី ហើយបន្ទាប់ពីធ្វើការហើយ លោកទៅផ្ទះសិនមុននឹងទៅហូបបាយ។ អ៊ីចឹងលោកចាំទេថា នៅថ្ងៃនោះ លោកត្រឡប់មកសហករណ៍វិញហ្នឹងនៅម៉ោងប៉ុន្មាន ក្រោយពីលោកទៅដល់ផ្ទះនោះ?

**ឆ៖** បាទខ្ញុំត្រឡប់មកប្រហែលជាម៉ោងប្រាំ មកពីរកត្រី។ ម៉ោងប្រាំវិញ ហើយខ្ញុំហូបបបររួចខ្ញុំសម្រាកនៅផ្ទះ។

**ស៖** លោកនៅផ្ទះហ្នឹង លោកសម្រាករហូតទៅដល់ម៉ោងប៉ុន្មាន?

**ឆ៖** បាទសម្រាកនោះ សម្រាកប្រហែលជាម៉ោងប្រាំមួយ។ ទៅបានតែមួយសន្ទុះស្រាប់តែឮស្នូរស្រែក ជិតចូលម៉ោងប្រាំពីរហើយ ឮស្នូរសម្រែកអីបានខ្ញុំភ្ញាក់ផ្អើល ហើយចង់ដឹង ហើយលបមើលតែម្ដង។

[០៩:១៧:៣៧]

**ស៖** ពេលលោករៀបរាប់រឿងរ៉ាវលោកប្រាប់សហព្រះរាជអាជ្ញាហ្នឹង លោកថាពេលនុ៎ងលោកនៅជាមួយ ស៊ាន ស៊ង់។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកជួប ស៊ាន ស៊ង់ នៅម៉ោងប៉ុន្មាន? ព្រោះថាលោកថាលោកបានទៅលបមួយហ្នឹងគឺជាមួយ ស៊ាន ស៊ង់។ អ៊ីចឹងលោកជួប ស៊ាន ស៊ង់ នៅម៉ោងប៉ុន្មាន? ហើយ

នៅកន្លែងណា?

**ឆ៖** បាទ វាទៅលេងនឹងផ្ទះហ្នឹងឯង ជួបគ្នា ស្រាប់តែពួសួរទាំងអស់គ្នា នាំគ្នាលួចរត់លបមើលទាំងអស់ហ្នឹង។

**ស៖** អ៊ីចឹងថ្ងៃហ្នឹង លោកទៅក្បែរវត្តហ្នឹងម្ដង ឬក៏ពីរដង?

**ឆ៖** បាទ ទៅពីរដង និងព្រឹកហើយបានទៅម្ដងទៀត។ អាដែលគេសម្លាប់រួចហើយ ព្រឹកឡើងដើរគ្នាទៅមើល។ ទៅមើលទៀត ពីរដងប៉ុណ្ណោះឯង។

**ស៖** បើព្រឹកស្អែកឡើងគឺជាថ្ងៃមួយទៀតទេ អ៊ីចឹងមានន័យថា នៅថ្ងៃគេសម្លាប់មនុស្សហ្នឹង គឺលោកទៅតែម្ដងទេ ទៅវត្តហ្នឹងមែនទេ?

**ឆ៖** បាទ ទៅតែម្ដងទេ កំពុងដែលគេសម្លាប់នោះ ទៅតែម្ដងទេ។

**ស៖** ប្រសិនបើខ្ញុំចាំមិនច្រឡំទេ លោកថាថ្ងៃដែលគេសម្លាប់មនុស្សហ្នឹង គឺជាថ្ងៃតែមួយនឹងថ្ងៃដែលគេចាប់ មានន័យថាគេចាប់ពេលរសៀល ហើយពេលយប់ឡើង គេសម្លាប់មែនទេ?

**ឆ៖** ដែលគេចាប់នោះវាពីថ្ងៃ ក្នុងយប់នោះគេសម្លាប់។

[០៩:២០:២៥]

**ស៖** ដូច្នេះមានន័យថា មុនពេលលោកទៅវត្តនៅម៉ោងប្រាំពីរនុ៎ង លោកមិនបានឃើញគេចាប់ខ្លួនអ្នកទាំងអស់ហ្នឹងទេ មែនទេ?

**ឆ៖** បាទ មិនបានឃើញទេ អត់បានឃើញទេ។

**ស៖** ដោយសារតែកាលពីថ្ងៃពុធ លោកថា ពេលស្អែកព្រឹកឡើងនុ៎ងលោកទៅវត្តម្ដងទៀត ហើយលោកឃើញហោត្រ័យជាកន្លែងដែលគេឃុំមនុស្សហ្នឹង គឺអត់មានមនុស្សទៀតទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបាទព្រឹកឡើង ខ្ញុំទៅទៀត ទៅមើល ទៅលបមើលទៀត ឃើញទ្វារចំហផ្លុងអស់មនុស្សពីហោត្រ័យនោះរលីងទៅហើយ។ បានសេចក្ដីថាក៏គេសម្លាប់អស់ហើយ។

**ស៖** ដូច្នេះការសម្លាប់មនុស្សហ្នឹង គឺមិនមែននៅក្នុងវត្តទេ គឺនៅក្រៅវត្ត មែនទេ?

**ឆ៖** មិនមែននៅចំតួក្នុងវត្តទេ នៅក្រៅវត្តអ៊ីចេះ អែបរបងវត្តនោះឯង។

**ស៖** នៅពេលដែលលោកឃើញគេសម្លាប់មនុស្សនោះ គេសម្លាប់ហ្នឹងនៅខាងក្នុងរបងវត្ត ឬក៏ខាងក្រៅរបងវត្ត?

**ឆ៖** ដែលឃើញគេសម្លាប់នោះវានៅជាប់នឹងព្រៃរបងនោះឯង របងវត្តនោះឯង ដែលគេសម្លាប់

នោះ ម្ខាងរបងម្នាក់។

**ស៖** ដូច្នេះមានន័យថា លោកមិនមែនលួចមើលតាមប្រលោះរបងទេ មែនទេ?

**ឆ៖** ខ្ញុំលួចមើលតាមកន្លែងត្រង់ណោះ វាវាល មើលតាមប្រលោះរបងដែរ អើតមើលទៅឃើញច្បាស់។

[០៩:២៤:០០]

**ស៖** ខ្ញុំដូចជាមិនយល់ លោកមើលតាមរបងយ៉ាងម៉េច? លោកៗថា គេសម្លាប់នៅខាងក្រៅរបង។ ហើយអ៊ីចឹងលោកមើលតាមប្រលោះរបងយ៉ាងម៉េច? ខ្ញុំអត់យល់ចម្លើយរបស់លោកនេះ។

**ឆ៖** ខ្ញុំមើលវាកណ្ដាលវាលទេ វាមើលទៅឃើញច្បាស់។

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញាកាលពីថ្ងៃពុធ លោកថារបងហ្នឹងធ្វើពីឈើ អ៊ីចឹងលោកអាចមើលទៅខាងក្នុងបាន។ អ៊ីចឹងពេលដែលលោកមើលទៅខាងវត្តនោះ លោកឃើញអ្វីខ្លះ?

**ឆ៖** ក្នុងវត្តនោះ របងនោះអត់មានរបងជញ្ជាំងថ្មទេ វាវាលទេ របងក្រាក់ដែលឈរជាជួរចម្រឹងមើលទៅឃើញចូលដល់ក្នុងវត្តទៀត ចូលក្នុង ឃើញក្នុងវត្តទៀត ឃើញតែរោងសារមន្ទីរគេ។

**ស៖** អ៊ីចឹងពេលហ្នឹងគឺព្រះអាទិត្យអស្ដង្គតហើយ ពេលហ្នឹងគឺយប់ងងឹតហើយ ទោះបីជាមានពន្លឺភ្លើងទៀន ឬក៏ភ្លើងចង្កៀងខ្លះក៏ដោយ ក៏ប៉ុន្តែវាងងឹតឈឹងមែនទេពេលហ្នឹង?

**ឆ៖** បាទ ពេលនោះចង្កៀងម៉ាំងសុងដែលគេអុជរ៉ៃនោះ វានៅភ្លឺតែត្រង់កន្លែងគេរ៉ៃនោះឯង តែដល់ខ្ញុំនៅឆ្ងាយនេះវារន្ទះភ្លើងវាអត់ភ្លឺដល់ទេ យប់ងងឹតទេ។

**ស៖** ពេលដែលលោកលបមើលនោះ ជនរងគ្រោះដែលគេសម្លាប់នោះ លោកស្គាល់អ្នកណាខ្លះទេ?

**ឆ៖** ខ្ញុំបាទ ស្គាល់តែ តាឃុត និងយាយម៉ា និងចាន់ថា។ ផុតពីនោះ ខ្ញុំអត់ស្គាល់ទេ។

**ស៖** លោកពិតជាឃើញអ្នកទាំងបីហ្នឹងផ្ទាល់ភ្នែកមែនទេនៅយប់នោះ?

**ឆ៖** បាទ បានឃើញ ខ្ញុំបាទបានឃើញ។

[០៩:២៧:២១]

**ស៖** លោកឃើញហ្នឹង ឃើញនៅកន្លែងគេសម្លាប់តែម្ដង ឬក៏លោកឃើញតាមប្រលោះរបង?

**ឆ៖** បាទ ឃើញតាមប្រលោះរបងកណ្ដាលវាលជ្រេញនេះឯង ឃើញ។ គេនៅត្រង់ភ្លឺ ខ្ញុំនៅ

ខាងងងឹត ខ្ញុំឃើញច្បាស់ ព្រោះខ្ញុំលបមើល។

**ស៖** ពេលដែលវ៉ៃសម្លាប់ហ្នឹង លោកឃើញផ្ទាល់តែម្តងពេលហ្នឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបាទបានឃើញផ្ទាល់នឹងភ្នែកតែម្តង។

**ស៖** ពេលគេសម្លាប់ ចាន់ថា ហ្នឹង លោកពិតជាឃើញមែនទេ?

**ឆ៖** បាទ ខ្ញុំបាទឃើញ។

**ស៖** ចុះ តាឃុត និង យាយម៉ា លោកឃើញគេសម្លាប់គាត់ផ្ទាល់ទេ? ហើយបើលោកឃើញ ឃុត, ម៉ា ហើយ ចាន់ថា ហ្នឹង អ្នកណាត្រូវគេសម្លាប់មុន?

**ឆ៖** ដែលឃើញ គេសម្លាប់ តាឃុត មុន រួចបានគេសម្លាប់ យាយម៉ា ក្រោយ។

**ស៖** ពេលហ្នឹងគឺ ស៊ាន ស៊ង់ ហ្នឹងក៏នៅមើលជាមួយលោកដែរ មែនទេ?

**ឆ៖** ស៊ាន ស៊ង់ ក៏នៅមើលជាមួយនឹងខ្ញុំនោះដែរ ភ័យខ្លាំង អ៊ូ!។

[០៩:៣០:០១]

**ស៖** ខ្ញុំមានបញ្ហាពីរពាក់ព័ន្ធនឹងចម្លើយរបស់លោក ពីព្រោះថានៅពេលដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គេសួរលោកថា ពេលគេសម្លាប់ ចាន់ថា នោះលោកបានឃើញទេ? លោកឆ្លើយថា លោកអត់ឃើញទេ។ ខ្ញុំសូមយោងទៅលើ គឺខ្សែអាត់លេខ D166/20R គឺនៅម៉ោងសាមពីរនាទីហាសិបប្រាំវិនាទី ទៅដល់សាមសិបបីនាទីទៅដល់ដប់ប្រាំមួយវិនាទី គឺយើងមានតែភាសាខ្មែរទេខ្សែអាត់នេះ ហើយគឺយើងបានធ្វើប្រតិចារឹកគឺ E3/7778.1។ ខ្ញុំសូមអាននូវសំណួរ “សួរ៖ ពេលគេសម្លាប់ ចាន់ថា លោកឃើញផ្ទាល់ភ្នែក មែនទេ? លោកឆ្លើយដូចតទៅ៖ អត់ទេ ខ្ញុំអត់បានឃើញផ្ទាល់ភ្នែកទេ។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះលោកសាក្សី ការពិតនៅឯណា? លោកបានឃើញ ឬក៏មិនបានឃើញ ពេលដែលគេសម្លាប់ ចាន់ថា នេះ?

**ឆ៖** ព្រោះពេលនោះសម្លាប់ វាមុននិងក្រោយ វាអត់មានជាមួយគ្នាទេ។ គេយកមួយសម្លាប់មួយៗ ម្តងម្នាក់ៗ។

**ស៖** លោកមិនបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ ខ្ញុំសួរលោកថា ចម្លើយដែលលោកបានឆ្លើយនៅថ្ងៃនេះ និងចម្លើយលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត តើលោកយកចម្លើយមួយណាដែលជាចម្លើយពិតប្រាកដត្រឹមត្រូវនោះ?

**ឆ៖** ដឹងឆ្លើយមួយណា ពីព្រោះខ្ញុំ វាមានការភ្លេចភ្លាំងខ្លះដែរ ព្រោះបានឃើញវ៉ៃថ្ងៃនោះ វា

ប្រាកដមែនហើយ។

**ស៖** អ៊ីចឹងលោកអាចពន្យល់បានទេ នៅពេលដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ ម៉េចបានជាលោកថាមិនបានឃើញទេពេលគេសម្លាប់ ចាន់ថានោះ?

[០៩:៣៣:១៣]

**ឆ៖** ព្រោះគេយកទៅទាំងអស់ គេសម្លាប់ចោលនៅកន្លែងនោះទាំងអស់។ វាងងឹតផង--

**ស៖** សូមអភ័យទោស ដែលខ្ញុំកាត់ចម្លើយលោក ខ្ញុំមិនបានសួរអ៊ីចឹងទេ។ ខ្ញុំសួរលោកថា ហេតុអ្វីបានជានៅពេលដែលអ្នកស៊ើបអង្កេតសួរសំណួរដដែលហ្នឹងទៅលោកហ្នឹង លោកឆ្លើយថា "ទេ" លោកមិនបានឃើញគេសម្លាប់ ចាន់ថា ទេ ប៉ុន្តែនៅថ្ងៃនេះ ពេលនេះលោកថា លោកបានឃើញ?

**ឆ៖** ឲ្យខ្ញុំឆ្លើយរបៀបណាទៅទៀតទេ អារឿងខ្ញុំភ្លេចភ្លាំងផង។ វាងងឹត ភ័យផងអីផង វាភ្លេចភ្លាំង។ កាលដែលឃើញមិនប្រក្រតីកន្លែងនោះ។

**ស៖** លោកឆ្លើយថា លោកមិនចាំទេ ពេលហ្នឹងយប់ងងឹតពេក លោកអត់ចាំអ្វីទាំងអស់ ក៏ប៉ុន្តែប៉ុន្មាននាទីមុននេះ នៅពេលដែលខ្ញុំសួរលោកថា លោកឃើញគេសម្លាប់ ចាន់ថា និងជីដូនតាទេ លោកថាលោកបានឃើញច្បាស់ ពីព្រោះថានៅកន្លែងគេសម្លាប់ហ្នឹង គេមានអុជចង្កៀង។ លោកៗនៅខាងងងឹត ប៉ុន្តែខាងកន្លែងគេសម្លាប់មនុស្សគឺភ្លឺ។ លោកបានឆ្លើយបែបនេះនៅមុននេះ សូមលោកពន្យល់ទៅមើល?

**ឆ៖** វាភ័យខ្លាំងពេក ដែលឃើញវារន្ធត់ពេក។ ពេលនោះខ្ញុំក៏ភ័យខ្លាំងពេក ម្ល៉ោះហើយវាស្រវេមស្រវាមមិនដឹងថាមួយណាៗ។ មិនដឹងជាឈ្មោះណាៗខ្លះ រួចច្រឡូកច្រឡំគ្នានៅកន្លែងនោះ ប៉ុន្តែគេចាប់ទៅអំឡុងតែមួយនោះឯង ដែលគេវាយ។

**ស៖** ដូច្នេះនៅពេលនេះលោកចង់និយាយថា លោកមិនច្បាស់ទេថា តាយុត, យាយម៉ា, ចាន់ថា នោះត្រូវបានគេសម្លាប់ ឬមិនបាននោះ លោកមើលមិនឃើញច្បាស់ទេ លោកមិនដឹងទេ។ លោកចង់និយាយអ៊ីចឹងមែនទេ?

[០៩:៣៦:០៧]

**ឆ៖** ថាអ៊ីចុះក៏បានដែរ។

**ស៖** ចំណុចទី១ទៀតដែលខ្ញុំចង់បានការបំភ្លឺពីលោក។ លោកថា ប្រហែលជានៅម៉ោងប្រាំពីរយប់លោកទៅមើលនៅវត្ត ពីព្រោះលោកឮសំឡេងស្រែក។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាកាលពីថ្ងៃពុធ លោកថា លោកនៅលបមើលនោះរហូតដល់គេសម្លាប់មនុស្ស

អស់ប្រហែលជាម៉ោងដប់យប់។ លោកអាចបញ្ជាក់ពីចំណុចនេះទេ លោករក្សាចម្លើយហ្នឹងដដែលទេ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំដូចជាស្តាប់មិនឮដូចមេធាវី ហ្គីសសេ និយាយហ្នឹងទេ កាលពីថ្ងៃពុធនោះ។ កាលពីថ្ងៃពុធ ខ្ញុំសួរថាតើគាត់នៅរហូតដល់គេសម្លាប់ចប់ ឬក៏គាត់ចេញទៅមុន។ គាត់ថា គាត់ចេញទៅមុន។ ដូច្នេះសូមឲ្យមេធាវីយោងម៉ោងឲ្យច្បាស់មក ម៉ោងណា ពេលណា ដែលគាត់និយាយបែបហ្នឹង ពីព្រោះថា ខ្ញុំស្តាប់ឮ ៗមិនដូចលោកស្រីទេ។

[០៩:៣៧:៥១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** មិនជាបញ្ហាអ្វីទេ ខ្ញុំអាចផ្តល់លេខយោងបាន លោកសហព្រះរាជអាជ្ញា គឺម៉ោង គឺថ្ងៃពុធម៉ោង ០២:១៤:៣៥។ លោកសហព្រះរាជអាជ្ញា លោកបានសួរដូចតទៅ តើលោកអាចសន្និដ្ឋានឲ្យបានច្បាស់បន្តិចបានទេ ខ្ញុំដឹងថាលោកមិនមាននាឡិកាទេ ក៏ប៉ុន្តែលោកអាចគិតមើលថា លោកនៅពួនមើលហ្នឹងប្រហែលជាប៉ុន្មានម៉ោងដែរ? លោកគិតមើលប៉ុន្មានម៉ោង? ពេលនោះលោកសាក្សី គាត់បានឆ្លើយដូចតទៅ ពិតណាស់ ខ្ញុំមិនមាននាឡិកាទេនៅពេលនោះ អ៊ីចឹងខ្ញុំគ្រាន់តែអាចប៉ាន់ស្មានតែប៉ុណ្ណោះ មិនប្រាកដទេ គឺពេលហ្នឹងយប់ហើយ ក៏ប៉ុន្តែយើងអាចមើលស្គាល់គ្នា មើលគ្នាស្គាល់។ ការសម្លាប់មនុស្សហ្នឹងបន្តរហូតទៅដល់ម៉ោងដប់យប់។ ហើយបន្ទាប់មក ខ្ញុំក៏រត់មកផ្ទះវិញ។ នេះជាការពិត ខ្ញុំមិនដឹងថាប្រាប់លោកអ្វីទៀតទេ។ គឺនៅម៉ោងមួយទៀត គឺម៉ោង០២:២៦នាទី សហព្រះរាជអាជ្ញាបានសួរដូចតទៅដោយសារតែលោកភ័យខ្លាចញ័រខ្លួន ដូច្នេះលោកប៉ានមើលការសម្លាប់ទាំងអស់មែនទេ នៅពេលដែលលោកពួននោះ ឬក៏លោកងាកមុខចេញ ដោយមិនប៉ានមើលទេ ដោយសារភ័យខ្លាច? នៅម៉ោង ០២:២៦នាទី សាក្សីគាត់និយាយថា ខ្ញុំនៅលបមើលរហូតដល់ចប់។ បន្ទាប់មកទៀតខ្ញុំលូន ហើយរត់ទៅសហករណ៍វិញ ខ្ញុំភ័យញ័រខ្លួន ហើយយប់ហ្នឹង ខ្ញុំដេកមិនលក់ទេ។

ខ្ញុំគិតថា នេះជាចម្លើយគ្រប់គ្រាន់ហើយសម្រាប់សហព្រះរាជអាជ្ញា។ ដូច្នេះខ្ញុំសួរទៅសាក្សីនូវ

សំណួរដដែល។ លោកសាក្សី លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាថា លោកនៅមើលរហូតដល់គេសម្លាប់ចប់ គឺប្រហែលជានៅម៉ោងដប់យប់។ លោកនៅរក្សាចម្លើយហ្នឹងទេ?

[០៩:៤០:១៦]

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ខ្ញុំភ័យខ្លាំងពេក ខ្ញុំក៏ស្រាប់តែស្វាត់ ខ្ញុំក៏--

**ប្រធានអង្គជំនុំ៖**

បានហើយ ចាំស្ដាប់! ឲ្យឆ្លើយតបនឹងសំណួរ។ សំណួរគេសួរប៉ុន្មាន? អំមិញគេមិនទាន់សួរអីទៀតណា? រក្សាចម្លើយ ឬក៏អត់ប៉ុណ្ណឹងតើ។ យើងណែនាំតាំងពីដើមទីមក ហើយនៅតែដដែលៗ។ អញ្ជើញបន្តទៀតមេធាវី!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងលោករក្សារចម្លើយដដែល ថាលោកបាននៅទីនោះរហូតដល់ម៉ោងដប់ តើអ៊ីចឹងទេ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទៗ ខ្ញុំបាទ។

**ស៖** ប៉ុន្តែឥឡូវនេះយើងនឹងព្យាយាមពន្យល់មើល ថាតើពេលប៉ុនណាដែលលោកនៅ។ លោកទៅដល់ម៉ោងប្រាំពីរ ហើយលោកនៅទីនោះដល់ដប់។ តើលោកយល់ស្របដែរឬទេថា លោកនៅទីនោះពីរបីម៉ោង? ហើយពិបាកនឹងយល់ថា ពីម៉ោងណាដល់ម៉ោងណា។ អ៊ីចឹងលោកបាននៅទីនោះ យ៉ាងហោចណាស់ក៏បីម៉ោងដែរ។ តើលោកយល់ស្របនឹងការគណនានេះទេ?

**ឆ៖** បាទ ខ្ញុំបាទយល់ស្រប។

**ស៖** អ៊ីចឹងនៅទីនេះ នេះមិនមែនជាអ្វីដែលលោកនិយាយទេ នៅពេលដែលលោកផ្ដល់បទសម្ភាសន៍ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ ដោយហេតុថានៅពេលដែលមើលឯកសារ E3/7778 នោះ លោកនិយាយថាលោកនៅទីនោះតែមួយម៉ោងទេ ប្រហែលមួយម៉ោង។ តើរឿងរឿងរ៉ាវនេះវាយ៉ាងដូចម្ដេច បើវាខ្វែងគ្នាបែបនេះ?

**ឆ៖** នៅពេលនោះខ្ញុំរន្ធត់ ភ័យខ្លាំង មិនបានជាគិតម៉ោង គិតពេលវេលាទេ វារន្ធត់ចិត្តពេក។ ខ្ញុំមានការភ្លេចភ្លាំង។

[០៩:៤៣:០៤]

**សះ** ប៉ុន្តែលោកសាក្សី ដោយហេតុថាសភាពការណ៍នោះគួរឲ្យភ័យខ្លាច អ៊ីចឹងខ្ញុំសួរថាហេតុអ្វីក៏លោកនៅទីនោះយូរម្ល៉េះ? បើលោកមានការភ័យខ្លាចខ្លាំងរន្ធត់ ម៉េចក៏មិនចាកចេញភ្លាមៗ? លោកនិយាយថាលោកបានទៅដល់ម៉ោងប្រាំពីរ ហើយមើលរហូតដល់ម៉ោងដប់ វា៣ម៉ោង។ អ៊ីចឹងលោកបានឃើញសភាពការណ៍អង្គហេតុដែលថាគួរឲ្យរន្ធត់ ចុះហេតុអ្វីបានលោកនៅ? តើលោកយល់ថា ជារឿងចម្លែកទេ លោកបានឃើញ ហើយមានការភ័យរន្ធត់ ហើយនៅយូរបែបនេះ?

**ឆះ** ខ្ញុំបាទបានឃើញមែនឯង យូរ។ តែស្រាប់តែអស់មនុស្សស្រែក ខ្ញុំក៏វិលត្រឡប់ភិតភ័យរត់មកកន្លែងការដ្ឋានវិញ។

**ប្រធានអង្គជំនុំ៖**

លោកស្តាប់សំណួរឲ្យបានខ្លឹមសារ ដែលគេសួរ ហើយឆ្លើយតបឲ្យចំសំណួរដែលសួរ។ លោកធ្វើអ៊ីចឹងគឺនៅយូរ និងមិនងាយចប់ទេ។ ចាំស្តាប់សំណួរឲ្យច្បាស់សិន ហើយបើមិនយល់ទេសួរគេវិញសុំឲ្យបញ្ជាក់សំណួរម្តងទៀត។ លោកស្រីមេធាវីបញ្ជាក់សំណួរចុងក្រោយរបស់លោកស្រីម្តងទៀត។ ស្តាប់សំណួរឲ្យយល់ បើមិនយល់ទេ សុំសួរបញ្ជាក់ម្តងទៀត សុំឲ្យគេសួរម្តង ដើម្បីយល់សំណួរ សឹមឆ្លើយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**សះ** លោកសាក្សី ហេតុអ្វីបានលោកនៅទីនោះយូរម្ល៉េះ នៅ៣ម៉ោង? តាមអ្វីដែលលោកនិយាយក្នុងករណីដែលថាលោកមានការភ័យរន្ធត់ ហេតុអីក៏នៅមើលដល់៣ម៉ោង មូលហេតុអី?

[០៩:៤៤:៥៧]

**លោក អ៊ុំ ស៊ន់៖**

**ឆះ** ខ្ញុំវាភ័យខ្លាំងពេក មិនដឹងជាម៉ោងណាម៉ោងណាៗ មិនដឹងជាម៉ោងប៉ុន្មានៗ ពេលនោះខ្ញុំវារន្ធត់ខ្លាំងពេក ខ្ញុំភ្លេចភ្លាំង មិនបានជាគិតអារឿងម៉ោង។

**ប្រធានអង្គជំនុំ៖**

សំណួរគេសួរថា លោកទៅដល់ហ្នឹងឃើញស្ថានភាពទិដ្ឋភាពដែលលោកឃើញហ្នឹង ភ័យរន្ធត់ខ្លាំងពេក ម៉េចក៏លោកនៅទ្រាំនៅទីនោះ ម៉េចក៏លោកមិនវិលត្រឡប់មកផ្ទះវិញភ្លាម មិនចាកចេញពីទីកន្លែងនោះមកវិញភ្លាម ហេតុអី?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ឃើញដូច្នោះ ខ្ញុំត្រឡប់មកវិញភ្លាមហ្នឹងឯង វាភ័យខ្លាំងពេក។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដូច្នេះសំណួរសួរថា អ៊ីចឹងលោកត្រឡប់ទៅផ្ទះភ្លាមៗ ឬក៏លោកនៅចាំមើលកន្លែងនោះរហូតដល់៣ម៉ោង?

**ឆ៖** ខ្ញុំមិនបានគិតអារឿងម៉ោងទេ។ ខ្ញុំពេលនោះ ខ្ញុំវាបាត់ព្រលួរវាយ បាត់ព្រលួរស្រែកទៅ ខ្ញុំក៏ឡប់មកវិញមក មិនបានជាគិតម៉ោងផង។

[០៩:៤៦:៣០]

**ស៖** ចំណុចមួយដែលខ្ញុំសូមឲ្យលោកបំភ្លឺដែរ លោកសាក្សី។ ពីខាងដើមលោកបញ្ជាក់ថា ពីរបីនាទីមុននេះ ថាៗលោកក៏ត្រូវមានការងារយាមដែរ ហើយលោកបានពន្យល់តុលាការថា លោកនឹងឈរយាមពីម៉ោងប្រាំពីរ ដល់ម៉ោងប្រាំបួន ហើយលោកយាមរៀងរាល់ថ្ងៃ។ អ៊ីចឹងខ្ញុំសួរលោកដូចតទៅនេះ តើមានន័យថា នៅថ្ងៃនោះលោកៗមិន លោកមិនបានបង្ហាញខ្លួន ឬក៏មិនបានបំពេញភារកិច្ចជាអ្នកយាមទេ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ កាលណោះខ្ញុំអត់បានយាមទេ យប់ដែល ថ្ងៃដែលគេធ្វើឃាតនោះ ខ្ញុំអត់បានយាមទេ ខ្ញុំមកការដ្ឋានវិញ។

**ស៖** អ៊ីចឹងសំណួររបស់ខ្ញុំទៅលោក គឺថាហេតុអ្វីដែលខ្ញុំសួរលោកពីខាងដើមនោះ ថាលោកត្រូវយាមរៀងរាល់ថ្ងៃ ចុះហេតុអ្វីក៏លោកឆ្លើយថា “បាទ យាមរៀងរាល់ថ្ងៃ”? ហេតុអីក៏យប់នោះលោកក៏មិនយាម?

**ឆ៖** បាទពេលនោះគឺផ្លាស់វេនគ្នា គេចាត់តាំងផ្លាស់វេនគ្នា បានជាចន្លោះប្រហោងនៅកន្លែងនោះ។

**ស៖** លោកមិនបានឆ្លើយនឹងសំណួរខ្ញុំទេ។ ហេតុអី នៅពេលដែលខ្ញុំសួរលោកពីខាងដើមហ្នឹងថា “ថាតើលោកយាមពីម៉ោងប្រាំពីរដល់ម៉ោងដប់រៀងរាល់យប់ឬ លោកបានឆ្លើយថា បាទ”?

**ឆ៖** ព្រោះវាចន្លោះប្រហោង គេដាក់វេនគ្នាយាម។ មួយយប់ម្នាក់ៗ ខ្ញុំក៏មិនបានជាចាំផង។

[០៩:៤៩:២០]

**ស៖** កាលពីថ្ងៃពុធប្រហែលជា០១:៥១នាទីល្ងាច ហើយលោកនិយាយថា លោកបានឮ ចាន់ថា

ត្រូវបានគេបញ្ជូនគាត់ទៅរៀនសូត្រ។ តើលោកអាចប្រាប់តុលាការបានទេ តើលោកបានព័ត៌មាននេះមកពីណា?

**ឆ៖** ដឹងតែដំណឹងថាគេចាប់យកទៅបាត់ហើយ មិនដឹងគេធ្វើអី ខ្ញុំក៏មិនដឹងដែរត្រង់នោះ។ ឃើញបញ្ចូលទៅក្នុងវត្តខ្សាច់នោះដដែល។

**ស៖** នៅពេលលោកនិយាយថា លោកបានឃើញបុគ្គលនេះត្រូវបានគេបញ្ជូនទៅវត្ត តើលោកចង់និយាយម៉េច? ថាតើលោកបានឃើញ ចាន់ថា ទៅវត្តហ្នឹងដែរឬទេ?

**ឆ៖** បាទ គេរឿងត្រង់ណោះ ឃើញតែគេចាប់យកទៅបញ្ចូលតាមផ្លូវវត្តនោះឯង។

**ស៖** អ៊ីចឹងសំណួរខ្ញុំៗសួរដដែល តើលោកបានឃើញគេយក ចាន់ថា ទៅវត្តនោះនៅពេលណា?

**ឆ៖** នៅពេលយប់ ដែលគេយកទៅ នៅពេលយប់។

**ស៖** នៅពេលយប់នោះ តើប្រហែលម៉ោងប៉ុន្មាន? ហើយថាលោកបានត្រឡប់ទៅផ្ទះ ទៅសហករណ៍ ហើយម៉ោងប្រាំពីរហ្នឹងលោកថា ជនរងគ្រោះហ្នឹងត្រូវបាននៅទីនោះរួចហើយ។ អ៊ីចឹង ថាតើលោកបានឃើញគេយក ចាន់ថា ពីកន្លែងមួយយកទៅវត្តនោះនៅពេលណា គឺថានៅម៉ោងប៉ុនណា?

**ឆ៖** ខ្ញុំបាទមិនបានជាគិតរឿងម៉ោងពេលវេលាទេ ប៉ុន្តែយកទៅពេលយប់។

**ស៖** ខ្ញុំមិនសួរអំពីពេលម៉ោងជាក់លាក់ទេ ខ្ញុំសួរថា តើពេលណា? តើលោកអាចប៉ាន់ប្រមាណគឺទាក់ទងទៅនឹងពេលម៉ោង។ អ៊ីចឹងគឺថា ខ្ញុំសួរថា តើលោកបានឃើញគាត់ដំបូងហ្នឹងនៅពេលណា នៅពេលដែលថា ឃើញគេយកគាត់ទៅហ្នឹងគឺឃើញនៅពេលណា?

[០៩:៥២:៤៧]

**ឆ៖** នៅពេលដែលឃើញនោះ នៅពេលយប់ហ្នឹងឯង ដែលឃើញហ្នឹង។ នៅពេលមិនទាន់ដូចថាងងឹតខ្លាំងទេ។ ឃើញគេបណ្តើរយកទៅ ខ្ញុំមិនដឹងថាគេយកទៅណាផង ស្រាប់តែដល់ទៅឃើញនៅកន្លែងតំបន់វ៉ែនោះ បានដឹងថា អ៎! នៅកន្លែងនោះឯង កន្លែងវត្តនោះឯង។

**ស៖** នៅពេលដែលលោកបានឃើញគាត់ តើ ស៊ង់ ហ្នឹងនៅជាមួយលោកដែរឬទេ?

**ឆ៖** កាលនោះ ស៊ង់ នោះ ស៊ាន ស៊ង់ នោះអត់បាននៅជាមួយខ្ញុំទេ។

**ស៖** តើនៅពេលដែលគេយកគាត់ទៅហ្នឹង តើ ចាន់ថា ហ្នឹងតែម្នាក់ឯងទេ ឬក៏មានអ្នកផ្សេងជាមួយដែរ?

**ឆ៖** អត់ទេ ពេលនោះដែលគេចាប់ ចាន់ថា ទៅតែម្នាក់ឯងទេ។

**ស៖** តើអ្នកណាជាអ្នកយកគាត់ចេញទៅ?

**ឆ៖** រឿងទាំងនោះ ខ្ញុំមិនដឹងដែរ។ មើលអ្នកដែលបណ្ដើរយកទៅនោះ មិនស្គាល់មនុស្សទៀត វាងងឹតព្រាលៗហើយ ខ្ញុំវាភ័យ នឹកឃើញថា អីយ៉ា! ចាប់មនុស្សទៅហើយ ចាន់ថា ទៅហើយ មិនដឹង ខ្ញុំមិនបានជាមើលមនុស្សនោះប៉ុន្មាននាក់ទៀតដែលចាប់។

**ស៖** ដូច្នេះខ្ញុំយល់ថា តាមចម្លើយរបស់លោកគឺថាមនុស្សទាំងអស់នេះ គឺមិនមែនជាឈ្លបទេ ដែលលោកបានរៀបរាប់ទៅសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកមិនបាននិយាយពីពួកកងឈ្លប ដែលនៅវត្តនោះទេ។

[០៩:៥៥:២៥]

**ឆ៖** បាទ ខ្ញុំមើលមិនស្គាល់ មិនដឹងជាឈ្មោះណាមួយៗទេ ខ្ញុំអត់ស្គាល់ឈ្មោះគេទេ កន្លែងនោះ ដែលគេចាប់ ចាន់ថា នោះ។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកខណៈពេលមួយដែលលោកនិយាយថា បានឃើញការកាប់សម្លាប់ នៅពេលឆ្លើយសំណួរមុននោះ គឺថាលោកមិនបានស្គាល់អ្នកផ្សេងទៀតទេ ក្រៅពី ចាន់ថា ហើយនិង ជីដូនជីតារបស់គាត់។ ថាតើអាចដែរទេ គឺថាសក្ខីកម្មចម្លើយរបស់លោកហ្នឹងកែប្រែ? អ៊ីចឹងគឺថាខ្ញុំនឹង សួរសំណួរលោកទាក់ទងទៅនឹងចម្លើយដែលលោកឆ្លើយនៅថ្ងៃពុធ នៅពេលដែលលោកនិយាយអំពី ហេតុការណ៍ ឬក៏អង្គហេតុអំពីថាគេយកប្រមាត់មនុស្ស ហើយលោកនិយាយថា គឺនៅពេលគឺថាមុន ម៉ោង០២:៤០នៅថ្ងៃពុធ លោកនិយាយថា ខ្ញុំសូមដកស្រង់សម្ដីលោក៖ "ខ្ញុំមិនដឹង តើមានមនុស្សប៉ុន្មាន នាក់ដែលត្រូវបានគេវះយកប្រមាត់ទេ ហើយថាមិនដឹងថាគេយកប្រមាត់ពីមនុស្សប៉ុន្មាននាក់ទេ។ តាម ពិតប្រមាត់ស្រីដែល -- ស្រីក្រមុំដែល -- ស្រីក្រមុំ គេយកប្រមាត់មក"។ អ៊ីសំណួរ ខ្ញុំសួរលោកថា សំណួរទី១ តើលោកបានឃើញដោយផ្ទាល់ភ្នែកអំពីហេតុការណ៍ហ្នឹងដែរឬទេ មានន័យថាហេតុការណ៍ គេវះមនុស្សយកប្រមាត់នោះ?

**ឆ៖** ខ្ញុំបាទមិនបានឃើញទេ។ តែដែលក្រោយដែលខ្ញុំទៅលបមើលក្រោយទៀត ដែលគេ សម្លាប់ក្នុងយប់នោះ ស្រាប់តែឃើញព្រឹកឡើង ខ្ញុំទៅមើលទៀត ស្រាប់តែឃើញប្រមាត់នោះព្យួរនៅ ជញ្ជាំងធាងដូង។ តែកំពុងដែលគេវះប្រមាត់នោះ ខ្ញុំមិនបានឃើញទេ។

[០៩:៥៧:៥៧]

**ស៖** ដូច្នេះហេតុអ្វីក៏លោកនិយាយថា ប្រមាត់នោះគឺជាប្រមាត់ដែលយកចេញពីរបស់ស្រីក្រមុំ?

តើយល់អ៊ីចឹងដូចម្ដេច បើលោកមិនបានឃើញគេវះយកពីស្រីក្រមុំផង លោកមកនិយាយថាស្រីក្រមុំ គេវះយកប្រមាត់? តើហេតុអីបានលោកនិយាយអ៊ីចឹងកើត?

**ឆ៖** អ៊ីចឹងវាមានក្មេងមានចាស់។ មិនមែនតែចាស់រហូតណាស់ ដែលយកទៅសម្លាប់ចោល។ ឃើញក្មេងផងចាស់ផងៗ--

**ស៖** លោកសាក្សី សូមអភ័យទោស សូមស្ដាប់សំណួររបស់ខ្ញុំ។ ខ្ញុំសួរថាច្បាស់ៗថា តើហេតុអ្វីដែលនាំឱ្យលោកនិយាយបែបនេះ? ពីព្រោះលោកនិយាយថា ដោយសារថា លោកមិនបានឃើញហេតុការណ៍នោះផង លោកមិនស្គាល់មនុស្សនោះផង ហើយអ្នកផ្សេងដែលលោកថាក្រៅពី ចាន់ថា លោកមិនស្គាល់ផង គឺថាហេតុអីក៏លោកហ៊ាននិយាយថា គេយកប្រមាត់ទាំងអស់ហ្នឹង គឺយកមកពីជនរងគ្រោះជាស្រីក្រមុំ ដែលគេសម្លាប់?

**ឆ៖** ទេ ខ្ញុំបានឃើញប្រមាត់នៅនឹងជញ្ជាំងផាងដូងនោះ មានតែប្រមាត់ពួកនោះ ដែលគេសម្លាប់នោះ។

**ស៖** ដូច្នេះនៅទីនេះលោកបានប្រាប់ខ្ញុំថា គឺផ្អែកលើការសន្និដ្ឋានរបស់ខ្លួន ការសន្និដ្ឋានរបស់លោកផ្ទាល់ដែលថា ប្រមាត់ទាំងអស់នោះគឺជាប្រមាត់របស់ស្រីក្រមុំ។ គឺជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់លោកទេ គឺលោកមិនបានឃើញហេតុការណ៍គេវះ ហើយគេយកដាក់កន្លែងហ្នឹងទេ។ តើអ៊ីចឹងឬក៏យ៉ាងណា?

[១០:០០:១៦]

**ឆ៖** បាទ មិនបានឃើញគេទេ ស្រាប់តែឃើញព្យួរនៅជញ្ជាំង មិនបានឃើញទេ ខ្ញុំក៏មិនបានឃើញដែរ។

**ស៖** ខ្ញុំចង់ឱ្យលោកបញ្ជាក់ចុងក្រោយ បំភ្លឺចុងក្រោយ ដើម្បីឱ្យប្រាកដ។ តើលោកពិតជាបានឃើញការសម្លាប់ ចាន់ថា ដោយផ្ទាល់ភ្នែកដែរឬទេ? តើលោកបានឃើញគេវះយកប្រមាត់របស់គាត់ដោយផ្ទាល់ភ្នែកចេញមកទេ?

**ឆ៖** ខ្ញុំបាទមិនបានឃើញគេវះ ចាន់ថា នោះទេ ដឹងគេវះពីពេលណាទេ ខ្ញុំមិនដឹងដែរអារឿង។ ប៉ុន្តែថ្ងៃដែលខ្ញុំទៅមើលព្រឹកឡើងទៅមើលនោះឃើញ តែប្រមាត់គេពាក់នឹងជញ្ជាំង ប៉ុន្តែមិនដឹងគេយកមកពាក់ពីអង្គាល់ណាទេ។

**ស៖** នៅពេលដែលលោកចាកចេញពីកន្លែងដែលលោកបានមើលនោះ តើលោកត្រឡប់ទៅផ្ទះ

វិញឬទេ?

**ឆ៖** បាទ ខ្ញុំបាទត្រឡប់ទៅផ្ទះវិញ។

**ស៖** តើ ស៊ាន ស៊ង់ ក៏ត្រឡប់ទៅផ្ទះរបស់គាត់ដែរឬទេ?

**ឆ៖** បាទ កាលណោះរត់ត្រឡប់ទៅផ្ទះវិញទាំងអស់គ្នា។

[១០:០២:៣០]

**ស៖** អ៊ីចឹងលោកបានចាកចេញពីកន្លែងហ្នឹងទាំងពីរនាក់ក្នុងពេលតែមួយ ហើយក៏ត្រឡប់ទៅផ្ទះវិញ គឺទៅផ្ទះម្នាក់ៗវិញរៀងខ្លួន គឺនៅក្នុងកន្លែងកងចល័ត។ តើអ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** ទៅកន្លែងការដ្ឋានសហគម សហករណ៍នោះវិញ។

**ស៖** ខ្ញុំសូមពិនិត្យមើលអ្វីដែលលោកបាននិយាយពីខាងដើមពីរបីនាទីខាងដើមនេះ ទាក់ទងទៅនឹងអង្គហេតុដែលលោកថា លោកបានឃើញថាគេយក ចាន់ថា ទៅដោយផ្ទាល់នោះគឺនៅខែធ្នូ ថ្ងៃពុធនោះលោកបាននិយាយ គឺមុនម៉ោង១០:២៧នាទី៖ "ខ្ញុំបានឮអ្នកភូមិនិយាយថា គេយក ចាន់ថា ទៅសិក្សា ទៅរៀនសូត្រ តែតាមពិតបន្ទាប់ពីនោះមក ក្រោយពីបាត់ ចាន់ថា ៣ថ្ងៃក្រោយមកលោកដឹងថា ចាន់ថា បានបាត់ខ្លួន។" ចប់សេចក្តីដកស្រង់។ នេះជាសម្តីរបស់លោក។ ផ្អែកលើចម្លើយរបស់លោកកាលពីថ្ងៃពុធ យើងយល់ថាមិនមែនលោកមិនបានឃើញការចាប់ខ្លួន ចាន់ថា នោះទេ គឺពីរបីថ្ងៃក្រោយមកដែលលោកបានដឹងថាបាត់ ចាន់ថា។ ប៉ុន្តែថ្ងៃនេះលោកនិយាយប្រាប់តុលាការថា លោកបានឃើញគេចាប់ខ្លួន ចាន់ថា ហើយបានឃើញគេបណ្តើរគាត់ទៅវត្ត។ អ៊ីចឹងសំណួរខ្ញុំសួរទៅលោកដូចខាងក្រោមនេះ តើចម្លើយណាដែលត្រឹមត្រូវ? ថាតើ៣ថ្ងៃក្រោយពីបាត់ ចាន់ថា ទើបបានលោកដឹងថាគេយក ចាន់ថា ទៅវត្តនោះ? ហើយចម្លើយមួយទៀត ឬ -- ហើយចម្លើយមួយទៀតលោកថា បានឃើញគេយក ចាន់ថា ទៅនៅពេលយប់ ពេលដែលលោកបានឃើញគេសម្លាប់នោះឯង។ តើចម្លើយណាមួយត្រឹមត្រូវដែលលោកត្រូវប្រកាន់យក?

**ឆ៖** ព្រោះក្នុងយប់ដែលគេសម្លាប់នោះ ខ្ញុំបាទបានអើតឃើញ បានជាខ្ញុំថា។

[១០:០៥:១៨]

**ស៖** សំណួររបស់ខ្ញុំ គឺមានលក្ខណៈជាក់លាក់ណាស់លោកសាក្សី។ តើលោកបានឃើញ ចាន់ថា នៅថ្ងៃនោះដែរឬទេ ឬក៏លោកបានដឹងក្រោយមកទេ ថានាងបានបាត់ខ្លួន?

**ឆ៖** វាដូចជាភ្លេចភ្លាំងកាលដែលភ័យរន្ធត់ខ្លាំង ហើយឃើញសូវស្រែក វាវ៉ៃខ្លាំងនោះឯង ខ្ញុំក៏

មិនបានជារាប់ប៉ុន្មាននាក់ៗនោះផង។ វាបន្តបន្ទាប់គ្នានោះឯង។

**ស៖** លោកសាក្សី លោកមិនឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ ខ្ញុំសួរឡើងវិញដើម្បីឲ្យលោកស្ដាប់ច្បាស់។ សំណួរខ្ញុំថាតើលោកបានឃើញ ចាន់ថា គេយកគាត់ទៅវត្តនៅថ្ងៃនោះ ហើយគេសម្លាប់គាត់នៅថ្ងៃនោះ ឬក៏ចម្លើយមួយទៀតនៅថ្ងៃទី០៩ ថ្ងៃពុធ ខែធ្នូ នោះ ហើយលោកៗបានឮពីអ្នកភូមិថា គេយក ចាន់ថា ទៅរៀនសូត្រ។ អ៊ីចឹងសំណួររបស់ខ្ញុំៗសួរថា តើចម្លើយណាមួយត្រឹមត្រូវដែលលោកឆ្លើយពីរខុសគ្នានេះ?

**ឆ៖** ដែលដឹងដំណឹងថាគេយក ចាន់ថា ទៅនោះ ខ្ញុំដឹងមែន ក៏ប៉ុន្តែដល់ក្រោយទៀត វារំលងថ្ងៃគ្នា ដែលខ្ញុំបានឃើញគេដឹកមួយឡានមកទៀតមកដាក់នឹងហោត្រ័យនោះ ក៏ពេលដែលគេធ្វើឃាតនោះហើយ ក៏ជុំគ្នាតែម្ដងនោះឯង ព្រោះយកមុនយកក្រោយ។

**ប្រធានអង្គជំនុំ៖**

សាក្សីវំឭកម្ដងទៀត លោកស្ដាប់សំណួរឲ្យបាន គេសួរតែករណី ចាន់ថា ទេ ហើយសំណួរនេះគឺសួរពីបញ្ហាជាក់អំពីចម្លើយរបស់លោកឆ្លើយខុសគ្នា រវាងពីចម្លើយលើកមុន និងចម្លើយលើកក្រោយៗពាក់ព័ន្ធជាមួយនឹងការចាប់ខ្លួន ចាន់ថា នេះ។ តើលោកប្រកាន់ជំហរយកចម្លើយមួយណាដែលថាវាត្រឹមត្រូវ វាពិតប្រាកដនោះ រឿងផ្សេងទៀត យើងបានប្រាប់ហើយ ចាំស្ដាប់សំណួរ សឹមឆ្លើយ។

[១០:០៨:២១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បាទ អ៊ីចឹងខ្ញុំសួរសំណួរឡើងវិញជាចុងក្រោយដើម្បីឲ្យលោកអាចនឹងឆ្លើយ។ តើលោកពិតជាបានឃើញ ចាន់ថា ពេលគេចាប់ខ្លួន ហើយយកទៅសម្លាប់នៅថ្ងៃនោះដដែល ហើយចម្លើយរបស់លោកពីមុនហ្នឹង គឺថាលោកបានឮពីអ្នកភូមិថាគេចាប់ ចាន់ថា ទៅ ហើយលោកបានឮពីការបាត់ខ្លួនរបស់ ចាន់ថា នោះបីថ្ងៃក្រោយមក។ អ៊ីចឹងចម្លើយពីរនេះវាខុសគ្នា តើណាមួយដែលថាលោកយល់ថាជាចម្លើយត្រឹមត្រូវរបស់លោក?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ប្រុស អត់ទោស ខ្ញុំច្រឡំ។ អារឿងនេះ ខ្ញុំច្រឡំថ្ងៃៗដែលគេនេះ ព្រោះវាច្រឡំ។

**ស៖** ឥឡូវនេះ លោកច្រឡំពីកាលបរិច្ឆេទ។ សំណួរគឺមិនទាក់ទងនឹងកាលបរិច្ឆេទទេ សំណួរសួរទាក់ទងថាតើ បាទ ឬក៏ទេ ថាតើលោកបានឃើញការចាប់ខ្លួន ចាន់ថា ហើយយកទៅសម្លាប់ដែរ

ឬទេ? អ៊ីចឹងខ្ញុំសួរថាតើលោកបានឃើញការចាប់ខ្លួន ហើយនិងការសម្លាប់ ចាន់ថា ដែរឬទេ? ឬក៏លោកបានឮពីការចាប់ខ្លួនគាត់ហ្នឹង ក្រោយពីគាត់បាត់ខ្លួនហើយ? អ៊ីចឹងគឺថានេះជាសំណួរខ្ញុំសូមសួរច្បាស់ៗ។ តើចម្លើយណាមួយដែលត្រឹមត្រូវ ដែលលោកប្រាកដថា លោកបានឃើញរឿង ចាន់ថា នោះ?

**ឆ៖** ខ្ញុំវាវង្វេងត្រង់កន្លែងគេចាប់មុន ចាប់ក្រោយយកទៅមុន។ វាច្រឡំថ្ងៃគ្នា។

[១០:១០:៤១]

**ស៖** ម្តងទៀតមុននឹងពេលសម្រាក លោកប្រធាន។ តើលោកសាក្សីអាចប្រាប់ចម្លើយណាមួយដែលត្រឹមត្រូវក្នុងចម្លើយពីរដែលគាត់បានឆ្លើយផ្ទុយគ្នានេះ ខុសគ្នានេះ?

**ឆ៖** ភ្លេចអស់។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំបញ្ចប់នូវសំណួររបស់ខ្ញុំនៅពេលនេះ លោកប្រធាន។ នេះជាពេលត្រឹមត្រូវដែលថាខ្ញុំបញ្ចប់ដល់ពេលម៉ោងសម្រាក។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ អរគុណលោក អ៊ុំ ស៊ន់ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈរបស់លោកជាសាក្សីដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះបាន។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ ហើយសូមលោកមានជួបតែសំណាង--

យ៉ាងម៉េចទៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំជឿថា មានការបកប្រែល្អៀង ប្រហែលជាមិនយល់ច្បាស់ទេ។ ខ្ញុំបញ្ចប់ការសំណួរអំពីកម្រងសំណួរខ្ញុំវគ្គនេះ ហើយខ្ញុំជម្រាបថា ខ្ញុំនឹងបន្តក្រោយពីសម្រាកតទៅទៀត។

**ប្រធានអង្គជំនុំ៖**

បាទ បើនិយាយឲ្យច្បាស់លាស់អ៊ីចឹងទៅ បើនិយាយថា បើចប់អស់សំណួរហើយ វាចប់ហើយមានអីត្រូវសួរទៀត។ បើថាផ្អាក បានន័យថា សំណួរវានៅទៀត។

បាទ ឥឡូវនេះដល់សមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ

រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ ហើយសូមរំឭកដល់មេធាវីថា សូមរៀបចំសំណួរសាមញ្ញ ស្រួលស្តាប់ ខ្លី ឲ្យសមទៅនឹងគោលដៅដែលលោកស្រីសួរចំពោះអ្នកដែលមិនសូវចេះអក្សរ មានកម្រិតវប្បធម៌ទាប។ បើពុំដូច្នោះគឺអាចសួរប្អូនដប់ថ្ងៃក៏អាចមិនចប់ដែរបញ្ហានេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមគោរពតាមការណែនាំរបស់លោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី មុននេះបន្តិចលោកនិយាយថា នៅថ្ងៃដែលលោកបានឃើញគេសម្លាប់មនុស្សគឺ ស៊ាន ស៊ង់ មកជួបលោកនៅផ្ទះ ហើយអ្នកទាំងពីរក៏ចេញទៅមើលទាំងពីរនាក់។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

[១០:៣៣:៣៨]

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅថ្ងៃនោះ មុនពេលទៅវត្ត តើលោកមានគ្រោងថានឹងទៅកន្លែងណាមួយទេ?

**ឆ៖** មិនបានជាចាប់អារម្មណ៍គ្រោងទៅឯណាទេ ស្រាប់តែឮសូរស្រែកហ្នឹង ក៏នាំគ្នាទៅលបមើលប៉ុណ្ណោះ។

**ស៖** លោកមិនមានបានសុំការអនុញ្ញាតទៅលេងគ្រួសារទេមែនទេ នៅថ្ងៃនោះ?

**ឆ៖** អត់ទេ អត់បានសុំទេ។

**ស៖** ខ្ញុំសួរសំណួរនេះពីព្រោះថា ស៊ាន ស៊ង់ បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី២៨ តុលា ២០១៥ ឯកសារ E1/358.1 នៅម៉ោង ០១:៤៤:៣១ ស៊ាន ស៊ង់ គាត់ថាលោកបានសុំទៅលេងគ្រួសារ គាត់ពន្យល់ថា គាត់គ្រោងទៅលេងបងប្អូន ហើយលោកហ្នឹងក៏ ខ្ញុំសូមដកស្រង់ គេសួរគាត់នៅពេលនោះដូចតទៅ៖ “ដើម្បីឲ្យបានច្បាស់ ថាយើងយល់លោកច្បាស់ មិត្តរបស់លោកគាត់និយាយពីលោក ក៏បានស្នើសុំទៅលេងគ្រួសារដែរនៅយប់នោះមែនទេ? ពេលនោះ ស៊ាន ស៊ង់ គាត់បានឆ្លើយថា៖ បាទ ត្រឹមត្រូវហើយ គឺយើងទាំងពីរនាក់បានសុំការអនុញ្ញាតទៅលេងគ្រួសារ។” តើលោកនឹកឃើញឡើងវិញទេ ថានៅថ្ងៃនោះ លោកសុំទៅលេងគ្រួសារ ឬក៏អត់?

**ឆ៖** ខ្ញុំភ្លេចភ្លាំង មិនបានជាចាប់អារម្មណ៍ផង កន្លែងចំណុចនេះ។ ខ្ញុំភ្លេចភ្លាំង។

[១០:៣៦:៤២]

**ស៖** ពេលដែលលោកឆ្លើយទៅនឹងសំណួររបស់មេធាវីដើមបណ្តឹង កាលពីថ្ងៃពុធ លោកថាកងយោធានិងកងឈ្លបដែលប្រចាំការនៅវត្តខ្សាច់ហ្នឹង គឺតាំងពីពេលចាប់ផ្តើមរបបមកម្ល៉េះ។ គឺនៅម៉ោង០៣:០៥នាទីរហូតដល់ម៉ោង០៣:២៦មួយនាទី លោកបាននិយាយបែបនេះ។ កាលពីថ្ងៃទី២៨ តុលា ឆ្នាំ២០១៥ គឺឯកសារដដែល គឺនៅម៉ោង១០:២៨នាទី ស៊ាន ស៊ង់ គាត់បាននិយាយថា នៅវត្តអត់មានពួកយោធាទេ។ តើលោកអាចបញ្ជាក់បានទេថា លោកច្បាស់ទេថា នៅវត្តហ្នឹងមានយោធាប្រចាំការទេ គឺតាំងពីឆ្នាំ៧៥មក? ពីព្រោះលោក ស៊ាន ស៊ង់ នោះគាត់បានឆ្លើយថា នៅវត្តហ្នឹងគឺមិនមានពួកយោធាណានៅប្រចាំការអីទេ។

**ឆ៖** មានដូច ស៊ាន ស៊ង់ ឆ្លើយមែន អត់មានទេ មានតែពួកកងឈ្លបទេ។

**ស៖** លោក១បានឆ្លើយថា គឺខាងកងយោធា មិនមែនឈ្លប កងឈ្លបទេ គឺវាកងពីរផ្សេងគ្នា។ ដូច្នេះលោកឥឡូវនេះ លោកឆ្លើយថា គឺមានតែកងឈ្លបទេ ដែលនៅប្រចាំការនៅវត្តនោះ។ មែនទេ?

**ឆ៖** បាទ មានពួកកងឈ្លបទេ គេត្រួតពិនិត្យនៅកន្លែងនោះ។

**ស៖** ដូច្នេះគឺលោកកែចម្លើយលោកកាលពីថ្ងៃពុធ មែនទេ? នៅពេលនេះលោកឆ្លើយថាគឺគ្មានយោធាទេ មានតែកងឈ្លបតែប៉ុណ្ណោះដែលឈរជើងនៅវត្ត មែនទេ?

**ឆ៖** កងឈ្លប និងយោធា ឃើញតែពួកគេនោះឯង ពួកហ្នឹងឯង -- អ្នកឃាតកម្មនៅកន្លែងនោះមានតែគេនោះឯង មិនដឹងណាមួយយោធា មិនដឹងណាមួយកងឈ្លប។

[១០:៣៩:៣៥]

**ស៖** អ៊ីចឹងនៅពេលដែលលោកនិយាយថា ស៊ាន ស៊ង់ ហ្នឹងនិយាយត្រូវ មានន័យថា លោកនិយាយតាម ស៊ាន ស៊ង់ គឺថាអត់មានយោធាទេ មានតែឈ្លប។ លោកយកចម្លើយតាមគាត់មែនទេ?

**ឆ៖** បាទ ខ្ញុំយកចម្លើយតាម ស៊ាន ស៊ង់ ហ្នឹងឯង។

**ស៖** អ៊ីចឹងខ្ញុំចូលទៅចំណុចផ្សេងទៀត។ ខ្ញុំយល់តាមរយៈសក្ខីកម្មរបស់លោកថា ចាន់ថា និងយាយតា ត្រូវបានសម្លាប់នៅវត្តខ្សាច់។ ដូច្នេះ ខ្ញុំចង់សួរលោកថាតើលោករក្សាចម្លើយនេះដដែលទេ?

**ឆ៖** ថារួចម្តងទៅហើយ ដឹងខ្ញុំថាម៉េចទៀត! ខ្ញុំមិនដឹងចាំឆ្លើយយ៉ាងម៉េចទៅទៀតទេ។

**ស៖** ដូច្នេះ ខ្ញុំគិតថាលោករក្សាចម្លើយដដែល។ សហព្រះរាជអាជ្ញាហាក់ដូចជាអានឲ្យលោកស្តាប់រួចមកហើយ ក៏ប៉ុន្តែខ្ញុំចង់បានចម្លើយជាក់លាក់ពីលោក។ សាក្សីមួយរូបគឺ 2-TCW-846 នៅក្នុងឯកសារស្តាប់ចម្លើយលេខ E3/7685 នៅក្នុង ERN ជាភាសាបារាំងគឺ 00333930, ERN ជាភាសាអង់គ្លេស 00275396, ERN ជាភាសាខ្មែរគឺ 00221617។ នៅក្នុងឯកសារនេះគាត់ សាក្សីគាត់បានឆ្លើយថា៖ "តាឃុត និងយាយម៉ា ដែលជាយាយតារបស់ ចាន់ថា ត្រូវបានគេសម្លាប់ចោលមួយថ្ងៃមុនថ្ងៃរំដោះ ១៧ មេសា ៧៥ គឺមុនពេលវៀតណាមវៃចូលមួយថ្ងៃ។ គាត់ថា៖ គេមិនមែនសម្លាប់នៅវត្តខ្សាច់ទេ គឺគេសម្លាប់នៅតំបន់--

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែស្តាប់មិនបានទេលោកប្រធាន ឈ្មោះនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

[១០:៤២:៤៥]

**ប្រធានអង្គជំនុំ៖**

ឈប់! ម្តងៗទៀត តាំងសំណួរចុងក្រោយអំមិញ ហើយសូមអាននូវទីកន្លែង ប្រកបទីកន្លែង

ឲ្យបានច្បាស់លាស់ ព្រោះអ្នកបកប្រែបកប្រែទីកន្លែងនុ៎ង គឺមិនអាចបកប្រែបានទេ។

**កញ្ញា អង់តា ហ្គីសសេះ**

សម្រាប់អ្នកបកប្រែគឺ ខ្ញុំបានប្រាប់ហើយគឺលេខ ឯកសារ E3/7685, ERN ជាភាសាខ្មែរគឺ 00221617 គឺជាទំព័រចុងក្រោយនៃកំណត់ហេតុ គឺកន្លែងនោះឈ្មោះថា "តំបន់អណ្ដូងនួន"។ ដូចខ្ញុំជឿជាក់ថា អ្នកបកប្រែគេអាចរកឈ្មោះកន្លែងនេះឃើញហើយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកសាក្សីគឺតំបន់អណ្ដូងនួន។ ខ្ញុំសួរឡើងវិញ។ លោកមានចម្លើយយ៉ាងណាតបទៅនឹងចម្លើយរបស់សាក្សីរូបនោះ? គាត់ថា ចាន់ថា និងយាយតាមិនមែនត្រូវបានសម្លាប់នៅវត្តខ្សាច់ទេ គឺសម្លាប់នៅតំបន់អណ្ដូងនួន ហើយគឺសម្លាប់ហ្នឹងគឺមុនពេលកងទ័ពវៀតណាមវាយចូលមកកម្ពុជាមុនមួយថ្ងៃតែប៉ុណ្ណោះ។

ខ្ញុំមិនដឹងថាការសួររបស់ខ្ញុំត្រូវបានបកប្រែ ឬក៏យ៉ាងណា ម៉េចក៏សាក្សីមិនឆ្លើយ?

**ឆ៖** ព្រោះកន្លែងថាយកទៅសម្លាប់ចោលអណ្ដូងនួន ខ្ញុំមិនស្គាល់អណ្ដូងនួននោះទៀតផង។ អត់ស្គាល់ទេ។

[១០:៤៥:៤៨]

**ស៖** ខ្ញុំសួរសំណួរនេះពីព្រោះថាលោក ស៊ាន ស៊ង់ នៅពេលដែលគាត់មកផ្ដល់សក្ខីកម្មនៅថ្ងៃទី ២៨ តុលា ឆ្នាំ២០១៥កន្លងទៅនេះ គាត់មិនដែលនិយាយថា ចាន់ថា និងយាយតាត្រូវបានសម្លាប់ក្នុងពេលតែមួយទេ។ ហើយលោកៗថា គេឃើញគេសម្លាប់អ្នកទាំងបីក្នុងពេលតែមួយ។ នេះជាចម្លើយរបស់ ស៊ាន ស៊ង់ គឺនៅម៉ោង១៣:៣៧:០៧វិនាទី គឺគេសួរគាត់ដូចតទៅ៖ "ចុះយាយតារបស់ ចាន់ថា នោះយ៉ាងម៉េចដែរ មានរឿងអ្វីកើតឡើងចំពោះពួកគាត់? ស៊ាន ស៊ង់ គាត់ឆ្លើយថា៖ ខ្ញុំមិនដឹងទេ។ គេសួរគាត់បន្តទៅទៀត យាយតារបស់នាងហ្នឹងឈ្មោះ តាឃុត និងយាយហៃ មែនទេ? គាត់ឆ្លើយថា៖ បាទ ត្រឹមត្រូវហើយ។ សួរ៖ មានសាក្សីមួយរូបគឺ E3/7685 បានអះអាងថា យាយតារបស់ ចាន់ថា ហ្នឹងត្រូវបានសម្លាប់គឺមួយថ្ងៃមុនថ្ងៃរំដោះតែប៉ុណ្ណោះ គឺមុនពេលវៀតណាមវាយចូល។ លោកធ្លាប់ស្ដាប់ឮគេនិយាយពីរឿងហ្នឹងទេ? ពេលនោះ ស៊ាន ស៊ង់ គាត់បានឆ្លើយថា៖ ខ្ញុំឮអ្នកផ្សេងក៏និយាយថាអ៊ីចឹងដែរ។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ស៊ាន ស៊ង់ នេះដែលលោកថាគាត់នៅជាមួយលោកដែរនោះនៅយប់នោះ គាត់ឆ្លើយថា គាត់មិនដឹងថាមានរឿងអ្វីកើតឡើងចំពោះយាយតារបស់ ចាន់ថា ទេ។

ហើយគាត់ឮគេនិយាយថា យាយតារបស់ ចាន់ថា នោះត្រូវបានគេសម្លាប់មួយថ្ងៃមុនពេលកងទ័ពវៀតណាមវាយចូល។ ដូច្នេះលោកអាចឆ្លើយយ៉ាងម៉េចបានពាក់ព័ន្ធនឹងចម្លើយរបស់លោកដែលវាផ្ទុយគ្នាទៅនឹងចម្លើយរបស់ ស៊ាន ស៊ីង់ នោះ?

[១០:៤៨:២១]

**ឆ៖** ខ្ញុំមិនដឹងទេ រឿងត្រង់ណោះ។

**ស៖** លោកមិនដឹងអ្វីទេ ក៏ប៉ុន្តែមុននេះនៅពេលដែលខ្ញុំសួរលោកថា តើយាយតា ចាន់ថា នៅជាមួយ ចាន់ថា ឬក៏អត់នៅក្នុងវត្តនោះ? លោកឆ្លើយថា បាទលោកឃើញអ្នកទាំងបី ដោយសារតែពេលនោះគេអុជចង្កៀង។ ដូច្នេះលោកកែចម្លើយរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** ព្រោះមើលមិនច្បាស់ដែរកន្លែងត្រង់នោះ។ ខ្ញុំមិនសូវដឹងដែរត្រង់នោះ។ វាភ័យខ្លាំងពេក។

**ស៖** ដូច្នេះត្រឹមត្រូវទេ បើខ្ញុំនិយាយថា លោកមិនដឹងអ្នកណាជាអ្នកណាទេ នៅក្នុងវត្តនោះៗ?

**ឆ៖** ខ្ញុំមិនដឹងជាអ្នកណាជាអ្នកណាទេ ក្នុងវត្តនោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** អ៊ីចឹងសំណួរចុងក្រោយមួយ ខ្ញុំឮការបកប្រែ លោកសាក្សី តើៗលោកឆ្លើយថាលោកមិនដឹងអ្វីកើតឡើង ឬក៏លោកមិនដឹងអ្នកណាជាជនរងគ្រោះ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ខ្ញុំមិនបានស្គាល់ឈ្មោះគេអស់ទេ។

**ស៖** តើឈ្មោះរបស់ជនរងគ្រោះ ហើយនិងឈ្មោះរបស់អ្នកសម្លាប់ តើលោកស្គាល់ដែរឬទេ?

**ឆ៖** កាលនៅក្នុងវត្តនោះ ពួកកងឈ្លបគេនោះស្គាល់ឈ្មោះ មិត្តមុយ, មិត្តយត។ ឈ្មោះ យត, ឈ្មោះ មុយ។

[១០:៥១:៤៨]

**ស៖** ដូច្នេះនៅពេលដែលលោកមិនស្គាល់ឈ្មោះគេទេ ឬក៏លោកចង់និយាយថា លោកមិនស្គាល់ឈ្មោះអ្នកដែលត្រូវគេសម្លាប់។ អ៊ីចឹងឬដូចម្តេច?

**ឆ៖** មិនស្គាល់ទេត្រង់ណោះ មិនស្គាល់ទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោក អ៊ុំ ស៊ន់ ឥឡូវការស្តាប់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជានឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ុំ ស៊ន់ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយសវនាការជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-805។ ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-805 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សី 2-TCW-949 ចេញពីបន្ទប់សវនាការ)*

*(សាក្សី 2-TCW-805 ចូលក្នុងបន្ទប់សវនាការ)*

[១០:៥៤:៤២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី តើលោកស្រីឈ្មោះអី?

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ខ្ញុំឈ្មោះ អ៊ុង សំអ៊ាន។

**ស៖** អរគុណលោកស្រី អ៊ុង សំអ៊ាន។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរទេ?

**ឆ៖** ខ្ញុំអត់ចាំផងលោកគ្រូ។

**ស៖** ឆ្នាំនេះលោកស្រីអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំអាយុ៦៣។

**ស៖** អរគុណ។ ហើយលោកស្រី សំអ៊ាន តើទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ខ្ញុំនៅភូមិក្រហម-ក។

**ស៖** ភូមិស្រុកខេត្ត?

**ឆ៖** ភូមិក្រហម-ក គ្រាន់តែឆ្លើយភូមិក្រហម-ក ឃុំចន្ត្រី ស្រុករមាសហែក ខេត្តស្វាយរៀង។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់ស្រី តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំនៅភូមិក្រហម-ក ដដែលលោកគ្រូ។

[១០:៥៦:០៣]

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ម្ដាយខ្ញុំ ឪពុកខ្ញុំ ឈ្មោះ អ៊ុង ឌុល ម្ដាយឈ្មោះ មាស អន។

**ស៖** អរគុណ។ ចុះប្ដីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីខ្ញុំឈ្មោះ ហាស់ ផេង កូនខ្ញុំមួយ។

**ស៖** អរគុណលោកស្រី អ៊ុង សំអ៊ាន។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកស្រីអាចដឹងបាន គឺលោកស្រីមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ក៏ដូចជាជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីនៃដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវលោកគ្រូ។

**ស៖** ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកនៅពីខាងកើតសាលសវនាការនេះហើយឬនៅ?

**ឆ៖** ខ្ញុំបានទៅធ្វើហើយលោកគ្រូ។

[១០:៥៧:២៨]

**ស៖** អ៊ុង សំអ៊ាន តទៅនេះ ក្នុងឋានៈលោកស្រីជាសាក្សី យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះដូចខាងក្រោមនេះ។ អំពីសិទ្ធិ ក្នុងឋានៈលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការធ្វើឱ្យលោកស្រីធ្វើអត្ថាធិប្បាយដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចនៅក្នុងឋានៈលោកស្រីជាសាក្សី លោកស្រីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត -- ត្រូវឆ្លើយតបនូវរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោកស្រី ឬការធ្វើអត្ថាធិប្បាយរៀបរាប់របស់លោកស្រីហ្នឹងនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

លោកស្រី អ៊ឹង សំអ៊ាន តើកន្លងមកធ្លាប់បានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា ធ្វើនៅពេលណា? ចាំដែរទេ?

**ឆ៖** ខ្ញុំមានធ្វើនៅកន្លែងណា លោកគ្រូ គេទៅសួរនៅតែឯផ្ទះ។

**ស៖** កាលសួរនៅផ្ទះហ្នឹង តើសួរនៅឆ្នាំណា ហើយចាំដែរទេ?

**ឆ៖** ខ្ញុំអត់ចាំឆ្នាំផង លោកគ្រូ យូរហើយ។

[១០:៥៩:២៨]

**ស៖** ហើយកាលនុ៎ងគេសួរប៉ុន្មានដង?

**ឆ៖** គាត់ទៅសួរម្តងលោកគ្រូ។

**ស៖** លោកស្រី អ៊ឹង សំអ៊ាន តើលោកស្រីចេះអក្សរដែរទេ?

**ឆ៖** ខ្ញុំអត់ចេះផង លោកគ្រូ។

**ស៖** បាទ អរគុណ។ ចុះមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកស្រីបានស្តាប់ការអាននូវសក្ខីកម្មរបស់លោកស្រី ដែលបានផ្តល់បទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននៅនឹងផ្ទះរបស់លោកស្រី ដែលលោកស្រីថា បានធ្វើជាច្រើនឆ្នាំកន្លងមកហើយនោះដែរឬទេ? មានអ្នកណាអានឲ្យស្តាប់ដែរឬទេ នូវចម្លើយដែលលោកស្រីបានផ្តល់សក្ខីកម្មកាលពីពេលមុននោះ?

**ឆ៖** បានអានឲ្យស្តាប់ហើយលោកគ្រូ។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបានថាតើលោកស្រីអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអាន ត្រូវបាន

អ្នកផ្សេងទៀតអានឲ្យលោកស្រីស្ដាប់ដើម្បីរំឭកការចងចាំនោះ ពិតជាមានខ្លឹមសារត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកស្រីបានផ្ដល់កិច្ចសម្ភាសន៍កាលពីពេលមុននៅនឹងផ្ទះរបស់លោកស្រីដែរឬទេ?

**ឆ៖** ត្រឹមត្រូវលោកគ្រូ ដូចខ្ញុំឆ្លើយនៅឯផ្ទះខ្ញុំអ៊ីចឹង គាត់អានឲ្យស្ដាប់។

[១១:០១:០៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សូមជម្រាបសួរលោកស្រីថា នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តើលោកស្រីរស់ភូមិ ឃុំ និងស្រុកណាដែរ?

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ខ្ញុំនៅភូមិក្របាម-ក ឃុំចន្ត្រី ស្រុករមាសហែក ខេត្តស្វាយរៀងលោកគ្រូ។

**ស៖** ហើយលោកស្រីរស់នៅទីនោះក្នុងអំឡុងពេលហ្នឹងរហូត ឬក៏មានផ្លាស់ប្ដូរទីលំនៅទៅណាដែរ?

**ឆ៖** ផ្លាស់លោកគ្រូ។ វាផ្លាស់ខ្ញុំទៅនៅស្រុកតាកែវអ្ហ្ន។

[១១:០២:៥០]

**ស៖** កាលនោះនៅឆ្នាំណាដែរ?

ឆ៖ ៧៩។

ស៖ នៅខែណានៃឆ្នាំ៧៩?

ឆ៖ នៅខែ--

**ប្រធានអង្គជំនុំ៖**

កុំៗអាលទាន់ឆ្លើយ! កុំអាលទាន់ឆ្លើយតប!

**លោកស្រី អ៊ឹង សំអ៊ាន៖**

ឆ៖ មិនដឹងនៅខែណាទេ លោកគ្រូ ខ្ញុំអត់ដឹងដែរ តែខ្ញុំទៅបានតែមួយអាទិត្យ គេឲ្យមកវិញ។

**សួរដោយលោក ស្រ៊ា រតនៈ៖**

ស៖ តើបើលោកស្រីអត់ចាំខែអ៊ីចឹង តើនៅបើប្រៀបធៀបជាមួយនឹងថ្ងៃរំដោះ ០៧ មករា ឆ្នាំ ១៩៧៩ តើមានរយៈពេលប៉ុន្មានមុនពេលថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ នៅពេលដែលគេបញ្ជូនលោកស្រីទៅខេត្តតាកែវហ្នឹង?

ឆ៖ មិនដឹងឆ្នាំប៉ុន្មានលោកគ្រូ ខ្ញុំអត់ដឹងទៅ គេផ្លាស់ទៅបានតែមួយអាទិត្យ គេឲ្យមកវិញ។ រំដោះមកវិញ គេមិនឲ្យមកវិញទេ រំដោះមកវិញ។

ស៖ អ៊ីចឹងបើខ្ញុំស្ដាប់មិនច្រឡំទេ បានន័យថាលោកស្រីត្រូវបានគេបញ្ជូន -- លោកស្រីរស់នៅក្នុងភូមិក្រហម-ក ឃុំចន្ទ្រី ស្រុករមាសហែករហូតក្នុងចន្លោះឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ៧៩ មួយអាទិត្យមុនថ្ងៃរំដោះ០៧ មករា ឆ្នាំ១០៧៩*(ស៊ីក)* មែនទេបាទ?

[១១:០៤:៤៦]

ឆ៖ ចាស។

ស៖ នៅក្នុងភូមិរបស់លោកស្រី នៅក្នុងភូមិក្រហម-ក នៅឯខេត្តស្វាយរៀងហ្នឹង តើលោកស្រីដឹងថាមានប្រជាពលរដ្ឋ -- មានប្រជាជនវៀតណាមរស់នៅទីនោះទេ?

ឆ៖ មាននៅខ្លះៗដែរ លោកគ្រូ។

ស៖ តាមដែលលោកស្រីស្គាល់ និងបានដឹង តើមានប៉ុន្មានគ្រួសារដែរ?

ឆ៖ បីបួនគ្រួសារ លោកគ្រូ វាកើតនៅហ្នឹងហ្មង តាំងពីសង្គម។

ស៖ លោកស្រីស្គាល់ពួកគាត់ទេ អាចស្គាល់ពួកគាត់មានឈ្មោះអីខ្លះទេ?

ឆ៖ មិនសូវស្គាល់ទេលោកគ្រូ វានៅឆ្ងាយៗពីគ្នាដែរ វានៅត្រពាំងរុន ខ្ញុំនៅក្រហម-ក អ៊ីចឹង

លោកគ្រូ។

**ស៖** ឆ្ងាយពីគ្នាហ្នឹង ភូមិផ្សេងគ្នា ឬយ៉ាងម៉េច ហើយមានចម្ងាយប៉ុន្មានដែរ ដែលលោកស្រីអះអាងថាឆ្ងាយហ្នឹង?

[១១:០៦:២៥]

**ឆ៖** ១គីឡូដីអី លោកគ្រូ ហើយមិនដែលបានដើរ មិនសូវស្គាល់វាផង។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាជាតិ សហព្រះរាជអាជ្ញារងជាតិ គប្បីតាំងសំណួរអង្កន់ខ្លីទៅ ហើយលោកសួរគាត់ជាប់ពីរពាក្យអម្បាញ់មិញថា ភូមិដោយឡែកពីគ្នា ហើយនិងចម្ងាយពីគ្នាប៉ុន្មាន? គាត់ឆ្លើយថា ១គីឡូ។ វាអត់ច្បាស់លាស់ទេ។ ប្រសិនបើលោកសួរដាច់ពីគ្នាជាពីរ គឺវាច្បាស់លាស់ជាង។ ហើយអំមិញយើងសួរហើយ ថាគាត់អត់ចេះអក្សរទេ។ ក្នុងន័យនេះ គឺចង់ឲ្យភាគីមានការប្រយ័ត្នប្រយែងរៀបចំសំណួរឲ្យបានល្អ ឲ្យងាយយល់ ដើម្បីឲ្យគោលដៅ ដែលមិនសូវចេះ មិនមានកម្រិតវប្បធម៌ខ្ពង់ខ្ពស់ហ្នឹងអាចយល់ និងឆ្លើយតបបានត្រឹមត្រូវ។ វាសំខាន់ គឺសួរដេញដោលហ្នឹង គឺអ្នកគោលដៅដែលផ្តល់សក្ខីកម្មហ្នឹងស្តាប់សំណួរបាន ហើយឆ្លើយតបអំពីអង្គហេតុដែលគាត់ដឹង ច្បាស់លាស់។

**លោក ស្រ៊ា រតនៈ៖**

បាទ លោកប្រធាន ខ្ញុំនឹងព្យាយាមធ្វើតាមអ្វីដែលលោកប្រធានបានលើកឡើង។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** តើលោកស្រី ហើយនិងជនជាតិវៀតណាមទាំងនោះ រស់នៅភូមិផ្សេងពីគ្នាមែន?

**លោកស្រី អ៊ុំង សំអ៊ាន៖**

**ឆ៖** នៅភូមិផ្សេងពីគ្នា លោកគ្រូ។

**ស៖** ចុះលោកស្រីសម្គាល់លើអ្វី បានដឹងថាពួកគាត់ហ្នឹងជាជនជាតិវៀតណាម?

**ឆ៖** វាធ្លាប់រែកអីៗមកលក់នៅភូមិខ្ញុំ។

[១១:០៨:២៥]

**ស៖** ចុះលោកស្រីបានដឹងទេថា មានអ្វីកើតឡើងចំពោះពួកគាត់ នៅក្នុងចន្លោះឆ្នាំពី៧៥ ដល់ឆ្នាំ៧៩? តើពួកគាត់ -- តើមានអ្វីកើតឡើងចំពោះពួកគាត់?

**ឆ៖** ដល់ហើយទៅណាណីបាត់អស់ទៅ ទៅស្រុកវាវិញបាត់អស់ទៅ គេដេញទៅ។ មានកើត

ម៉េច ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកស្រីដឹងថា ដែលពួកគាត់ -- ខ្ញុំប្រើពាក្យលោកស្រី "ត្រូវបានគេដេញទៅ" ហ្នឹង នៅឆ្នាំណា?

**ឆ៖** ខ្ញុំអត់ដឹងឆ្នាំណាទេ លោកគ្រូ ព្រោះអត់បានដឹង បានគិតផង។

**ស៖** ចុះលោកស្រីមានបានដឹងថា គេចាប់ជនជាតិវៀតណាមយកទៅទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ លោកគ្រូ ស្រាប់បាត់អស់ទៅពីភូមិទៅ។ គេទៅស្រុកគេវិញមិនដឹង គេទៅឯណាមិនដឹង ខ្ញុំអត់ដឹងផង។

**ស៖** ដើម្បីរំឭកដល់ការចងចាំរបស់លោកស្រី នៅក្នុងឯកសារ D166/55 ដែល ERN ជាភាសាខ្មែរ 00250719, ជាភាសាបារាំង 00282908, ជាភាសាអង់គ្លេស 00268645 លោកស្រី គឺខ្ញុំសូមបញ្ជាក់ឡើងវិញ គឺឯកសារ E3/7796 ដែលមាន ERN ដូចដែលខ្ញុំរៀបរាប់ខាងដើមអំមិញនេះ។ លោកស្រីបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថា៖ "នៅឆ្នាំ១៩៧៧ កូនកាត់វៀតណាមចំនួនបួន ឬប្រាំនាក់ ដែលមានឪខ្មែរ ម៉ែយួន ខ្លះឪយួន ម៉ែខ្មែរ ត្រូវគេចាប់យកទៅបាត់រហូត។ អ្នកទាំងនោះរស់នៅក្នុងភូមិក្រហម-ក យូរមកហើយ។" តើលោកស្រីនៅនឹកឃើញហេតុការណ៍នៃការចាប់កូនយួន និងកូនកាត់វៀតណាមបួន ឬប្រាំនាក់នោះទេ?

[១១:១១:៤៥]

**ឆ៖** អង្កាល់ហ្នឹងចាប់មែន លោកគ្រូ ចាប់ទៅបាត់អស់ទៅ ខ្ញុំនៅចាំ។

**ស៖** តើលោកស្រីបានឃើញផ្ទាល់ភ្នែកឬទេ ហេតុការណ៍នុ៎ង?

**ឆ៖** ខ្ញុំឃើញ បានខ្ញុំហ៊ានថា។ បើខ្ញុំមិនឃើញ ខ្ញុំមិនហ៊ានថាទេ ខ្ញុំមិនហ៊ាននិយាយទេ។

**ស៖** តើការចាប់នោះកើតឡើងនៅម៉ោងប៉ុន្មាន?

**ឆ៖** នៅល្ងាចលោកគ្រូ មិនដឹងម៉ោងប៉ុន្មាន តែល្ងាចពេលថ្ងៃរសៀល។

**ស៖** ហើយអ្នកណា អ្នកគេមកចាប់ហ្នឹង?

**ឆ៖** ខ្ញុំអត់ -- ខ្ញុំអត់ស្គាល់ទេលោកគ្រូ។

**ស៖** មានគ្នាប៉ុន្មាននាក់ អ្នកមកហ្នឹង?

**ឆ៖** ពីរនាក់។

**ស៖** គេស្លៀកពាក់បែបម៉េច? ហើយមាន -- គេស្លៀកពាក់បែបម៉េច?

**ធ៖** គេស្លៀកពាក់ធម្មតា ដូចតែយើងអ៊ីចឹង។

**ស៖** ធម្មតាហ្នឹង ម៉េចទៅ?

**ធ៖** ស្លៀកពាក់ខោអាវធម្មតា ដូចដែលយើង ខោខ្មៅ អាវខ្មៅ អ៊ីចឹងលោកគ្រូ។

**ស៖** ពួកគេមានកាន់កាំភ្លើងទេ?

**ធ៖** អត់មានទេ លោកគ្រូ ទទេ។

[១១:១៩:០២]

**ស៖** ចុះបើអត់កាំភ្លើង មានកាំបិត មានដំបងអីទេ?

**ធ៖** គ្មានកាំបិត គ្មានដំបងអីទេ គេមកហៅទៅៗៗ។

**ស៖** ចុះការដែលចាប់ហ្នឹង គេមក នៅពេលដែលមកចាប់ហ្នឹង តើពួកក្មេងៗហ្នឹងនៅជុំគ្នា ឬក៏នៅផ្សេងពីគ្នា?

**ធ៖** នៅជុំគ្នាលោកគ្រូ។ គេថាយកទៅណេះ ទៅណោះទៅ គេមកយកទៅហ្នឹង។

**ស៖** ពេលគេមកដល់ហ្នឹង គេប្រាប់ថាម៉េច?

**ធ៖** ពេលគេមកដល់ គេថាយកទៅកងចល័ត កងអីអ៊ីចឹងលោកគ្រូ។

**ស៖** ចុះការចាប់ហ្នឹង ប្រើរយៈពេលប៉ុន្មានដែរ?

**ធ៖** មានយូរណាលោកគ្រូ គ្រាន់តែមកតែមួយភ្លែតៗ គេថាទៅកងចល័ត។

**ស៖** និយាយពីពួកកូនកាត់វៀតណាមនោះវិញ តើពួកហ្នឹងមានអាយុប៉ុន្មានខ្លះ ប្រហែលប៉ុន្មាន?

**ធ៖** ប្រហែល១០ឆ្នាំ, ១៥ឆ្នាំហ្នឹង លោកគ្រូ ប៉ុនៗហ្នឹង ល្មមចូលកងចល័តអស់ហើយ។

**ស៖** ពួកហ្នឹងមកពីប៉ុន្មានគ្រួសារ បានន័យថា គេមានម៉ែឪជាបង -- សូមទោស ខ្ញុំសូមរៀបចំសំណួរឲ្យៗៗស្រួលស្ដាប់។ ពួកហ្នឹងមកពីប៉ុន្មានគ្រួសារ?

**ធ៖** ពីរបីគ្រួសារ លោកគ្រូ។

[១១:១៧:២១]

**ស៖** តើអ្នកដែលអ្នកស្រីសម្គាល់ថាលោកស្រីសម្គាល់ថា កូនកាត់ខ្មែរ-វៀតណាមហ្នឹង ពួកហ្នឹងនិយាយខ្មែរច្បាស់ទេ?

**ធ៖** និយាយច្បាស់តើ លោកគ្រូ។ វានិយាយតែខ្មែរ មាននិយាយចិន និយាយយួនអីវា។

**ស៖** ចុះម៉េចលោកស្រីស្គាល់ថា ពួកក្មេងៗហ្នឹង ជាកូនកាត់ខ្មែរវៀតណាម?

ធ៖ ឪខ្មែរ ម៉ែយួនអ៊ីចឹងទៅ ម៉ែយួនឪខ្មែរ ចឺខ្ញុំមិនស្គាល់ ខ្ញុំមិនដឹង។

ស៖ ពេលៗដែលគេនាំទៅហ្នឹង គេៗដឹកអីទៅ ឬក៏គេបណ្ដើរទៅ?

ធ៖ គេបណ្ដើរទៅហ្នឹង លោកគ្រូ មានអីដឹក កងចល័តជិតៗផ្ទះ ប្រព័ន្ធភ្លឺស្រែ ប្រព័ន្ធអីហ្នឹង។

ស៖ គេមានចងទេ?

ធ៖ គេគ្មានចងទេ។

ស៖ ចុះលោកស្រីដឹងថាគេនាំទៅណាទេ?

ធ៖ គេនាំទៅ គេថាគេយកទៅចូលកងចល័តលោកគ្រូ មិនដឹងថាគេនាំទៅនៅឯណាវិញ។

ស៖ ចុះចាប់តាំងពីពេលនោះមក លោកស្រីដែលឃើញពួកគាត់ទៀតទេ?

ធ៖ ខ្ញុំអត់ដែលឃើញផង បើខ្ញុំទៅតែធ្វើការដែរ ប្រព័ន្ធភ្លឺស្រែដូចតែគ្នា។

ស៖ ចុះចំពោះឪពុកម្ដាយពួកគេវិញ នៅពេលហ្នឹង មានអីកើតឡើងចំពោះពួកគេ?

ធ៖ មានអីកើតឡើងចំពោះពួកគេទេ ទទេ ព្រោះទាំងខ្មែរទាំងយួនទាំងចិនអី សុទ្ធតែកងចល័ត សុទ្ធតែប្រព័ន្ធភ្លឺស្រែ ទៅលើកប្រឡាយ ជីកប្រឡាយអីហ្នឹង លោកភ្លឺស្រែភ្លឺអី លោកគ្រូ។

[១១:២០:៤២]

ស៖ ខ្ញុំចង់សួរថា តើឪពុកម្ដាយរបស់ក្មេងដែលត្រូវគេនាំទៅកាលនុ៎ង គាត់ត្រូវបានគេបញ្ជូនទៅណាដែរទេ?

ធ៖ មានទៅណាគាត់នៅតែផ្ទះ។ គាត់នៅនឹងផ្ទះដែរម៉ែឪ។

ស៖ ខ្ញុំចង់សួរបញ្ជាក់ថែមបន្តិចទៀតពាក់ព័ន្ធនឹងករណីនេះ។ លោកស្រីលើកឡើងថា គាត់នៅផ្ទះ ប៉ុន្តែខ្ញុំចង់បញ្ជាក់អំពីពេលវេលានៅកាលនុ៎ង គឺលោកស្រីបានលើកឡើងតាមឯកសារដែលខ្ញុំរៀបរាប់ពីខាងដើម ថានៅឆ្នាំ១៩៧៧។ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់លោកស្រីអំពីពួកគាត់ ឪពុកម្ដាយរបស់ក្មេងៗបន្ទាប់ពីត្រូវបានគេនាំយកទៅបាត់នុ៎ង។ តើពួកគាត់បន្តរស់នៅផ្ទះហ្នឹងទៀត ឬក៏គាត់ត្រូវបាន ឬក៏លោកស្រីលែងបានឃើញគាត់ទៀត?

ធ៖ ខ្ញុំអត់បានឃើញទៀតទេលោកគ្រូ ព្រោះខ្ញុំទៅតែជីកប្រឡាយដែរ អត់បានឃើញគាត់នៅផ្ទះទៀតផង។ ខ្ញុំទៅឆ្ងាយៗទៅឯកើតស្វាយរៀងឯណោះ ខ្ញុំ។

ស៖ បានន័យថា លោកស្រីមិនដឹងពីភ័ព្វវាសនារបស់ជនជាតិវៀតណាមដែលជាឪពុកម្ដាយក្មេងទាំងនោះទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេលោកគ្រូ។

[១១:២២:៣៩]

**លោក ស្រ៊ា រតនៈ៖**

លោកប្រធាន ខ្ញុំបាទអស់សំណួរត្រឹមនេះ ហើយសុំការអនុញ្ញាតជូនវេទិកាទៅសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងឈល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងឈល៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំឈ្មោះ វ៉ាំងសង់ វ៉ាយដ៍។ ខ្ញុំនឹងបន្តសួរទៅកាន់លោកស្រីតាំងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំនឹងនិយាយលម្អិតអំពីបញ្ហាជនជាតិវៀតណាម។ ខ្ញុំនឹងធ្វើមួយជំហានម្តងៗ។ សូមលោកស្រីស្តាប់ឲ្យបានច្បាស់ ហើយឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំចង់ដឹងថាមានអ្វីកើតឡើងចំពោះបងរបស់លោក មាស សាខន ហើយនិងអាជ្ញាធរផ្សេងៗនៅក្នុងតំបន់ និងស្រុករបស់លោកស្រី? ខ្ញុំចង់សួរលោកស្រីជាដំបូងថាតើស្រុករមាសហែកហ្នឹងស្ថិតនៅក្នុងតំបន់អីដែរ? លោកស្រីនៅចាំលេខទេ?

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ខ្ញុំអត់ចាំទេលោកគ្រូ។ កាលហ្នឹងគេហៅតំបន់ តំបន់ស្វាយរៀង តែខ្ញុំអត់ចាំ។ ប្អូនខ្ញុំវាធ្វើទាហានហ្នឹង។

**ស៖** ខ្ញុំនឹងនិយាយអំពីប្អូនរបស់លោកស្រីនៅពេលក្រោយ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរលោកស្រីថាតើភូមិរបស់លោកស្រីហ្នឹងមានចម្ងាយប៉ុន្មានម៉ែត្រដែរពីព្រំដែនវៀតណាម?

[១១:២៤:៥៥]

**ឆ៖** ច្រើនគីឡូណាស់លោកគ្រូ មិនដឹងប៉ុន្មានគីឡូទេឆ្ងាយដែរ។

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់ក្រោយ គឺនិយាយអំពីរបបសម្តេច សីហនុ មុនពេល លន់ នល់ កាន់អំណាចនៅឆ្នាំ១៩៧០។ លោកស្រីរស់នៅស្វាយរៀង មិនឆ្ងាយប៉ុន្មានពីព្រំដែនវៀតណាម។ នៅក្នុងសម័យ សីហនុ តើមានការដោះដូរទំនិញគ្នារវាងខ្មែរនិងវៀតណាមនៅតាមព្រំដែនទេ? ឧទាហរណ៍ដូចជាជនជាតិវៀតណាមមានចូលមកក្នុងទឹកដីយើង ហើយយកទំនិញមកដោះដូរជាមួយនឹងខ្មែរទេ?

ផ៖ ខ្ញុំអត់ដឹងទេលោកគ្រូ ខ្ញុំអត់ដឹង ខ្ញុំមិនបា៉នឆ្លើយផង។

ស៖ អម្បាញ់មិញនេះ លោកនិយាយអំពីគ្រួសារមួយចំនួនដែលកើតនៅក្នុងភូមិរបស់លោកស្រី និងភូមិត្រពាំងម្លូន។ នៅក្នុងភូមិឃុំរបស់លោកស្រីនោះ គឺឃុំចន្ត្រីនោះ តើមានជនជាតិវៀតណាមរស់នៅច្រើនទេ?

ផ៖ អត់មានច្រើនទេលោកគ្រូ មានតែពីសង្គមនៅពីរបីគ្រួសារប៉ុណ្ណឹង ខ្ញុំឃើញ។

ស៖ លោកស្រីនៅតែក្នុងភូមិទេ ឬក៏លោកស្រីដើរទៅណាមកណាបានឆ្ងាយដែរ?

ផ៖ ខ្ញុំគេឲ្យទៅប្រព័ន្ធភ្លឺស្រែ ជីកស្រះ ដើរឆ្ងាយៗដែរ។ ខ្ញុំមិនសូវនៅនឹងភូមិផង។

ស៖ លោកស្រីនិយាយអំពីរបប សីហនុ ឬក៏របបខ្មែរក្រហម?

ផ៖ របបខ្មែរក្រហម ខ្ញុំអត់ដឹង--

ស៖ សូមលោកស្រីចាំឲ្យភ្លើងក្រហមឆេះសិន ចាំនិយាយ។

[១១:២៧:៣៥]

ផ៖ ខ្ញុំអត់ដឹង ខ្ញុំអត់បា៉នឆ្លើយទេ លោកគ្រូ។ បើខ្ញុំត្រង់ណាខ្ញុំដឹង ខ្ញុំឆ្លើយ ត្រង់ណាខ្ញុំអត់ដឹង ខ្ញុំអត់បា៉នទេ ព្រោះខ្ញុំអត់ដឹង។

ស៖ ខ្ញុំសួរសំណួរឡើងវិញ ប្រហែលជាលោកស្រីស្តាប់មិនច្បាស់។ ខ្ញុំសួរថានៅក្នុងរបប សីហនុ នោះ លោកស្រីមានដើរទៅភូមិឃុំផ្សេងទៀត ដើម្បីរកស៊ីទេ ឬក៏លោកស្រីនៅតែភូមិក្រហម-ក នេះនៅក្នុងឃុំចន្ត្រីនេះរហូតតែម្តង មិនចេញទៅណាទេ?

ផ៖ ខ្ញុំអត់ដែលដើរទៅណាទេលោកគ្រូ ខ្ញុំនៅតែនឹងភូមិក្រហម-ក ឃុំចន្ត្រីរហូត តាំងពីតូចមករហូតទាល់ចំណាស់ហ្នឹងទៅហើយ មិនដែលទៅណាផង។

ស៖ អ៊ីចឹងលោកស្រីនិយាយថា មានវៀតណាមតិចតួចហ្នឹង គឺលោកស្រីសំដៅតែទៅក្នុងភូមិក្រហម-ក តែប៉ុណ្ណោះ មែនទេ លោកស្រីមិននិយាយអំពីភូមិណាផ្សេងទៀតទេ?

ផ៖ ចាស ខ្ញុំនិយាយតែភូមិខ្ញុំ។ ភូមិនានា ខ្ញុំអត់ដឹងផង។

ស៖ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីគ្រួសារដែលនៅក្នុងភូមិរបស់លោកស្រី។ តើមានគ្រួសារណាដែលមានវៀតណាមសុទ្ធទេ? គឺខ្ញុំសំដៅលើគ្រួសារណាដែលមានសុទ្ធតែជាប្តី ប្រពន្ធ កូនអីសុទ្ធតែជាវៀតណាមតែម្តង?

ផ៖ អត់មានទេលោកគ្រូ ទទេទេ។

[១១:២៩:៣៦]

**ស៖** ដូច្នេះលោកស្រីចង់និយាយថា នៅសម័យ សីហនុ ហ្នឹងគឺអត់មានគ្រួសារណាមានជនជាតិវៀតណាមសុទ្ធទេ គឺមាន បើមានប្ដីអាចជាខ្មែរ ប្រពន្ធវៀតណាម ឬប្ដីវៀតណាម ប្រពន្ធខ្មែរ លោកស្រីចង់មានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** នៅសម័យ សីហនុ ដដែល តើគ្រួសារខ្មែរ និងគ្រួសារវៀតណាមនុ៎ងត្រូវគ្នាទេ? គឺមានន័យថា សហគមន៍ ឬក៏ភូមិរបស់លោកស្រីហ្នឹងទទួលយកបានទេនៅពេលដែលមានគ្រួសារណាដែលមានប្ដី ឬក៏មានប្រពន្ធជាជនជាតិវៀតណាមហ្នឹង គឺអ្នកភូមិត្រូវគ្នាទេ អត់មានបញ្ហាអីទេ?

**ឆ៖** មានខុសគ្នាទេលោកគ្រូ ដូចតែខ្មែរគ្នាឯងអ៊ីចឹង បីប្អូននាក់ មានទៅនៅឯណាច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលារសៀលនេះ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:០៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកស្រីសាក្សី ខ្ញុំព្យាយាមសុំការបំភ្លឺពីលោកស្រីពាក់ព័ន្ធទៅនឹងគ្រួសារមួយចំនួនដែលមានអ្នកខ្លះជាជនជាតិវៀតណាមនៅក្នុងភូមិរបស់លោកស្រី និងនៅក្បែរភូមិរបស់លោកស្រី។ អម្បាញ់មិញនេះ ខ្ញុំចាំថា លោកស្រីថា មានបីបួនគ្រួសារដែលកើតនៅក្នុងភូមិលោកស្រី ជាជនជាតិវៀតណាម ហើយរស់នៅគឺប្រហែល១គីឡូម៉ែត្រពីក្រហម-ក។ ហើយគ្រួសារទាំងនោះ គឺមកលក់ដូរនៅក្នុងភូមិរបស់លោកស្រី។ ខ្ញុំចាំអ៊ីចឹងត្រឹមត្រូវទេលោកស្រី?

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ចាស ត្រឹមត្រូវហើយលោកគ្រូ។

**ស៖** គ្រួសារទាំងនោះ មានប្តីជាខ្មែរទៅ ឬក៏គ្រួសារខ្លះមានប្រពន្ធជាខ្មែរ។ តើឪពុកម្តាយរបស់បុរស ឬក៏ស្ត្រីជាវៀតណាមនោះ រស់នៅជាមួយកូនៗទេ? ខ្ញុំសំដៅលើឪពុកម្តាយដែលជាជនជាតិវៀត-ណាម។

[១៣:៣៥:១៩]

**ឆ៖** នៅជាមួយលោកគ្រូ។

**ស៖** ដូច្នេះនៅក្នុងគ្រួសារចម្រុះជាតិសាសន៍ទាំងអស់ហ្នឹង គឺមានអ្នកខ្លះវៀតណាមសុទ្ធ គឺជីដូនជីតា បន្ទាប់មកមានកូនដែលរៀបការជាមួយនឹងខ្មែរ ឬក៏មានចៅដែលជាជនជាតិវៀតណាម។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីរបៀបបែងចែកអ្នកណាជាខ្មែរ អ្នកណាជាវៀតណាមនៅក្នុងសម័យសម្ដេច សីហនុ។ បើគ្រាន់តែមើលមុខ ឬក៏ស្ដាប់សំឡេង យើងអាចដឹងថា អ្នកណាជាខ្មែរ អ្នកណាជាវៀតណាមបានទេ?

**ឆ៖** អត់ដឹងទេ លោកគ្រូ ខ្ញុំ ព្រោះខ្មៅៗដូចតែខ្មែរ។

**ស៖** ក្រៅពីសម្បុរខ្មៅ តើនៅក្នុងគ្រួសារវៀតណាមទាំងអស់ហ្នឹង មានអ្នកណានិយាយវៀត-ណាមទេ ឬក៏និយាយខ្មែរ តែនិយាយប៉ែឡាំៗ? លោកស្រីមានសង្កេតឃើញចំណុចហ្នឹងទេ?

**ឆ៖** និយាយខ្មែរ និយាយច្បាស់ទែងលោកគ្រូ គ្មាននិយាយប៉ែឡាំអីទេ។

**ស៖** គ្រួសារទាំងអស់ហ្នឹងមានគោរពប្រពៃណីវៀតណាមទេ? ឧទាហរណ៍ដូចជា គេចូលឆ្នាំអីគេចូលនៅខែ២ មិនមែនខែ៤ ដូចខ្មែរយើងទេ គេមានប្រារព្ធពិធីទេ ពេលបុណ្យចូលឆ្នាំវៀតណាមខែ២នោះ?

**ឆ៖** អត់មានទេ លោកគ្រូ។ មានបុណ្យដូចខ្មែរឯងអ៊ីចឹង ព្រោះគ្នាតិច តែពីរបីគ្រួសារ។

[១៣:៣៩:០៦]

**ស៖** តាមពិតទៅ លោកស្រីមិនដឹងទេ ប្រហែលជាគេអាចប្រារព្ធនៅក្នុងផ្ទះក៏មិនដឹង លោកស្រីអត់មានសង្កេតឃើញថាគេធ្វើអីអ៊ីចឹងទេ?

**ឆ៖** មិនដែលដើរទៅផ្ទះគេផង បានអីដឹងលោកគ្រូ។

**ស៖** នៅក្នុងឃុំចន្ទ្រី មានកន្លែងប្រារព្ធពិធីសាសនាសម្រាប់ជនជាតិវៀតណាមដែលសាងសង់ឡើងដោយជនជាតិវៀតណាមទេ ឧទាហរណ៍ដូចជា វិហារវៀតណាមអ៊ីចឹង មានទេ?

**ឆ៖** អត់មានទេ លោកគ្រូ ទទេ មានតែវត្តខ្មែរ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំបានកត់ត្រាឃើញថា នៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួរដំបូងនោះគឺថានៅឆ្នាំចន្លោះឆ្នាំ៧៥ ដល់៧៨ វៀតណាមត្រូវបានបណ្ដេញចេញពីស្រុកខ្មែរ ហើយបញ្ជូនទៅវៀតណាមវិញ។ ហើយព្រះរាជអាជ្ញាជាតិហ្នឹងសួរថានៅឆ្នាំណា លោកស្រីៗឆ្លើយថាមិនចាំនៅឆ្នាំណាទេ។ ដូច្នេះខ្ញុំចង់ត្រឡប់មកចំណុចនេះវិញ។ លោកស្រីថាវៀតណាមត្រូវបានគេបណ្ដេញចេញពីខ្មែរ តើការបណ្ដេញចេញនេះ គឺក្រោយពីភ្នំពេញដួលរលំហើយភ្លាមៗ ឬក៏យូរមកហើយ លោកស្រីនៅចាំទេ?

**ឆ៖** មុននុ៎ង លោកគ្រូ មុនភ្នំពេញបែក ស្វាយរៀងបែក។ ថាទៅឯណាឯណីអស់ទៅ ខ្ញុំអត់ដឹងដែរ។

[១៣:៤១:២៣]

**ស៖** ពេលហ្នឹងជាពេលដែលកងទ័ពបដិវត្តន៍ចូលមកដល់ក្នុងតំបន់របស់លោកស្រីហើយឬនៅ? ឬដែលយើងហៅថាខ្មែរក្រហមហ្នឹង ពេលគេដេញវៀតណាមចេញហ្នឹង ខាងកងទ័ពខ្មែរក្រហមហ្នឹងបានចូលមកដល់ភូមិលោកស្រីហើយឬនៅ?

**ឆ៖** មិនទាន់ឃើញទេ លោកគ្រូ។

**ស៖** ម៉េចបានជាលោកស្រីដឹងថា ជនជាតិវៀតណាមត្រូវបានបណ្ដេញទៅស្រុកវិញ? គេនិយាយគ្នាអំពីរឿងនេះនៅក្នុងភូមិមែនទេ បានជាលោកស្រីដឹង?

**ឆ៖** ចាស។ គេនៅជិតៗនោះគេនិយាយ ហើយខ្ញុំឮ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់សួរលោកស្រីនៅចន្លោះឆ្នាំ៧៥ និង៧៩ និងនៅក្នុងភូមិរបស់លោកស្រី លោកស្រីធ្លាប់ចូលរួមក្នុងការប្រជុំធំៗទេ គឺមានន័យថាមាននៅថ្ងៃណាមួយនោះ គេមិនឱ្យធ្វើការទេ គឺគេឱ្យទៅប្រជុំ?

**ឆ៖** មានដែលបានទៅប្រជុំធំៗទេលោកគ្រូ។ បានតែប្រជុំគ្នាឯង ប្អូនដប់នាក់ៗ មួយក្រុមៗ។

**ស៖** ដូច្នេះមិនដែលមានកម្មាភិបាលមកពីថ្នាក់ឃុំ ឬថ្នាក់ស្រុកមកប្រជុំក្នុងភូមិលោកស្រីទេមែនទេ?

**ឆ៖** ចាស អត់មានទេលោកគ្រូ មានតែពួកនៅនឹងភូមិៗ គេប្រជុំ។

[១៣:៤៣:៥០]

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីគ្រួសារវៀតណាមបីបួនគ្រួសារ ដែលក្នុងនោះមានប្ដីជាខ្មែរ ឬក៏ប្រពន្ធជាវៀតណាម។ អម្បាញ់មិញលោកស្រីថា លោកស្រីមិនចាំឈ្មោះអ្នកទាំងអស់នោះទេ ទោះបីជាលោកស្រីស្គាល់ពួកគេច្បាស់ក៏ដោយ ហើយលោកស្រីថាលោកស្រីឃើញអ្នកទាំងអស់ហ្នឹងមកលក់ដូរនៅក្នុងភូមិរបស់លោកស្រីជាញឹកញាប់។ ហេតុអីបានលោកស្រីមិនចាំឈ្មោះទាល់តែសោះបែបនេះ? លោកស្រីទើបតែភ្លេចនៅសព្វថ្ងៃនេះទេ ឬក៏លោកស្រីនៅសម័យនៅគឺថាអត់ដែលស្គាល់អីអ្នកទាំងអស់នោះតែម្ដង?

**ឆ៖** ខ្ញុំអត់ស្គាល់មែនលោកគ្រូ អត់ស្គាល់ឈ្មោះគេផង គ្រាន់តែឃើញគេ។

**សះ** លោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ ក្នុងចំណោមបីបួនគ្រួសារនោះ មានប្ដីជាខ្មែរប៉ុន្មាននាក់ ហើយមានប្រពន្ធជាវៀតណាមនោះប៉ុន្មាននាក់ដែរ?

**ផះ** បីគ្រួសារ លោកគ្រូ។ ខ្ញុំឃើញ ប៉ុណ្ណឹង។

**សះ** ក្នុងចំណោមទាំងបីគ្រួសារហ្នឹង មានគ្រួសារណាដែលមានប្រពន្ធវៀតណាម ហើយប្ដីខ្មែរទេ? ហើយបើមាន សរុបទាំងអស់ប៉ុន្មាន?

**ផះ** មានប្រាំគ្រួសារ លោកគ្រូ។ ខ្ញុំឃើញ ហើយបើក្រៅពីនោះ ខ្ញុំអត់បានឃើញផង ខ្ញុំអត់ដឹងផង។

[១៣:៤៦:១៨]

**សះ** មុននេះខ្ញុំឮបី ឥឡូវលោកស្រីថាប្រាំ។ លោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់ទេ? លោកស្រីប្រហែលជាមិនយល់សំណួរខ្ញុំ ឬក៏យ៉ាងម៉េច? លោកស្រីអាចប្រាប់ខ្ញុំមើល៍ លោកស្រីយល់សំណួរខ្ញុំ ឬក៏អត់?

**ផះ** ខ្ញុំយល់ហើយ ដែលម៉ែឪវា វាបីគ្រួសារ ចុះបើមកកូនចៅវាទៀត បានប្ដីប្រពន្ធខ្មែរ។ វាប្រាំលោកគ្រូ ប្រាំគ្រួសារ។ ចុះវានៅយូរឆ្នាំហើយ វាមិនបានកូនចៅវាគរគោកគរដី។ ម៉ែខ្មែរ ឪយួនហ្នឹង។

**សះ** ខ្ញុំនៅតែមិនយល់អំពីប្រាំគ្រួសារនេះ។ ក្នុងគ្រួសារនីមួយៗមានសមាជិកប្រហែលជាប្រាំនាក់ ឬក៏យ៉ាងម៉េច ខ្ញុំអត់យល់លោកស្រី?

**ផះ** លោកគ្រូ ចេះតែសួរដេញខ្ញុំ។ ដែលម៉ែឪវា វាបីគ្រួសារ ហើយដល់ពេលមកកូនវា បែកមកជាកូនជាចៅវា ដល់មានប្ដីមានប្រពន្ធទៅ ទាំងម៉ែ ទាំងឪវាទៅបានប្រាំគ្រួសារ លោកគ្រូ។

**សះ** បើអ៊ីចឹងមានន័យថា ដំបូងមានបីគ្រួសារ ក្រោយមកកើតជាកូនជាចៅទៅ គឺបានជាប្រាំគ្រួសារ។ អំមិញនេះលោកស្រីបាននិយាយថា លោកស្រីបានឃើញមនុស្សជំទង់បួនប្រាំនាក់ ដែលមានអាយុប្រហែលជា១០ ទៅ១៥ឆ្នាំ ដែលជាកូនកាត់ខ្មែរ-វៀតណាម ដែលកើតចេញមកពីគ្រួសារនៅក្នុងភូមិរបស់លោកស្រីហ្នឹង ត្រូវបានគេនាំចេញទៅ។ ហើយគេប្រាប់អ្នកទាំងអស់នោះថា គេបញ្ជូនឲ្យទៅនៅក្នុងកងចល័ត។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបាននិយាយពាក្យថា “ចាប់ខ្លួន” ហើយកាលពីព្រឹកមិញនេះ ក៏លោកស្រីបានប្រើពាក្យថា “ចាប់ខ្លួន” ដែរ។ ម៉េចបានជាលោកស្រីគិតថាកូនកាត់វៀតណាមបួនប្រាំនាក់ហ្នឹង ត្រូវបានគេចាប់ខ្លួន បើគេគ្រាន់តែបញ្ជូនទៅកងចល័តនោះ?

**ផះ** ខ្ញុំឃើញគេមកចាប់ទៅ ថាយកទៅកងចល័ត។ ទាំងកូនបងប្អូនខ្ញុំ ទាំងខ្ញុំទាំងអី ទៅកង

ចល័តទាំងអស់តែគ្នាហ្នឹង លោកគ្រូ។

[១៣:៤៩:៣៦]

**ស៖** លោកស្រីដឹងថា កូនកាត់វៀតណាមទាំងបួនប្រាំនាក់ហ្នឹង ទៅកងចល័តទេ? ហើយប្រសិនបើដឹងនោះ លោកស្រីអាចជម្រាបបានទេ លោកស្រីមានព័ត៌មានអីខ្លះ?

**ឆ៖** ទៅកងចល័តមែន លោកគ្រូ។ ទៅលើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ ជីកស្រះអីហ្នឹង លោកគ្រូ។ ខែច្រូតអ៊ីចឹងទៅ ទៅច្រូត។ ខែស្ទូង ទៅស្ទូង ទាំងអស់តែគ្នា គេយកទៅនុំង។

**ស៖** នៅពេលដែលលោកស្រីនិយាយថា គេចាប់ខ្លួនហ្នឹង អ្នកទាំងអស់ហ្នឹងត្រូវបានសម្លាប់ចោល ឬក៏ស្លាប់ដោយសារមូលហេតុណាមួយ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមានការជំទាស់ពីរ។ ទី១ គឺថាជាសំណួរច្រំដែល សាក្សីបានឆ្លើយរួចមកហើយ ហើយថា ក្រុមគ្រួសារទាំងនេះត្រូវបានបញ្ជូនទៅនៅកងចល័ត ហើយព្រឹកមិញនេះ ក៏បាននិយាយថា ក្រុមគ្រួសារត្រូវបានបញ្ជូនទៅវៀតណាម។ ហើយខ្ញុំក៏សូមចូលជំទាស់ ការជំទាស់ទី២ គឺថាទី១ ចង់ដឹងថា ការសួរថា គេយកទៅសម្លាប់ ឬក៏យ៉ាងនោះ មិនត្រឹមត្រូវទេ គឺគាត់បញ្ជាក់ថា ត្រូវបានគេបញ្ជូនទៅវៀតណាម ហើយនៅរស់រានមានជីវិតនៅឡើយទេ។

[១៣:៥១:២៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

អ៊ីចឹងហើយបានជាខ្ញុំព្យាយាមសួរបញ្ជាក់នោះលោកប្រធាន។ អ្វីដែលខ្ញុំចង់ដឹងហ្នឹង គឺដោយ-សារតែគាត់ប្រើពាក្យថា "ចាប់ខ្លួន" ជាភាសាបារាំង ពាក្យហ្នឹងគឺមានន័យថា គេចាប់ចងហើយ នាំទៅកន្លែងណាមួយ ហើយគេដកហូតសិទ្ធិសេរីភាពទាំងស្រុង អាចក្រោយមកត្រូវបានដោះលែង ឬក៏អាចក្រោយមកគេធ្វើបាប ឬក៏សម្លាប់ចោល។ នេះជាខ្លឹមសារនៃពាក្យថា "ចាប់ខ្លួន" ជាភាសាបារាំង។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** ដូច្នេះលោកស្រីបានប្រើពាក្យថា "ចាប់ខ្លួន" លោកស្រីគ្រាន់តែចង់មានន័យថា អ្នកទាំងអស់ហ្នឹងត្រូវបានគេបញ្ជូនទៅកន្លែងណាមួយផ្សេង ឬក៏លោកស្រីសំដៅលើការចាប់ចងផ្ទាល់តែម្តង លោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់បានទេ?

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញារងអន្តរជាតិអន្តរជាតិ ដូចជាលោកដកស្រង់មិនត្រឹមត្រូវទេ។ លោកមានស្ទីដែលជាបង្ហាញនូវប្រតិចារឹកកន្លែងណាដែលសួរដូច្នេះ ព្រោះមួយព្រឹកហើយ ដូចអត់មានចូលក្នុងរឿងដែលថាចាប់ចងហ្នឹងទេ។ ហើយការជំទាស់របស់មេធាវី វ៉ិចទ័រ កូប៉េ គឺត្រឹមត្រូវហើយ ច្រំដែលហើយនិងការសួរហ្នឹង វាអត់មានមូលដ្ឋានជាក់ស្តែងដែលសាក្សីផ្តល់សក្ខីកម្មនៅព្រឹកនេះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានមតិបន្ថែមបន្តិច គឺថាផលវិបាកនៃជម្រើសទី២នេះ គឺថាមិនត្រឹមត្រូវ។ សូមសួរឲ្យ ធ្វើម៉េចសួរឲ្យបានខ្លីៗទៅបានហើយ។

[១៣:៥៣:១៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនឹងដកស្រង់នូវកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីគឺ E3/7796 ជាភាសាបារាំងគឺ 00282908, ជាភាសាខ្មែរគឺ 00250719 និងជាភាសាអង់គ្លេស 00268645 គឺចម្លើយទី១ តែម្តងរបស់លោកស្រីសាក្សីរូបនេះ។ នៅក្នុងកំណត់ហេតុនោះ គាត់បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “នៅឆ្នាំ១៩៧៧ កូនកាត់វៀតណាមប្អូនប្រាំនាក់ ដែលឪខ្មែរ ម៉ែយួន ឬក៏ខ្លះឪយួន ម៉ែខ្មែរ (ខ្ញុំមិនចាំឈ្មោះ) ត្រូវចាប់យកទៅបាត់រហូត។ អ្នកទាំងនេះបានរស់នៅក្នុងភូមិក្រហម-កនេះជាយូរមកហើយ។” សូមបញ្ចប់ការដកស្រង់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ កំណត់ហេតុស្តាប់ចម្លើយនៅក្នុងដៃរបស់ខ្ញុំ គឺថាត្រូវបានចាប់ខ្លួនហើយបញ្ជូនចេញទៅបាត់ទៅ។ ចប់តែប៉ុណ្ណោះឯង។ ដូច្នេះខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ បាត់ខ្លួន ជាពាក្យដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយគឺថា “ត្រូវបានចាប់ខ្លួន បញ្ជូនទៅ ហើយបាត់រហូត”។

[១៣:៥៥:០៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

អ៊ីចឹងខ្ញុំនឹងសួរបញ្ជាក់ពីលោកស្រីសាក្សី ពីព្រោះថាក្នុងភាសាបារាំងហ្នឹង គេដាក់បញ្ជាក់ហើយថា ចាប់យកទៅបាត់រហូត។ ហេតុនេះហើយបានជា លោកប្រធាន ខ្ញុំយកពាក្យ "ចាប់" នេះយកមកសួរ។ ថាពាក្យថា "ចាប់" នេះមានន័យខុសពី "បញ្ជូនទៅណា"។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ដូច្នេះលោកស្រី ពេលដែលលោកស្រីនិយាយថា "កូនកាត់វៀតណាមបួនប្រាំនាក់ត្រូវបានចាប់យកទៅ" តើលោកស្រីដឹងថាមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងបួនប្រាំនាក់ហ្នឹងទេ?

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ខ្ញុំអត់ដឹងទេ លោកគ្រូ។ ខ្ញុំអត់ដឹងផង។ បើដឹងខ្ញុំថាដឹង ដល់អត់ដឹងខ្ញុំថាអត់ដឹង។

**ស៖** ចុះក្រោយឆ្នាំ៧៩ ក្រោយរបបខ្មែរក្រហមមកនោះ លោកស្រីឃើញកូនកាត់វៀតណាមទាំងបួនប្រាំនាក់ហ្នឹង នៅក្នុងភូមិលោកស្រីទៀតទេ ឬក៏លោកស្រីមិនធ្លាប់ឃើញអ្នកទាំងអស់ហ្នឹងទៀតទេ?

**ឆ៖** អត់បានឃើញទេ លោកគ្រូ។

**ស៖** ចុះឪពុកម្តាយរបស់កូនកាត់ទាំងបួនប្រាំនាក់ហ្នឹង លោកស្រីបានឃើញទៀតទេ?

**ឆ៖** នុ៎ងក៏មិនឃើញដែរ មិនដឹងគេទៅឯណាទៅឯណីអស់ ខ្ញុំអត់ឃើញផង។

[១៣:៥៦:៥១]

**ស៖** អ៊ីចឹងមានន័យថា លោកស្រីមិនឃើញក្រុមគ្រួសារទាំងអស់នោះ ទាំងមូលតែម្តង ឬក៏លោកស្រីគ្រាន់តែលែងឃើញអ្នកដែលជាជនជាតិវៀតណាមទេ?

**ឆ៖** ខ្ញុំអត់បានឃើញអ្នកដែលយកទៅកងចល័ត ខ្ញុំអត់បានឃើញទេ លោកគ្រូ។ អត់ឃើញមកវិញ ទាំងឪទាំងម៉ែគេ។ គេទៅតាមម៉ែកូនគេទៅ បាត់អស់ទៅ។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្រោយឆ្នាំ៧៩ តើអ្នកភូមិមានដឹងអំពីរឿងហេតុដែលបានកើតឡើងចំពោះកូនកាត់វៀតណាមទាំងបួនប្រាំនាក់ហ្នឹងទេ? គេមាននិយាយគ្នាអំពីរឿងហ្នឹងទេ?

**ឆ៖** គេគ្មានឮនិយាយទេ លោកគ្រូ ទទេ។

**ស៖** ខ្ញុំបញ្ចប់ប្រធានបទនេះ ឥឡូវខ្ញុំចូលទៅប្រធានថ្មី គឺជោគវាសនារបស់ប្អូនប្រុសរបស់

លោកស្រី ឈ្មោះ មាស សាឃឿន។ ប្រហែលជាខ្ញុំអាចអានឈ្មោះនេះមិនត្រូវ សូមអភ័យទោសផង គឺ មាស សាឃឿន។ មាស សាឃឿន នេះពិតជាប្អូនប្រុសរបស់លោកស្រីមែនទេ?

**ធ៖** ប្អូនខ្ញុំពិតប្រាកដមែន លោកគ្រូ ប្អូនបន្ទាប់របស់ខ្ញុំហ្នឹង។

**ស៖** ប្រសិនបើខ្ញុំមិនច្រឡំទេ អ្នកដែលលោកស្រីបានជួបនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានអានប្រវត្តិរូបរបស់ប្អូនលោកស្រី ដែលបានធ្វើនៅស្លែង ឬក៏មន្ទីរស-២១។ លោកស្រីចាំទេ?

**ធ៖** ខ្ញុំអត់ដឹងផង អត់ចាប់។

[១៣:៥៩:២០]

**ស៖** ក៏ប៉ុន្តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីគឺ E3/7796 ជាភាសាបារាំងគឺ 00282909, ជាភាសាខ្មែរគឺ -- ខ្ញុំមានលេខ ERN ច្រើនពេកមិនដឹងមួយណា ប្រហែលជា 00250720 ហើយជាភាសាអង់គ្លេសគឺ 00268646។ លោកស្រីបានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដូចតទៅ ខ្ញុំសូមដកស្រង់៖ “នៅឆ្នាំ២០០៥ បុគ្គលិកអង្គការមួយបានមករកប្អូនខ្ញុំ ហើយគេយកប្រវត្តិរូបជាអ្នកទោសនៅ ស-២១ នៅទួលស្លែងមកឲ្យខ្ញុំ។” គឺមានន័យថា ពេលហ្នឹងមានបុគ្គលិកអង្គការហ្នឹងបានបង្ហាញប្រវត្តិរូបរបស់ប្អូនលោកស្រី ឲ្យលោកស្រីមើលមែនទេ កាលពីឆ្នាំ២០០៥នោះ? លោកស្រីមាននឹកឃើញទេ?

**ធ៖** គាត់យកទៅមែន លោកគ្រូ។ គាត់ទៅសួររកឪពុកម្តាយខ្ញុំ ហើយដល់គាត់ស្លាប់អស់ទៅ នៅតែខ្ញុំ គាត់យកទៅឲ្យខ្ញុំលោកគ្រូ។ ខ្ញុំមិនដែលដឹងប្អូនខ្ញុំស្លាប់ផង។

**ស៖** សូមអរគុណ។ ក្នុងប្រវត្តិរូបដែលមានលេខ E3/2537 បញ្ជាក់ថាប្អូនរបស់លោកស្រីហ្នឹងត្រូវបានគេចាប់នៅអាយុ២៣ឆ្នាំ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើប្អូនរបស់លោកស្រីហ្នឹងចូលធ្វើកងទ័ពនៅអាយុប៉ុន្មានដែរ?

**ធ៖** ប្អូនខ្ញុំកាលចូលហ្នឹង អាយុទើបតែ១៧ លោកគ្រូ។

**ស៖** ប្រវត្តិរូបនេះបញ្ជាក់ថា គាត់ចូលធ្វើកងទ័ពនៅឆ្នាំ៧២។ តើលោកស្រីចាំទេថា ប្អូនរបស់លោកស្រីហ្នឹងបានចូលធ្វើកងទ័ពហ្នឹង គឺ៣ឆ្នាំ មុនពេលខ្មែរក្រហមវាយចូលយកទីក្រុងភ្នំពេញបាន?

**ធ៖** ខ្ញុំមិនសូវចាំដែរហ្នឹងលោកគ្រូ ព្រោះខ្ញុំអត់ដែលគិតផង។

[១៤:០២:២៧]

**ស៖** លោកស្រីដឹងថាប្អូនរបស់លោកស្រីហ្នឹងស្ថិតនៅក្នុងអង្គភាពយោធាណាទេ? ហើយដឹងថា

គាត់ធ្វើការនៅកន្លែងណាទេ?

**ឆ៖** ដឹងអង្គភាពណាទេលោកគ្រូ ប៉ុន្តែវាធ្វើការ វានៅឯកើតផ្ទះខ្ញុំនោះ នៅតាមព្រំដែន។

**ស៖** ក្នុងប្រវត្តិរូបរបស់ប្អូនលោកស្រីគឺនៅ ស-២១ បញ្ជាក់ថាគាត់ជាប្រធានក្រុមឃោធាស្រុករមាសហែក ពី៧២ ដល់៧៥។ បន្ទាប់មកទៀតប្រធានក្រុមកងតូចនៅក្នុងតំបន់២៣។ លោកស្រីដឹងថាប្អូនរបស់លោកស្រីមានស័ក្តិប៉ុន្មានទេ ឬក៏មានឋានន្តរស័ក្តិអីទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មានការកត់សម្គាល់បី ទី១ គឺឯកសារ E3/2--។ ទី២ សូមស្នើឱ្យបញ្ជាក់ថាតើឯកសារនេះជាឯកសារមកពី ស-២១ ឬក៏យ៉ាងណា? និងទី៣ -- បាទ គឺទី១ ឯកសារ E3/2537 និងទី១ បញ្ជាក់ឯកសារនេះ មកពី ស-២១ ឬក៏យ៉ាងណា?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ការកត់សម្គាល់ចុងក្រោយហ្នឹង គឺស្រួលឆ្លើយទេ គឺមានការបែងចែកដាច់គ្នា រវាងខ្លឹមសារនៃការ នៃចម្លើយសារភាពដែលទទួលបានមកពី ស-២១ ឬក៏ការប្រើប្រាស់ត្រឹមតែប្រវត្តិរូបដែលមានតែមួយទំព័រនោះ ដែលគ្រាន់តែរៀបរាប់អំពីមុខងារនៅក្នុងឆ្នាំផ្សេងៗ ឬក៏បង្ហាញថាតើបុគ្គលណាម្នាក់នោះធ្វើការអី។ ដូច្នេះទំព័រប្រវត្តិរូបនេះ មិនមែនជាខ្លឹមសារនៃចម្លើយសារភាពទេ។ ដូច្នេះខ្ញុំគិតថា ឯកសារហ្នឹងមិនមែនជាឯកសារដែលត្រូវបានហាមឃាត់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ ចំពោះប្រភពដើមនៃឯកសារ គឺឯកសារនោះមានដាក់ចំណងជើងថាប្រវត្តិរូបអ្នកទោស ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមិនអាចលម្អិតអីបានលើសពីហ្នឹងទេ ព្រោះថាឯកសារហ្នឹងវាស្ថិតនៅក្នុងចំណោមប្រវត្តិរូបជាច្រើនដែលរកបាននៅស-២១។ លោកប្រធាន តើខ្ញុំអាចបន្តទៀតបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀត!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ឈប់សិនៗ!

[១៤:០៦:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១២:០០]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៅទៀត។ ហើយពេលវេលាយើងបានប្រើប្រាស់អស់កាលពីព្រឹកមិញហ្នឹងគឺ ៤០នាទីហើយ។ អ៊ីចឹងមិនអាចប្រើប្រាស់ពេលវេលារសៀលនេះទេ ក្នុងការតាំងសំណួរគឺឲ្យយ៉ាងច្រើន គឺប្រើពេលដែលអង្គជំនុំជម្រះបែកចែក ពីរវគ្គសវនាការប៉ុណ្ណោះ។ ដោយអង្គជំនុំជម្រះត្រូវការពេលវេលាមួយចំនួនដើម្បីសួរបញ្ជាក់ពាក់ព័ន្ធនឹងបញ្ហាប្រឈមនឹងត្រូវការកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់មកស្តាប់សក្ខីកម្មនៅសប្តាហ៍ក្រោយ ដែលកំពុងតែប្រឈមនាពេលនេះ។ អង្គជំនុំជម្រះត្រូវការស្តាប់ភាគី យោបល់ភាគីនៅពេលបន្តិចទៀតនេះ។ ឲ្យច្បាស់លាស់ ក្រែងលោចទ្បាំថាមួយល្ងាចនេះគឺប៉ាវដាច់ទៅ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធានព្រឹកនេះយើងបានចាប់ផ្តើម លោកបានប្រាប់ខ្ញុំថា យើងទទួលបានពីរវគ្គ ហើយខ្ញុំបានគិតពីម្សិលមិញថា សាក្សីនេះតាមយើងអាចនឹងប្រើថ្ងៃនេះ មិនមែនសប្តាហ៍ក្រោយ។ អ៊ីចឹងការត្រៀមរៀបចំរបស់យើងគឺមិនទៅតាមការគិតរបស់យើងខ្ញុំ--

[១៤:១៣:២៦]

**ប្រធានអង្គជំនុំ៖**

យើងមិនត្រូវ -- យើងប្រាប់ថាមួយវគ្គ ពីរវគ្គនៃថ្ងៃសវនាការ គឺមួយរសៀលនេះ ព្រឹកមិញយើងឲ្យពេលវេលាអស់៤០នាទីហើយ។ អង្គជំនុំជម្រះត្រូវការពេលវេលាឥឡូវនេះបន្តិចទៀតនេះ ដើម្បីស្តាប់ភាគីអំពីបញ្ហាទាំងឡាយដែលប្រឈមនឹងកង្វះដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលអង្គជំនុំជម្រះមានគម្រោងនឹងកោះហៅមកធ្វើសក្ខីកម្ម ស្តាប់សក្ខីកម្មនៅក្នុងសប្តាហ៍ក្រោយនេះ។ អ៊ីចឹងគឺពេលវេលាហ្នឹងគឺទុកពេលវេលា៤០នាទីយ៉ាងតិច សម្រាប់អង្គជំនុំជម្រះធ្វើកិច្ចនីតិវិធីនេះស្តាប់ភាគីដើម្បីអង្គជំនុំជម្រះចាត់ការទាន់ពេលវេលានៅចុងសប្តាហ៍នេះជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ខ្ញុំនឹងបន្ត។ តាមពិតខ្ញុំយល់ដែលថាអង្គជំនុំជម្រះនឹងត្រូវការពេល៤០នាទី។ ហើយខ្ញុំមិនដឹងថាដកពេលប៉ុន្មានដែលត្រូវចែកមកឲ្យខាងយើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹងអង្គជំនុំជម្រះត្រូវការដក៤០នាទីនៅរសៀលនេះ ដើម្បីធ្វើកិច្ចនីតិវិធីផ្សេងទៀត។ មិនមែនដកពីលោកទេ គឺពេលវេលាដែលអង្គជំនុំជម្រះបានប្រើប្រាស់កាលពីព្រឹកមិញ លោកបានប្រើប្រាស់ពីព្រឹកមិញរួចហើយ។

[១៤:១៥:០១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ អរគុណលោកប្រធាន។ ការបកប្រែដែលខ្ញុំបានឮនោះគឺច្បាស់ហើយ អ្វីដែលលោកប្រធានមានប្រសាសន៍។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អ៊ីចឹងសាក្សី តើប្អូនរបស់សាក្សី លោកស្រីដឹងឋានៈរបស់គាត់ទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ហើយខ្ញុំបានជំទាស់ ហើយថាសហព្រះរាជអាជ្ញាបានប្រើឯកសារយកមកពី ស-២១។ អ៊ីចឹងគឺថា យើងនឹងត្រូវមានការសម្រេចថាតើឲ្យគាត់ប្រើជាមូលដ្ឋាននៃការសួរបន្ត ឬក៏អត់ដែរ?

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ ងើបឈរម្តងទៀតមើល!

លោក វ៉ិចទ័រ កូប៉េ អញ្ជើញងើបឈរ!

លោកជំទាស់ ឬក៏លោកកត់សម្គាល់? យើងស្តាប់ខ្មែរ គឺគ្រាន់តែលោកកត់សម្គាល់ទេ លោកមិនបានប្រើជំទាស់ទេ។ នៅក្នុងនីតិវិធីដែលយើងធ្វើកន្លងមកនេះ គ្រាន់តែជាការកត់សម្គាល់ យើងមិនត្រូវសម្រេចអីទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។ លោកប្រធានមានប្រសាសន៍ត្រូវហើយ មិនមានការជំទាស់អ្វីទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តទៀត!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ ខ្ញុំនឹងព្យាយាមសួរម្តងទៀត។

[១៤:១៦:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៧:០១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវការជំទាស់របស់មេធាវីការពារក្តីរបស់ នួន ជា គឺមេធាវី វ៉ិចទ័រ កូប៉េ ដោយសារបញ្ហានេះ គឺអង្គជំនុំជម្រះធ្លាប់បានធ្វើរួចមកហើយ យកតែចំណុចបញ្ហាសំខាន់ៗ ពាក់ព័ន្ធនឹងប្រវត្តិរូប ឈ្មោះ ទីកន្លែងកំណើតរបស់អ្នកដែលមានប្រវត្តិរូបនៅស-២១ ប៉ុណ្ណោះ។ មិនអនុញ្ញាតឲ្យសួរលើខ្លឹមសារនៃឯកសារដែលបានមកពីធ្វើការទារុណកម្មទេ។ ហើយដែលសំណួរកន្លងមកនេះ គឺជាសំណួរដែលពាក់ព័ន្ធតែនឹងប្រវត្តិរូបដូចអង្គជំនុំជម្រះធ្លាប់បានអនុវត្តនៅក្នុងសំណុំរឿង០០១ រួចមកហើយ។

សូមបញ្ជាក់ថា អ្នកបកប្រែភាសាប្រយ័ត្នប្រយែងឲ្យមែនទែនណា ការប្រើពាក្យ។ "ជំទាស់" ហើយនិង "កត់សម្គាល់" ហ្នឹងគឺខ្មែរកត់សម្គាល់ច្រើនដងទៅហើយ ដល់ពេលមកអង់គ្លេសថាជំទាស់នេះ ប្រធានសវនាការស្តាប់ភាសាខ្មែរ ដល់ពេលវាខុសគ្នាអ៊ីចឹង ហើយធ្វើម៉េចទៅ។ "កត់សម្គាល់" អង្គ-ជំនុំជម្រះមិនត្រូវសម្រេចអីទេ។ អ៊ីចឹងសូមប្រយ័ត្នប្រយែងក្នុងការប្រើពាក្យឲ្យមែនទែនក្នុងការបកប្រែភាសា ជាពិសេសភាសា "ជំទាស់" របស់ភាគីពាក់ព័ន្ធហ្នឹងតែម្តង។ សូមអញ្ជើញត!

[១៤:១៨:២៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តាមដែលខ្ញុំយល់គឺថា លោកមេធាវី លោកជំទាស់ការប្រើប្រវត្តិរូប មិនមែនចម្លើយសារភាពទេ។ តើអ៊ីចឹងទេ លោកមេធាវីការពារក្តី? អ្វីដែលមានការបកប្រែហ្នឹងអ៊ីចឹងដើម្បីឲ្យយើងយល់ដូចគ្នា។ ការសួរនៅក្នុងបរិបទនេះ តើសហព្រះរាជអាជ្ញាដែលចង់ប្រើឯកសារមានព័ត៌មានអ្វីទាក់ទងទៅនឹងថា តើបានឯកសារហ្នឹង ឯកសារហ្នឹងគេធ្វើនៅកន្លែងណា? ជួនកាលគឺថាវិធីគេធ្វើ គេយកឯកសារនោះមក

ពីក្រៅមកចូល ស-២១ ជួនកាលគេធ្វើឯកសារហ្នឹងនៅនឹង ស-២១។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

អ្វីដែលខ្ញុំដឹងគឺថា ប្រវត្តិរូបនៃអ្នកឃុំខ្លួននេះគឺមានកាលបរិច្ឆេទ ហើយគេរកឃើញនៅក្នុង ស-២១ ហើយផ្អែកលើពេលវេលាដែលខ្ញុំបានទទួល ហើយមានការរំខានខ្លះដល់សាក្សី ដល់ពេលនេះ ខ្ញុំមិនអាចសួរលម្អិត ហើយខ្ញុំក៏ត្រូវទៅសួរទៅសាក្សី។ ហើយដែលនិយាយថា យើងគឺជាប្រវត្តិរូប ហើយមិនមែនជាប្រវត្តិរូបទូទៅទេ គឺជារបស់អ្នកឃុំខ្លួនដែលគេឃុំខ្លួននៅកន្លែងផ្សេងទៀតនោះផងដែរ។ ហើយស្ថិតនៅក្នុងបណ្ណសារនៅក្នុងនៅប្រទេសដែលមិនស្ថិតនៅក្នុងស-២១ នោះទេ គឺថានៅក្រាំងតាចាន់ជាដើម គឺមិនមានជាប្រវត្តិរូបអ្នកទោសនៅនោះទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** អ៊ីចឹងសាក្សី ខ្ញុំសួរសំណួរសាមញ្ញ តើតំណែងអ្វីដែលប្អូនស្រីរបស់លោកស្រីនៅក្នុងកងទ័ព? តើជាទាហានមានឋានៈធម្មតា ឬក៏មានតំណែងអ្វីដែរ?

**លោកស្រី អ៊ុំ សំអ៊ាន៖**

**ឆ៖** ចាស ខ្ញុំអត់ដឹងទេលោកគ្រូ ព្រោះថាវាទៅធ្វើទាហាន ហើយវាមិនដែលមកផង ខ្ញុំម៉េចនឹងដឹងវាធ្វើធំ ធ្វើតូចអី ខ្ញុំអត់ដឹងផង ហើយវាបាត់ទៅ។

**ស៖** តើលោកស្រីដឹងថា គេចាប់ខ្លួនគាត់ទេ? ក្នុងករណីដែលដឹងថាគេចាប់ខ្លួនហ្នឹង តើគេចាប់ខ្លួនគាត់នោះនៅពេលណា?

**ឆ៖** ខ្ញុំអត់ដឹងទេលោកគ្រូ។ ទើបតែឃើញប្រវត្តិរូបទៅពីហ្នឹង ទៅពីភ្នំពេញហ្នឹងលោកគ្រូ ខ្ញុំមិនដឹងផង។

**ស៖** តើលោកស្រីធ្លាប់ឮអ្នកណាម្នាក់និយាយ ដែលថាស្រុករមាសហែកថាមានទាហានស្ថិតនៅតាមព្រំដែនខ្មែរ-វៀតណាមបានក្បត់អង្គការដែរឬទេ? តើលោកធ្លាប់បានឮពាក្យបែបនេះទេនៅក្នុងពេលដែលលោកស្រីនៅទីនោះ?

**ឆ៖** អត់ដែលដឹង ដែលឮទេ លោកគ្រូ មិនដែលឮគេនិយាយផង។

[១៤:២២:១៧]

**ស៖** លោកស្រីទំនងជាបញ្ជាក់ថា លោកស្រីបានឮពីការចាប់ខ្លួនប្អូនស្រី លោកស្រីបាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/7796 បារាំង 282909, អង់គ្លេសនៅទំព័រ៣, នៅខ្មែរទំព័រ៣ផង

ដែរ។ ចម្លើយទី១ ដែលលោកស្រីបានឆ្លើយ លោកស្រីបាននិយាយដូចខាងក្រោមនេះ នៅប្រហែលពាក់កណ្ដាលឆ្នាំ១៩៧៨ ហើយបន្ទាប់មកលោកស្រីនិយាយថា សូមដកស្រង់សម្ដីលោកស្រី៖ “នៅពេលនោះគឺប្អូនស្រីរបស់ខ្ញុំ មាស -- ប្អូនប្រុសរបស់ខ្ញុំ មាស សាឃឿន ដែលជាទាហាននៅក្នុងស្រុករមាសហែក ត្រូវបានគេចាប់ខ្លួន ហើយក៏បានបាត់ខ្លួន។ ហើយគេបានប្រាប់ថាគេបញ្ជូនទៅឲ្យកសាងផ្លូវយន្តហោះនៅកំពង់ឆ្នាំង។ ហើយបន្ទាប់មកនៅក្នុងចម្លើយទី២ លោកស្រីបានឆ្លើយថា៖ ការៗបាត់ខ្លួនប្អូនប្រុសរបស់ខ្ញុំ មាស សាឃឿន កើតឡើងនោះគឺនៅពេលដែលទាហានខាងបូព៌ា ត្រូវបានចាប់ខ្លួនទាំងឡានៗដោយពួកនិរតី ដោយមិនដឹងមូលហេតុ នៅប្រហែលពាក់កណ្ដាលឆ្នាំ១៩៧៨។” បញ្ចប់សេចក្ដីដកស្រង់។ ឥឡូវនេះ តើលោកស្រីដឹងទេ នៅឆ្នាំ១៩៧៨ ថាគេបានយកគាត់ទៅ ហើយប្រហែលជាគេយកគាត់ទៅកសាងព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង?

**ឆ៖** ចាស កូនទាហាននៅនុ៎ងដែរ ទាហានៗគ្នាវាប្រាប់ខ្ញុំថា គេយកទៅកសាងនៅតារាងកប៉ាល់ហោះកំពង់ឆ្នាំងមែន លោកគ្រូ។

**ស៖** សមមិត្តរបស់ពួកគាត់ ថាតើអ្នកនោះប្រាប់ថាគាត់ឃើញគាត់នៅកំពង់ឆ្នាំង ឬក៏គាត់គ្រាន់តែប្រាប់លោកស្រីថា គេអាចបញ្ជូនប្អូនលោកស្រីទៅកំពង់ឆ្នាំង? តើប្អូនប្រុសរបស់លោកស្រី ពិតជាបានទៅដល់ការដ្ឋានកំពង់ឆ្នាំងនោះដែរឬទេ ឬក៏គាត់មិនបានទៅដល់? ថាតើពួកម៉ាកគាត់នោះ ប្រាប់ដូចម្ដេចខ្លះដល់លោកស្រីពីរឿងនេះ?

**ឆ៖** វាប្រាប់ខ្ញុំថា ឃើញគេទៅ ហៅដាក់ឡាន ថាទៅធ្វើតារាងកប៉ាល់ហោះនៅកំពង់ឆ្នាំង។ វាមិនដឹងថាទៅកំពង់ឆ្នាំងៗ វាអត់ដឹងដែរ លោកគ្រូ។ វាមកផ្ទះវិញ អានុ៎ង។

[១៤:២៥:៤២]

**ស៖** តើលោកស្រីបានដឹងថា ប្អូនប្រុសរបស់លោកស្រីទៅតែម្នាក់ឯង ដែលជិះឡាន គេដឹកទៅតែម្នាក់ឯង ឬក៏គាត់ទៅជាមួយទាហានផ្សេងៗជាច្រើនទៀតមកពីភូមិភាគបូព៌ា នៅកាលនោះ?

**ឆ៖** វាប្រាប់ថា ទៅច្រើន លោកគ្រូ។ មិនមែនទៅតែម្នាក់ឯងទេ ទៅមួយឡានឯណោះ។ គេយកទៅធ្វើតារាងកប៉ាល់ហោះនោះ គេមិនយកទៅធ្វើអីបន្តិចបន្តួច លោកគ្រូ។

**ស៖** តើលោកស្រីដឹង ប្រហែលជាកន្លែងណាដែលគេបញ្ជូនអ្នកទាំងអស់នោះទៅ ឬក៏មុននឹងគេបញ្ជូន គេចេញមកពីកន្លែងណា? ហើយទិសដៅដែលទៅ ទៅកន្លែងណា បើប្រៀបធៀបទៅនឹងតំបន់ដែលលោកស្រីរស់នៅកាលនោះ?

**ផ៖** គ្រាន់តែទាហានៗគ្នាវា វារត់រួចមកវិញ វាប្រាប់ខ្ញុំ មិនដឹងចេញទៅពីណាវិញ លោកគ្រូ។ វាមក វាប្រាប់ខ្ញុំ វាអត់ស្គាល់ថា ប្អូនខ្ញុំផងហ្នឹង។ ដល់សួរខ្ញុំ បានថាប្អូនខ្ញុំ បានវាប្រាប់ខ្ញុំ ហើយបាត់រហូតទៅ។

**ស៖** បាទ សំណួររបស់ខ្ញុំគឺថា តើមកពីឃុំ មកពីស្រុកណានៃស្វាយរៀង ដែលៗប្អូនប្រុសរបស់លោកស្រីឡើងជិះឡាននោះ? បើសិនបើលោកស្រីដឹង ប្រាប់ថាដឹង បើមិនដឹង ប្រាប់ថាមិនដឹង។

**ផ៖** ខ្ញុំអត់ដឹងទេ លោកគ្រូ។ ត្រង់ណាដឹង ខ្ញុំប្រាប់លោកគ្រូ។ ត្រង់ណាមិនដឹង ខ្ញុំមិនដឹងផង ខ្ញុំអត់បានឃើញ។

[១៤:២៧:៥៥]

**ស៖** បាទ ខ្ញុំនឹងបន្តទៅសំណួរមួយចំនួនទៀត។ នៅឆ្នាំ១៩៧៥ ដល់១៩៧៩ តើលោកស្រីស្គាល់ប្រធាន ឬក៏គណៈស្រុករមាសហែកដែរឬទេ? មានអ្នកណាខ្លះ ឬក៏ឈ្មោះអ្វី?

**ផ៖** ខ្ញុំថីមិនឃើញលោកគ្រូ តែអត់ស្គាល់ឈ្មោះគេ។ គេធ្វើប្រធាន ឯងហើយមិនស្គាល់ម៉េចគេប្រើវាល់ថ្ងៃ។

**ស៖** តើលោកស្រីបានផ្តល់ឈ្មោះ នៅពេលដែលផ្តល់បទសម្ភាសន៍ទៅ ឌី.ស៊ី.ខេម ឆ្នាំ២០០៥ ទំព័រខ្មែរ ប៉ុន្តែភាសាបារាំងនៅទំព័រ១២។ លោកប្រធាន នៅក្នុងអង់គ្លេសទំព័រលេខ៨។ ហើយលោកស្រីនិយាយថា លេខាស្រុកនោះឈ្មោះ តាសុផល។ តើលោកស្រីនឹកឃើញឈ្មោះនេះដែរឬទេ ឬក៏លោកស្រីមិនច្បាស់ពីឈ្មោះនេះទេ?

**ផ៖** ខ្ញុំស្គាល់ គាត់នៅនឹងឃុំចន្ទ្រី ខ្ញុំស្គាល់តាហ្នឹង។

**ស៖** អ៊ីចឹងលោកស្រីមិនច្បាស់ថា គាត់ជាលេខាឃុំ ឬក៏លេខាស្រុកទេ។ តើអ៊ីចឹងឬទេ?

**ផ៖** ចាស។ ខ្ញុំមិនសូវចាប់អារម្មណ៍ មិនសូវដឹង យើងប្រជាជន លោកគ្រូ ធ្វើម៉េចនឹងដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន មានសេចក្តីសង្កេតខ្លីតូចមួយ គឺមិនមែនសាក្សីរូបនេះ ដែលនិយាយថា តាសុផលជាគណៈស្រុកហ្នឹង គឺអ្នកជិតខាងរបស់គាត់ទេ ដែលបានរំខាននៅក្នុងបទសម្ភាសន៍នេះ។ សាក្សី គាត់ថាគាត់និយាយពី ស្គាល់ពី តាសុផល ប៉ុន្តែនៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនសម្តីរបស់សាក្សីទេ។

[១៤:៣០:៥៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ប៉ុន្តែចម្លើយខាងក្រោមរបស់សាក្សី គឺវាស៊ីសង្វាក់ទៅនឹងព័ត៌មាននេះគឺថា គាត់ស្គាល់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អ៊ីចឹងខ្ញុំសួរថា តើនៅពេលណាមួយក្នុងស្រុក ឬក៏ឃុំចន្ត្រីរបស់លោកស្រី តើកម្មាភិបាលរបស់ -- តើកម្មាភិបាលភូមិ ឬក៏ភូមិស្រុក ដែលលោកស្រីរស់ហ្នឹងមានការផ្លាស់ប្តូរដែរឬទេ?

**លោកស្រី អ៊ុំង សំអ៊ាន៖**

**ឆ៖** ក្នុងឃុំអីគ្មានផ្លាស់ផង នៅទាំងអស់។ បើស្រុកបានគេផ្លាស់ ដល់ឃុំនៅទាំងអស់ សុទ្ធតែពួកអ្នកនឹងស្រុក លោកគ្រូ។

**ស៖** ចុះនៅថ្នាក់ស្រុកវិញ តើអ្នកណាមកជំនួសគណៈស្រុកចាស់? ថាតើអ្នកណា អ្នកថ្មីមកជំនួសមកពីណា លោកស្រីបានដឹងទេ?

**ឆ៖** ខ្ញុំចីក៏មិនឮ គេនិយាយ។ គេមកជំនួសទ្នុង គេឲ្យអ្នកចាស់ចេញ អ្នកថ្មីមក មកពីនិរតីលោកគ្រូ។ និរតីហ្នឹងឯណាវិញទេ ខ្ញុំអត់ស្គាល់ដែរ។

**ស៖** បាទ នៅប្រធានបទចុងក្រោយ ខ្ញុំជម្រាបអង្គជំនុំជម្រះថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានសំណួរសួរទៅសាក្សីនេះទេ។ អ៊ីចឹងតើលោកស្រីសាក្សី សូមនិយាយអំពីការសង្កេតមើលការគោរពប្រតិបត្តិពុទ្ធសាសនានៅក្នុងកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីអាចទៅវត្តបានដែរឬទេ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩?

[១៤:៣៣:១៣]

**ឆ៖** ទៅវត្តម៉េចលោកគ្រូ បើអត់មានវត្តផង ទទេ។ គេផ្សឹកលោកចេញអស់ហើយ។

**ស៖** បើមិនមានវត្ត មិនមានអ្វីទេនៅវត្តនោះ អ៊ីចឹងគឺថា តើកម្មាភិបាលមូលដ្ឋានប្រាប់លោកស្រីអ្វីទេ អំពីព្រះសង្ឃ អំពីអ្វីជាដើមនោះ?

**ឆ៖** ប្រាប់តើ! លោកគ្រូ មានព្រះសង្ឃឯណា ព្រះសង្ឃផ្សឹកទៅកងចល័តអស់ហើយ នៅតែវត្តទទេ វត្តមួយៗ គ្មានលោកផង។

**ស៖** ចុះតើរូបព្រះពុទ្ធបដិមាករនៅតាមវត្ត តាមវិហារយ៉ាងដូចម្តេចដែរ?

**ឆ៖** គ្មានទេលោកគ្រូ គេលុបចោលអស់ហើយតាមវិហារ។ គេលុបព្រះ លុបអីហ្នឹងចោលអស់ហើយ។

**ស៖** តើលោកស្រីដឹងថា វត្តចន្ទ្រីហ្នឹងគេយកប្រើធ្វើជាអ្វីរវាងឆ្នាំ១៩៧៥ ដល់១៩៧៩?

**ឆ៖** ខ្ញុំអត់ដឹងទេលោកគ្រូ អត់ដែលទៅផង។ តែឃើញនៅសល់តែវិហារ សល់តែអី តែគ្រាន់តែលុបតែរូបព្រះ រូបអីហ្នឹង លុបចេញអស់ហើយ។

**ស៖** នៅពេលដែលរូបព្រះពុទ្ធបដិមាករត្រូវបានបំផ្លាញ ហើយគេផ្សឹកលោកសង្ឃកាលនោះ តើវាជារឿងធម្មតាចំពោះលោកស្រី ឬក៏លោកស្រីយល់ឃើញថាដូចម្តេចដែរ កាលនោះ?

[១៤:៣៥:៣១]

**ឆ៖** ខ្ញុំមានយល់ឃើញថាម៉េច យល់ឃើញថាបើគេឲ្យផ្សឹកអស់ហើយ។ បើមិនផ្សឹក នៅមានបាយឯណាឆាន់ ទទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីសាក្សី។ ខ្ញុំមិនមានសំណួរអ្វីសួរទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅវេលាម៉ោងបីខ្វះដប់នាទី។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៤ នាទី)*

[១៤:៥៤:៣០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅភាគីក្នុងការ

តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះមានបញ្ហាពីរចង់ស្តាប់មតិយោបល់ពីភាគី។ បញ្ហាទី១ គឺមានតែភាគីតែមួយទេគឺដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះបានទទួលនូវអ៊ីម៉ែល ព័ត៌មានពីអង្គភាគគាំពារសាក្សី និងអ្នកជំនាញតាមរយៈអ៊ីម៉ែល ហើយកាលពីថ្ងៃត្រង់នេះ ដែលបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-869 គាត់មានបញ្ហាសុខភាព គាត់មានជំងឺ ទី១។ ទី២ គឺគាត់មានចេតនាសូមលះបង់សិទ្ធិរបស់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ។ តើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ពីបញ្ហានេះជូនដល់អង្គជំនុំជម្រះបានយល់ដឹងដែរឬទេ ដើម្បីរៀបចំនូវកាលវិភាគសវនាការសម្រាប់សប្តាហ៍នោះ ឲ្យបានសមស្របនិងអស់លទ្ធភាពដែលៗ -- នៃពេលវេលាដែលមានសេសសល់នៅក្នុងឆ្នាំនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោក លោកស្រី -- លោកប្រធាន លោក លោកស្រីចៅក្រម និងភាគី។ ដូចដែលលោកប្រធានបានលើកឡើងអម្បាញ់មិញ គឺដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-869 គឺគាត់មានបញ្ហាសុខភាពមួយចំនួន ហើយអ្វីដែលថាកើតឡើងទៀត គឺបន្ទាប់ពីការជួបជាមួយមេធាវីរបស់គាត់ មេធាវីរបស់គាត់ពិនិត្យឃើញថាគាត់មានការមិនទុកចិត្ត ហើយមានការខ្លបខ្លាចនៅក្នុងការចូលមកឆ្លើយនៅចំពោះមុខអង្គសវនាការនៅពេលដែលមានមនុស្សគ្នាច្រើន ហើយមានន័យថា មានហាក់ដូចជាមានលក្ខណៈជាការបាក់ស្បាតនៅក្នុងការប្រឈមនឹងការឆ្លើយចំពោះមនុស្សគ្នាច្រើន។ ហើយម៉្យាងទៀតចេតនារបស់គាត់ដោយសារថា គាត់មិនទុកចិត្តខ្លួនឯងដូច្នេះ ធ្វើឲ្យគាត់មិនមានបំណងនៅក្នុងការឆ្លើយនឹង -- ចូលមកឆ្លើយនៅចំពោះអង្គសវនាការទេ។ ហើយយើងព្យាយាមទាក់ទងគាត់បន្ថែមទៀតតាមទូរស័ព្ទ ក៏ប៉ុន្តែមិនមានការលើកទូរស័ព្ទទេ។ នេះជាព័ត៌មានដែលយើងខ្ញុំមាន។ ដូច្នេះសម្រាប់មេនាំមុខយើងខ្ញុំមិនៗគាំទ្រខ្លាំង ឬក៏មិនមានការជំរុញឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវតែឡើងមកផ្តល់សក្ខីកម្មនោះទេ លោកប្រធាន។

[១៤:៥៨:២៤]

**ប្រធានអង្គជំនុំ៖**

ចុះបញ្ហាដែលថា គាត់មានបំណងក្នុងការដកខ្លួន ឬក៏លះបង់សិទ្ធិក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង មានដឹងព័ត៌មាននេះច្បាស់លាស់ទេ?

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន តាមរយៈព័ត៌មានដែលផ្តល់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះផ្ទាល់ និងតាមរយៈព័ត៌មានដែលផ្តល់ដោយអង្គភាពគាំពារសាក្សី គឺត្រូវគ្នា គឺថាគាត់បញ្ជាក់ថា គាត់មិនចង់ -- មិនមានបំណងថានឹងមកផ្តល់សក្ខីកម្មនៅទីនេះទេ។

**ប្រធានអង្គជំនុំ៖**

គាត់មិនបាននិយាយដល់ពីការលះបង់សិទ្ធិក្នុងនាមជាភាគី ដែលជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ មែនទេ?

**លោក ពេជ អង្គ៖**

បាទ ជាការពិតគាត់មិនបាននិយាយថា គាត់លះបង់លក្ខន្តិកៈគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ គាត់គ្រាន់តែបញ្ជាក់ថា គាត់មិនមានបំណងមកផ្តល់សក្ខីកម្មតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានសំណួរមួយ និងការផ្តល់ជាមតិពីរ បើសិនណាជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវដកពាក្យសុំរបស់ខ្លួន បុគ្គលនេះក៏អាចនៅកោះហៅជាសាក្សីដែរ ដោយសារថា បុគ្គលរូបនេះត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា។ ខ្ញុំទើបតែបានទទួលរបាយការណ៍ពីវេជ្ជបណ្ឌិតថា គាត់អាចមានលទ្ធភាពមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការបាន។ តើខ្ញុំអាចស្នើសុំឲ្យផ្តល់ព័ត៌មានឲ្យបានពេញលេញបន្ថិចទៀតបានទេ?

[១៥:០០:៣៣]

**លោក ពេជ អង្គ៖**

ខ្ញុំប្រហែលជាអាចចាប់សំណួររបស់លោកស្រីមិនបានច្បាស់លាស់។ ក៏ប៉ុន្តែអ្វីដែលគាត់បានបញ្ជាក់គឺ គាត់គ្មានចេតនា ឬក៏មិនមានចេតនានៅក្នុងការមកផ្តល់សក្ខីកម្មទេ។ ហើយក៏គាត់មិនបានបញ្ជាក់អំពីការដកខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរ។ គាត់មិនបានបញ្ជាក់អំពីបញ្ហាគាត់ដកខ្លួនគាត់ចេញពីភាពជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

តើសហមេធាវីនាំមុខមានបានជម្រាបទៅដើមបណ្ដឹងរដ្ឋប្បវេណីថា គាត់នៅតែអាចជាសាក្សី ហើយគាត់ត្រូវចូលខ្លួនមកចំពោះមុខតុលាការទេ នៅពេលដែលកោះហៅ ក្នុងឋានៈជាសាក្សីនោះ?

**លោក ពេជ អង្គ៖**

បាទ សូមជម្រាបលោកស្រីចៅក្រម ខ្ញុំព្យាយាមទូរស័ព្ទទៅកូនរបស់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ក៏ប៉ុន្តែមិនមានការលើកទូរស័ព្ទទេ។ ដូច្នេះ ខ្ញុំពុំទាន់មានលទ្ធភាពនៅក្នុងការបញ្ជាក់ជូនលោកស្រីចៅក្រមអំពីបញ្ហានេះទេ។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

ហើយមុននឹងបន្តទៅទៀត ខ្ញុំសូមសួរទៅខាងសហព្រះរាជអាជ្ញា តើខាងសហព្រះរាជអាជ្ញានៅតែប្រកាន់កោះហៅបុគ្គលរូបនេះជាសាក្សីដដែល ឬក៏យ៉ាងណា?

[១៥:០២:១៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំមានព័ត៌មានតិចតួចណាស់ ដើម្បីបង្ហាញអំពីយោបល់របស់ក្រុមខាងយើង។ ពិតណាស់ ថាយើងបានស្នើសុំដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ឲ្យមកបង្ហាញខ្លួន ហើយខ្ញុំឮថា គាត់មានបញ្ហាបាក់ស្បាត។ ដូច្នេះខ្ញុំគោរពទៅការសម្រេចរបស់អង្គជំនុំជម្រះ គឺមានបញ្ហាពីរ គឺទី១ ខាងផ្លូវកាយ គឺគ្រូពេទ្យអាចពិនិត្យមើលបាន ថាតើគាត់អាចមានសម្បទាក្នុងការមកផ្ដល់សក្ខីកម្ម ឬក៏អត់។ នេះគឺរឿងមួយ។ ក៏ប៉ុន្តែខ្ញុំឮអំពីការនិយាយអំពីការបាក់ស្បាត វាអាចមានករណីនេះមែន។ ដូច្នេះ យើងត្រូវតែគិតអំពីចំណុចនេះ។ យើងមិនត្រូវធ្វើឲ្យសាក្សីកាន់តែបាក់ស្បាតពីរជាន់ទេ ព្រោះគាត់ធ្លាប់បាក់ស្បាតម្ដងរួចមកហើយ។ ហើយបញ្ហាមួយទៀតនោះ គឺខ្ញុំកត់សម្គាល់ឃើញថា មានការស្លាប់ជាបន្តបន្ទាប់របស់សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងខេត្តព្រៃវែង។ ដូច្នេះនេះជាបញ្ហាព្រួយបារម្ភចំពោះយើង ពីព្រោះយើងគិតថា ត្រូវតែមានអ្នកមកជំនួសពួកគាត់ដែលបានស្លាប់ទៅ។ ហើយមានមនុស្សពីរនាក់គឺ 2-TCW-843 និង 2-TCW-997។ ខ្ញុំគិតថា ពួកគាត់ទាំងពីរនាក់ អាចមកជំនួសសាក្សីផ្សេងទៀតបាន ដែលយើងបានស្នើសម្រាប់ខេត្តព្រៃវែង។ ហើយក្នុងករណីដែលអង្គជំនុំជម្រះសម្រេចមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-869នោះ យើងអាចកោះហៅសាក្សីពីររូបនេះមកជំនួសបាន។ នេះជាយោបល់របស់ខាងយើងខ្ញុំ។

[១៥:០៣:៥៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ យើងហាក់ដូចជាមានការព្រួយបារម្ភពាក់ព័ន្ធនឹងការបាក់ស្បាតរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ តើសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីអាចបញ្ជាក់បានទេថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដឹងអំពីអង្គការ ធី.ភី.អូ ទេ? ពីព្រោះថា ធី.ភី.អូ គាត់អាចជួយអំពីរឿងនេះបាន។ ធី.ភី.អូ អាចផ្ដល់ព័ត៌មានពាក់ព័ន្ធទៅនឹងស្ថានភាពរបស់សាក្សីរូបនេះ -- អ៎! របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបាន។ បើសិនបើគាត់ដឹងអំពី ធី.ភី.អូ នោះគឺថា ធី.ភី.អូ អាចផ្ដល់ការគាំទ្រផ្លូវចិត្តដល់គាត់បាន។ យើងត្រូវតែជូនដំណឹងដល់គាត់ថា ដើមបណ្ដឹងរដ្ឋប្បវេណីណា ក៏អាចមានភាពបាក់ស្បាតដែរ។ ដូច្នេះបើយើងគ្រាន់តែនិយាយថាបាក់ស្បាតៗប៉ុណ្ណឹង គឺវាមិនគ្រប់គ្រាន់ទេ។ យើងត្រូវតែផ្ដល់ព័ត៌មានពេញលេញទៅដល់គាត់ ថាមាន ធី.ភី.អូ ដែលអាចជួយក្នុងករណីនេះបាន។

**លោក ពេជ អង្គ៖**

បាទសូមជម្រាបលោកចៅក្រម តាមការពិតមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីនាំមុខបានរៀបចំការជួបជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ទាំងដើមបណ្ដឹងរដ្ឋប្បវេណីនេះ ទាំងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតច្រើនដងរួចហើយ ហើយក៏បានផ្ដល់ឱកាសដើម្បីឲ្យពួកគាត់បានជួបជាមួយខាងអង្គការ ធី.ភី.អូ ដែរ។ ហើយដោយឡែកចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅខែតុលា កន្លងទៅនេះ គឺមេធាវីរបស់គាត់បានជួបគាត់ផ្ទាល់ពីរដង ហើយទោះបញ្ជាក់អំពីបញ្ហាទាំងព័ត៌មាន ទាំងចេតនារបស់គាត់នៅក្នុងការចូលនៅក្នុងសវនាការ។ ហើយគាត់នៅតែទទូចថា គាត់សុំមិនមកផ្ដល់សក្ខីកម្មទេ។ ដូច្នេះបញ្ហា ធី.ភី.អូ ជាបញ្ហាដែលមិនថ្មីសម្រាប់គាត់ទេ គឺមានការរៀបចំដើម្បីឲ្យគាត់បានជួបជាមួយនឹង ធី.ភី.អូ រួចហើយ ក៏ប៉ុន្តែបញ្ហាសំខាន់ ព័ត៌មានថ្មីៗនេះ គឺគាត់នៅតែបន្តទទូចថា សុំមិនមកផ្ដល់សក្ខីកម្មទៀត។

[១៥:០៦:៥១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំយល់អំពីចំណុចនេះ ក៏ប៉ុន្តែប្រសិនបើមេធាវីរបស់គាត់បានជួបគាត់ហើយ ក៏ប៉ុន្តែមានបាន

ទាក់ទងជាមួយ ធី.ភី.អូ ឬក៏អត់? ខ្ញុំស្តាប់ឮដូចជាលោកថា មេធាវីបានជួបនៅខែតុលា ហើយលទ្ធផលយ៉ាងម៉េច? យើងមិនអាចនិយាយថា ខ្ញុំមិនចង់មកផ្តល់សក្ខីកម្មទេ ពីព្រោះថាយើងមានលិខិតបញ្ជាក់វេជ្ជសាស្ត្រ ដែលបញ្ជាក់ថាគាត់អាចមកផ្តល់សក្ខីកម្មបាន។ នេះជាបញ្ហា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ខ្ញុំសូមឆ្លើយបន្ថែមលោកប្រធាន។ យើងៗទើបតែទទួលបានព័ត៌មាននេះ ដូចដែលអង្គជំនុំជម្រះដែរនៅថ្ងៃនេះ។ លោកស្រី ជេត វណ្ណលី ដែលជាមេធាវីរបស់គាត់នោះមិនមានវត្តមាននៅថ្ងៃនេះទេ។ ដូច្នេះយើងទទួលបានព័ត៌មានតិចតួចបំផុត ហើយលោកមេធាវី ពេជ អង្គ នោះក៏គាត់ព្យាយាមទូរស័ព្ទទៅដើមបណ្តឹងរដ្ឋប្បវេណីនៅពេលអាហារថ្ងៃត្រង់ដែរ។ អ៊ីចឹងយើងអត់អាចទាក់ទងគាត់បានទេ។ ដូច្នេះព័ត៌មានដែលយើងទទួលបាន ហើយដែលយើងអាចចែករំលែកជូនអង្គជំនុំជម្រះនោះគឺមានកម្រិតណាស់ ហើយបើសិនអង្គជំនុំជម្រះសួរថាតើយើងមានបានទាក់ទងជាមួយ ធី.ភី.អូ ឬក៏អត់ ហើយយើងអាចរាយការណ៍ជូនអង្គជំនុំជម្រះយ៉ាងម៉េចខ្លះពាក់ព័ន្ធទៅនឹងការគាំទ្រផ្លូវចិត្តពីខាងធី.ភី.អូ សម្រាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ? គឺយើងអាចធ្វើនៅសប្តាហ៍ក្រោយបាន នៅពេលដែលយើងអាចពិភាក្សាគ្នាជាមួយមេធាវីរបស់គាត់ផ្ទាល់ ហើយយើងអាចទាក់ទងជាមួយដើមបណ្តឹងផ្ទាល់។ ក៏ប៉ុន្តែឥឡូវនេះព័ត៌មានដែលយើងមាននេះ គឺតិចតួចណាស់។ អ៊ីចឹងខ្ញុំពិបាកនឹងឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ ណាស់។

[១៥:០៨:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អារឿងនេះប៉ុណ្ណឹងបានហើយ។ ហើយជាបន្តទៅទៀតគឺមានបញ្ហាប្រឈមដោយសារមានបញ្ហាករណីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលបានជជែកពិភាក្សាអម្បាញ់មិញនេះ។ ហើយនិងបញ្ហាមួយទៀត គឺសាក្សីដែលគ្រោងផ្តល់សក្ខីកម្មនៅថ្ងៃនេះហ្នឹង គឺមានបញ្ហាផ្ទាល់ខ្លួន ដោយសារម្តាយរបស់គាត់ទទួលមរណភាព ហើយគាត់មិនអាចមកបានទេ គឺ 848។ អ៊ីចឹងការរៀបចំកាលវិភាគសវនាការ គឺវាមានបញ្ហាប្រឈមនៅសប្តាហ៍ក្រោយ។ ហើយដោយសារអង្គជំនុំជម្រះមិនបាន ទាន់បានរៀបជូនដំណឹងទៅភាគីអំពីថាខ្លួនហ្នឹងមានបំណងក្នុងការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-846 និង 2-TCW-1000 ដែលអង្គជំនុំជម្រះបានសម្រេចតាមសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានផ្សព្វផ្សាយនូវសេចក្តីសម្រេចផ្ទាល់មាត់កាលពីថ្ងៃទី០៧ ធ្នូ កន្លងមក។ ហើយឥឡូវនេះអង្គជំនុំ

ជម្រះចង់ដឹង ដោយសារមានបញ្ហាប្រឈមផ្នែកខាងសាក្សីផ្តល់សក្ខីកម្មនៅសប្តាហ៍ក្រោយ ដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីសួរបញ្ជាក់ថា សាក្សីពីររូបដែលតាមគម្រោងការគិតរបស់អង្គជំនុំជម្រះ ថានឹងស្តាប់សក្ខីកម្មរបស់គាត់នៅដើមដំបូងនៃ ខែមករា ឆ្នាំ២០១៦ទេ។ ប៉ុន្តែឥឡូវវាមានបញ្ហាអ៊ីចឹង សួរថា តើបានត្រៀមរៀបចំខ្លួនរួចហើយឬនៅក្នុងការដែលអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះនៅក្នុងសប្តាហ៍ក្រោយ? បើសិនបើការរៀបចំកាលវិភាគសវនាការទៅ មានរកមនុស្ស សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្មមិនបាននោះ។ តើអាចប្រព្រឹត្តទៅបានដែរឬទេ?

[១៥:១០:៤៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំមិនមានឈ្មោះ 2-TCW-1000។ អ៊ីចឹងខ្ញុំពិបាកឆ្លើយនឹងសំណួរ នឹងផ្នែកទី២នៃសំណួររបស់លោកប្រធាន។ ហើយចំពោះសាក្សី 2-TCW-846 យើងមិនមានការយល់ទាស់អ្វីទេក្នុងការដែលអង្គជំនុំជម្រះស្តាប់ចម្លើយគាត់នៅសប្តាហ៍ក្រោយ ហើយមាន 2-TCW-820 ទៀតដែលមាននៅក្នុងបញ្ជី ដែលខ្ញុំគិតថាគាត់នឹងត្រូវមកផ្តល់សក្ខីកម្មនៅសប្តាហ៍ក្រោយដែរ ប្រសិនខ្ញុំមិនច្រឡំទេ។ ខ្ញុំអត់មានការជំទាស់អីទេ ប្រសិនបើអង្គជំនុំជម្រះកោះហៅនោះ។ ខ្ញុំមិនដឹងថា តើមានអ្នកណាម្នាក់អាចផ្តល់ឈ្មោះជាលាយលក្ខណ៍អក្សរមកដល់ខ្ញុំបានទេគឺ 2-TCW-1000 នេះ ខ្ញុំអត់មានព័ត៌មានពាក់ព័ន្ធនឹងគាត់សោះ ឬអាចក្រឡាបញ្ជីអាចផ្តល់ព័ត៌មានបានទេ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីចៅក្រម ហ្វេនស៍ យកទៅជូនតំណាងសហព្រះរាជអាជ្ញាអន្តរជាតិពិនិត្យ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

នេះជាសាក្សីដែលគ្រោងនឹងផ្តល់សក្ខីកម្មនៅខែមករា។ ដូច្នេះប្រសិនបើមកសប្តាហ៍ក្រោយ ខ្ញុំសូមឱ្យលោកប្រធានដាក់នៅចុងសប្តាហ៍វិញលោកប្រធាន ដើម្បីឱ្យយើងអាចរៀបចំខ្លួនបាន។ ប្រហែលជាចាប់ពីថ្ងៃពុធ វាល្អសម្រាប់យើង ដែលយើងអាចត្រៀមខ្លួនបានទាន់ពេលវេលាសម្រាប់សាក្សី

2-TCW-1000 នេះ លោកប្រធាន។ សូមអរគុណ។

[១៥:១២:៣៧]

**ប្រធានអង្គជំនុំ៖**

ទទួលយកមកវិញ ជូនគាត់វិញ។ បាទ អរគុណ។ ចុះខាងភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងម៉េចដែរ លើបញ្ហាអង្គជំនុំជម្រះរៀបចំកាលវិភាគសវនាការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូបចុងក្រោយ ដែលអង្គជំនុំជម្រះជម្រាបអំមិញថា មានបំណងដាក់កាលវិភាគនៅដើមខែមករា ឆ្នាំ២០១៦នោះ ប៉ុន្តែឥឡូវ វាមានបញ្ហាខ្វះមនុស្សគឺសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្មសម្រាប់សប្តាហ៍ក្រោយ តើមានមតិយោបល់អ្វីដែរទេ លើការរៀបចំកាលវិភាគសវនាការបែបនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សម្រាប់ខាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានការជំទាស់អីទេ។

**ប្រធានអង្គជំនុំ៖**

ចុះខាងក្រុមមេធាវីការពារក្តីវិញ យ៉ាងម៉េចដែរ? ក្រុមមេធាវីការពារក្តីលោក នួន ជា?

**លោក វ៉ិចទ័រ កូប៉េ៖**

បើខ្ញុំយល់មិនច្រឡំទេ ពាក់ព័ន្ធទៅនឹង 2-TCW-1000 នេះគឺគួរតែកោះហៅនៅពេលដែលការស៊ើបអង្កេតចប់សព្វគ្រប់ទៅ។ ហើយម៉្យាងទៀតគឺដោយសារតែវាមានភាពស្មុគស្មាញផង។ បើសិនណាជាគាត់ត្រូវបានកោះហៅមកនៅសប្តាហ៍ក្រោយ យើងខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញាមេត្តាកុំកោះហៅនៅចំថ្ងៃចន្ទអី គឺថានៅកោះហៅគាត់នៅចុងសប្តាហ៍ទៅ។ ខ្ញុំមិនដឹងថាតើមានការកំណត់ពេលវេលាសម្រាប់សាក្សីរូបនេះមួយថ្ងៃ ឬក៏ពីរថ្ងៃនោះទេ។ នេះគឺជាការកត់សម្គាល់របស់ខាងយើងខ្ញុំលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហមេធាវីការពារក្តីលោក ខៀវ សំផន!

[១៥:១៤:៥៥]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ចំពោះសាក្សី 2-TCW-846 នោះគឺមិនមានការលំបាកអ្វីសម្រាប់

ខាងយើងខ្ញុំទេ ក៏ប៉ុន្តែ 2-TCW-1000 ជាសាក្សីមួយរូបដែលនឹងត្រូវកោះហៅឲ្យមកផ្តល់សក្ខីកម្មទៅតាមសំណើថ្មីៗនេះ របស់សហព្រះរាជអាជ្ញា។ យើងមានបញ្ហាខាងការរៀបចំខ្លួនហើយ។ ប្រសិនបើអង្គជំនុំជម្រះកោះហៅគាត់មកមុនខុសពីការគ្រោងទុកនោះ យើងជាមេធាវីការពារក្តីពិបាកនឹងរៀបចំខ្លួនណាស់។ អ៊ីចឹងបើអាចកោះហៅ សូមឲ្យគាត់កោះហៅ សូមមេត្តាកោះហៅនៅចុងសប្តាហ៍។ ខ្ញុំសូមរំឭកផងដែរថា យើងតែងតែព្យាយាមធ្វើយ៉ាងម៉េចឲ្យមានភាពទំនេរ ហើយនិងសម្របខ្លួនទៅតាមការផ្លាស់ប្តូរកាលវិភាគរបស់អង្គជំនុំជម្រះ ដែលអាចកើតមានឡើងជាយថាហេតុដោយសារតែការផ្លាស់ប្តូរពីវេសស៊ូ។ ដូច្នេះចំពោះផ្នែកនេះ យើងមានការផ្លាស់ប្តូរច្រើនណាស់។ ហើយនៅក្នុងដំណើរការការងាររបស់យើងហ្នឹងគឺថា យើងវាមានបញ្ហាពិបាកស្មុគស្មាញក្នុងការរៀបចំខ្លួនដើម្បីតាំងសំណួរទៅកាន់សាក្សីហើយជាពិសេសគឺសាក្សីដែលយើងមិនសូវស្គាល់ច្បាស់នោះ ជាមុន នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២ យើងនេះ។ ហើយការសម្រេចកោះហៅហ្នឹង គឺថ្មីៗទៀត ទើបតែធ្វើឆាប់ៗនេះទេ។ ដូច្នេះសូមអង្គជំនុំជម្រះពិចារណាផង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណរាល់មតិយោបល់របស់ភាគីដែលបានលើកឡើងបញ្ហានេះ ហើយក៏សូមអរគុណផងដែរ មតិយោបល់របស់លោកមេធាវី វ៉ិចទ័រ កូប៉េ ដែលបានបញ្ជាក់អំពីកាលវេលាដែលអង្គជំនុំជម្រះកំណត់ស្តាប់សក្ខីកម្មសាក្សី TCW-1000 នេះ។ អង្គជំនុំជម្រះក៏បានពិនិត្យបញ្ហានេះដែរ ហើយក៏មិនបាននឹកគិតថា បញ្ហានេះវាជួបប្រឈមភ្លាមៗអ៊ីចឹងទេ។ អង្គជំនុំជម្រះគិតថា នឹងធ្វើនៅក្នុងសប្តាហ៍ក្រោយដើម្បីរៀបចំសម្រាប់ត្រៀមសម្រាប់ដើមឆ្នាំក្រោយទេ ប៉ុន្តែឥឡូវវាជួបនឹងស្ថានភាពប្រថុចប្រញ៉ុចបែបនេះ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះស្តាប់ភាគី ហើយចំពោះពេលវេលាហ្នឹង អង្គជំនុំជម្រះនឹងជម្រាបជូនភាគីទៅតាមរយៈអ៊ីម៉ែល អាចនៅរសៀលនេះ អំពីពេលវេលាដែលត្រូវបែងចែកឲ្យទៅភាគីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី TCW-1000។

បាទ អរគុណ។ ហើយបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលសាក្សីរូបនេះ ហើយខ្ញុំស្តាប់សហព្រះរាជអាជ្ញារងអន្តរជាតិថា មិនមានសំណួរទេ ប៉ុន្តែវាមិនច្បាស់ អ៊ីចឹងសូមបញ្ជាក់ដោយខ្លួនឯង តើមានសំណួរសួរសាក្សីរូបនេះដែរឬទេសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

[១៥:១៧:៥៨]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសំណួរទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

បាទ លោកប្រធាន នេះជាការបញ្ជាក់តូចមួយពាក់ព័ន្ធទៅនឹងប្រវត្តិរូបរបស់អ្នកទោសនៅក្នុងសំណុំរឿង គឺជាប្រវត្តិរូបដែលត្រូវបានធ្វើឡើងនៅក្នុងសំណុំរឿងនៅពេលចូលមន្ទីរ ស-២១។ ហើយវាមានទម្រង់ស្ដង់ដារដែលត្រូវបានផ្ដល់យថាភាពដោយ ឌុច និង ស្ទីវ រួចមកហើយ។ ក៏ប៉ុន្ដែឈ្មោះរបស់ប្អូននៃសាក្សីរូបនេះ គឺស្ថិតនៅក្នុងបញ្ជីកែប្រែរបស់ ស-២១ ដែលផ្ដល់ដោយមន្ទីរសហព្រះរាជអាជ្ញាគឺ E3/342 គឺលេខ 5575។ ក៏ប៉ុន្ដែយើងក៏អាចផ្ដល់ព័ត៌មានបន្ថែមបានដែរ ប្រសិនបើអង្គជំនុំជម្រះត្រូវការនៅពេលក្រោយនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដំបូងនេះ សហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១៥:១៩:២៧]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រី សាក្សី។ ខ្ញុំមានសំណួរខ្លះៗ សួរទៅកាន់លោកស្រី។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** មុនពេលឈប់សម្រាកនេះគឺ លោកស្រីត្រូវបានសួរពីបុគ្គលម្នាក់ឈ្មោះ សុផល ដែលជាចៅហ្វាយស្រុកដែលនៅក្នុងស្រុករបស់លោកស្រី។ ខ្ញុំដឹងថា លោកស្រីស្គាល់គាត់មិនបានច្បាស់ទេ ប៉ុន្ដែខ្ញុំសូមអានសម្រង់ចេញពីសាក្សីម្នាក់ឲ្យលោកស្រីស្ដាប់ គឺសាក្សីដែលរស់នៅក្នុងឃុំ ស្រុកជាមួយលោកស្រីដែរ ប៉ុន្ដែភូមិផ្សេងគ្នា។ ហើយខ្ញុំនឹងបន្ទាប់មកសួរលោកស្រីៗយល់ថាម៉េច គឺឯកសារ E3/7816

ERN ជាភាសាខ្មែរ 00277274, បារាំង 00339874-75, អង់គ្លេស 00292839។ សាក្សីរូបនេះ បានឆ្លើយដូចតទៅ៖ “នៅក្នុងឆ្នាំ១៩៧៦ បុរសនៅក្នុងភូមិរបស់ខ្ញុំរួមទាំងបងប្អូនខ្ញុំ និងឪពុកខ្ញុំត្រូវបានទ័ពស្រុកចាប់យកទៅដោយសារថា អ្នកភូមិបានចូលរួមជាមួយខ្មែរស។ ខ្មែរសនេះមានមេដឹកនាំជាលេខាស្រុករមាសហែក ឈ្មោះ សុផល។ ដោយសារមូលហេតុនេះហើយបានជាក្រោយមក ពួកលេខាស្រុកត្រូវបានចាប់ខ្លួន។” តើលោកស្រីធ្លាប់ដែលបានឮថា តាសុផល លេខាស្រុកនេះជាប់ពាក់ព័ន្ធជាមួយនឹងចលនាខ្មែរស ដែរទេ?

[១៥:២១:៤៧]

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ខ្ញុំអត់ដែលដឹងទេ លោកគ្រូ។ មិនដែលឮផង មិនដឹងខ្មែរសម៉េចផង។

**ស៖** មិនថ្វីទេលោកស្រី សូមអរគុណ។ សំណួរមួយទៀត គឺពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅពេលដែលលោកស្រីរស់នៅក្នុងភូមិរបស់លោកស្រី តើលោកស្រីនឹកឃើញអំពីការស្តាប់បានសំឡេងដែលគ្រាប់បែក គ្រាប់កាំភ្លើងនៅតាមព្រំដែន គឺសំឡេងគ្រាប់កាំភ្លើងរបស់កងទ័ពវៀតណាមដែលផ្ទុះនៅតាមព្រំដែននោះទេ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន សំណួរនេះគួរតែសួរឲ្យបានច្បាស់បន្តិច ដោយយើងបញ្ជាក់អំពីពេលវេលាឲ្យបានច្បាស់លាស់។ នេះជាជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។ អ៊ីចឹងពេលមួយណា សូមលោកមេធាវីបញ្ជាក់ឲ្យបានច្បាស់ វាអាចធ្វើឲ្យសាក្សីភ័ន្តច្រឡំ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនទាន់បានយោងទៅលើរយៈពេលជាក់លាក់ណាមួយទេ។ ខ្ញុំសួរសំណួរទូទៅនេះ វាពាក់ព័ន្ធទៅនឹងរយៈនៅក្នុងសំណុំរឿងនេះតែម្តង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី លោកស្រីអាចនឹកឃើញថាចន្លោះពីឆ្នាំ១៩៧០ ទៅដល់ ឆ្នាំ១៩៧៩ លោកស្រីធ្លាប់ឮសំឡេងគ្រាប់បែក សំឡេងគ្រាប់ផ្លោង គ្រាប់កាំភ្លើងដែលបាញ់បោះឡើងដោយកងទ័ពវៀតណាមចូលមកក្នុងដែនដីកម្ពុជាទេ?

[១៥:២៣:៥២]

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** ឮលោកគ្រូ មាន។

**ស៖** លោកស្រីនៅចាំថាឆ្នាំណាដែរទេ ដែលលោកស្រីឮសូរស្នូរគ្រាប់កាំភ្លើង ស្នូរគ្រាប់ផ្លោងនេះ?

**ឆ៖** មិនដឹងឆ្នាំទេ លោកគ្រូ អត់បានគិតផង។ យួនទម្លាក់ យួនអីនោះ អត់ដឹងគិតផង។

**ស៖** តើវាមុន ឬក៏ក្រោយពេលខ្មែរក្រហមកាន់កាប់អំណាច?

**ឆ៖** មុននុ៎ងលោកគ្រូ មកទម្លាក់នុ៎ង គ្រាប់ផ្លោងគ្រាប់អីមុននុ៎ង។

**ស៖** ចុះលោកស្រីធ្លាប់បានឮសូរគ្រាប់ផ្លោង គ្រាប់បែក នៅក្នុងអំឡុងពេលដែលបងប្រុសលោកស្រីត្រូវបានបញ្ជូនមកព្រលានយន្តហោះកំពង់ឆ្នាំងដែរទេ? តើលោកស្រីធ្លាប់បានឮសូរគ្រាប់កាំភ្លើងនៅក្នុងឆ្នាំ១៩៧៨ដែរទេ?

**ឆ៖** ឮ លោកគ្រូ។

**ស៖** តើលោកស្រីអាចរៀបរាប់អំពីស្នូរគ្រាប់កាំភ្លើងនេះ ឮសូររយៈពេលយូរប៉ុនណាដែរ? ហើយគេបាញ់បោះមកពីខាងណា? សូមលោកស្រីជួយបញ្ជាក់ឲ្យបានលម្អិតបន្តិច សំឡេងស្នូរគ្រាប់កាំភ្លើងផ្ទុះឡើងនៅក្នុងឆ្នាំ១៩៧៨នុ៎ង។

**ឆ៖** ឮសូរមកពីកើត ទាំងយួនទាំងអី មកទម្លាក់ហ្នឹង មកពីខាងកើតវិញ។ ដឹងយួនពីណាពីណីខ្ញុំមិនដឹងដែរ។

[១៥:២៦:២០]

**ស៖** ធ្វើយ៉ាងដូចម្ដេច ទើបលោកស្រីអាចគិតថា ជាការបាញ់ផ្លោងពីខាងវៀតណាមចូលមកក្នុងទឹកដីកម្ពុជា? ធ្វើម៉េចបានជាលោកស្រីអាចហ៊ានៗឆ្លើយថា ជាការបាញ់មកពីខាងវៀតណាមចូលកម្ពុជានោះ?

**ឆ៖** បើខ្ញុំឃើញមកពីនុ៎ងមែន តែដឹងវៀតណាម ដឹងអី ខ្ញុំអត់ដឹងផង។ តែបាញ់មកពីកើតវិញ។

**ស៖** លោកស្រីនៅចាំទេ ស្នូរគ្រាប់កាំភ្លើងនេះ មានរយៈពេលយូរប៉ុនណាដែរ?

**ឆ៖** ពេលយូរ លោកគ្រូ រាប់ខែ។ ប្រជាជនរត់ចង់ងាប់ហើយ។

**ស៖** លោកស្រីនៅចាំទេ ថាមានប្រជាជនច្រើនទេ ដែលរត់គេចខ្លួនចេញពីភូមិរបស់លោកស្រី ឬក៏ចេញពីភូមិដទៃៗទៀត នៅក្នុងឃុំស្រុករបស់លោកស្រីហ្នឹង?

**ឆ៖** មានច្រើន លោកគ្រូ រត់គេចពីគ្រាប់ផ្លោង យួនទម្លាក់។ រត់ទៅនៅត្រើយខាងលិច ខាងលិចព្រែក។

**ស៖** តើមានពេលណាមួយនោះ លោកស្រីនៅចាំថា បានរត់គេចខ្លួនចេញពីកងចល័ត នៅពេលដែលកងចល័តរបស់លោកស្រីកំពុងតែច្រូតកាត់ ដើម្បីរត់គេចចេញពីគ្រាប់ផ្លោង គ្រាប់កាំភ្លើងទាំងនេះ លោកស្រីចាំទេ?

[១៥:២៨:៣៨]

**ឆ៖** មិនសូវចាំទេ លោកគ្រូ។ មិនដឹងពីខែណា ពីឆ្នាំណាផង។ មិនដឹងខែណា ព្រោះខ្ញុំអត់បានគិត តែចេះរត់ទៅ ទៅច្រូតនៅក្បែរព្រំដែនឯកើត។

**ស៖** ខ្ញុំសូមអានសម្រង់ខ្លីមួយ ដែលលោកស្រីឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ERN ជាភាសាអង់គ្លេស 00--

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាត មេធាវីអានញាប់ពេក មិនទាន់។

**ប្រធានអង្គជំនុំ៖**

លោក រ៉ិចទ័រ កូប៉េ អានម្តងទៀត! អ្នកបកប្រែបកអត់ទាន់ទេ។ អានលេខឯកសារអំមិញ។

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** ERN ជាភាសាខ្មែរគឺ – ឯកសារ E3/7545 ERNគឺ 00089205, បារាំង 00775800, អង់គ្លេស 00336493។ លោកស្រីសាក្សី លោកស្រីឆ្លើយថា៖ “ខ្ញុំនៅក្នុងកងចល័ត កំពុងតែច្រូតកាត់ស្រូវ ហើយប្តីរបស់ខ្ញុំធ្វើការផ្សេងពីខ្ញុំ។ ខ្ញុំចាំ ថាខ្ញុំបានរត់គេចខ្លួននៅពេលដែលយួនបាញ់ផ្លោងចូលមក។” លោកស្រីចាំទេ នៅពេលដែលលោកស្រីរត់គេចចេញពីគ្រាប់ផ្លោងរបស់យួននុ៎ង?

**លោកស្រី អ៊ុំង សំអ៊ាន៖**

**ឆ៖** ខ្ញុំចាំចឹមិនចាំ លោកគ្រូ រត់ចេញមកពីកើតមកលិចវិញ។ គេផ្លោងមកពីកើត រត់មកពីកើតមកលិច មកស្រុកឯងវិញ មកផ្ទះវិញ។

[១៥:៣០:៥១]

**ស៖** តើតែលោកស្រីទេឬដែលរត់គេចចេញពីគ្រាប់ផ្លោងនេះ ឬក៏អ្នកដទៃទៀតនៅក្នុងកងរបស់លោកស្រីហ្នឹងក៏រត់គេចខ្លួនដែរ?

**ឆ៖** មកតាំងអស់តែគ្នាហ្នឹង លោកគ្រូ មានអ្នកណានៅ។ រត់គេចពីគ្រាប់ផ្លោង យួនទម្លាក់ផងគ្រាប់ផ្លោងផង។

**ស៖** ថ្ងៃដែលលោកស្រីនិងដទៃទៀតរត់ចេញពីគ្រាប់ផ្លោងនុំង តើលោកស្រីនៅចាំថា មានអ្នកណាម្នាក់រងរបួស ឬក៏ស្លាប់ដែរទេ សមាជិកនៅក្នុងកងរបស់លោកស្រីហ្នឹង?

**ឆ៖** អត់មានទេ លោកគ្រូ រត់រួចទាំងអស់គ្នាមក។

**ស៖** តើលោកស្រីរត់ចេញពីកន្លែងធ្វើការហ្នឹង អស់រយៈពេលប៉ុនណា? ហើយពេលណាលោកស្រីត្រឡប់ទៅធ្វើការនៅកន្លែងនោះវិញ? តើលោកស្រីរត់គេចហ្នឹង រយៈពេលយូរប៉ុនណាដែរ?

**ឆ៖** មកពីរថ្ងៃបីថ្ងៃ លោកគ្រូ ទៅវិញ ទៅច្រូតវិញ។

**ស៖** នៅពេលដែលលោកស្រី និងអ្នកដទៃទៀតរត់ចេញ រត់គេចពីគ្រាប់ផ្លោងនេះ តើបងប្រុសរបស់លោកស្រីចូលរួមប្រយុទ្ធជាមួយនឹងវៀតណាមដែរ ឬក៏ត្រូវ -- ប្អូនរបស់លោកស្រីចូលរួមប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមហ្នឹងដែរ ឬក៏គេបញ្ជូនគាត់មកកំពង់ឆ្នាំងហើយទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ លោកគ្រូ។ ខ្ញុំនៅឯនេះ ហើយគេនៅឯនោះ ទាហាន។

**ស៖** តើលោកស្រីនៅចាំថាបានឃើញកងទ័ពកម្ពុជារបស់កម្ពុជាប្រជាធិបតេយ្យ គឺថាបាញ់តបឬក៏បាញ់ផ្លោង ដោយគ្រាប់កាំភ្លើងធំតបទៅខាងវៀតណាមវិញទេ?

**ឆ៖** ខ្ញុំអត់បានឃើញទេ លោកគ្រូ។ មិនដឹងកាំភ្លើងធំមិនដឹងគេដាក់ត្រង់ណាផង ខាងខ្មែរឃើញតែកាំភ្លើងចេញមកតែពីកើត។

**ស៖** សាក្សីម្នាក់ដែលបានមកផ្តល់សក្ខីកម្មពីមុននេះ គឺគាត់មិនមកពីស្វាយរៀងទេ តែមកពីខាងខេត្តព្រៃវែង។ គាត់បាននិយាយអំពីពេលវេលាមួយដែល សោ ភឹម គាត់និយាយអំពី សោ ភឹម។ អ៊ីចឹងបើនិយាយអំពី សោ ភឹម នេះលោកស្រីធ្លាប់ឮឈ្មោះគាត់នេះទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ លោកគ្រូ មិនដែលឮឈ្មោះគាត់ផង។

**ស៖** ខ្ញុំប្រហែលជាសួរសំណួរនេះម្តងហើយ ក៏ប៉ុន្តែសូមសួរបញ្ជាក់ឡើងវិញ។ តើលោកស្រីមានដែលឃើញជនស៊ីវិលទទួលរងរបួសដោយសារការបាញ់ផ្លោងនេះទេ? នេះមិនសំដៅតែអ្នកដែលនៅក្នុងកងរបស់លោកស្រីទេ ខ្ញុំនិយាយអំពីជនស៊ីវិលដែលរស់នៅក្នុងខេត្តរបស់លោកស្រីតែម្តង។

[១៥:៣៥:៤៩]

**ឆ៖** ផ្លោងមកមានត្រូវស្លាប់ដែរលោកគ្រូ មួយពីរអី វាផ្លោងចំ។

**ស៖** លោកស្រីស្គាល់អ្នកដែលស្លាប់ហ្នឹងដែរ?

**ឆ៖** អត់ស្គាល់ទេលោកគ្រូ។ កងខុសៗគ្នា ម៉េចនឹងស្គាល់។

**ស៖** អរគុណលោកស្រី។ ខ្ញុំសូមសួរពីចំណុចមួយដែលលោកស្រីបានឆ្លើយទៅអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារខ្ញុំយល់វាមិនច្បាស់នូវអ្វីដែលលោកស្រីបានឆ្លើយនោះ គឺឯកសារ E3/7545 ដដែល ERNជាភាសាខ្មែរ00089216, អង់គ្លេស00336449, បារាំង00775810 សំណួរគឺសួរអំពីថា៖ “តើមានប្រជាជនវៀតណាមរបស់នៅក្នុងភូមិលោកស្រីដែរឬក៏អត់ទេ? ហើយលោកស្រីបានឆ្លើយថា៖ មិនមានទេ ប៉ុន្តែក្នុងឆ្នាំ១៩៧០ ពួកគេមកស្នាក់នៅទីនោះប្រហែលពីរបីថ្ងៃ ហើយគេក៏ទៅ ធ្វើដំណើរចេញទៅកន្លែងផ្សេងទៅ។” នៅពេលដែលលោកស្រីនិយាយពី៧០នេះ គឺលោកស្រីសំដៅទៅលើរយៈពេល៧០ថ្ងៃ ឬលោកស្រីសំដៅទៅលើឆ្នាំ១៩៧០?

**ឆ៖** ឆ្នាំ១៩៧០ លោកគ្រូ។ ប្រជាជនយួនគេមកសម្រាកមួយថ្ងៃពីរថ្ងៃ គេទៅអស់ទៅ មិនដឹងទៅណា មានប្រុសមានស្រី។ មិនដឹងគេទៅណាវិញទេ ខ្ញុំអត់ដឹងដែរ។

**ស៖** ហើយចុះប្រជាជនវៀតណាមទាំងនេះមកពីណាដែរ?

**ឆ៖** ឃើញមកពីកើតវិញ។

[១៥:៣៨:២៥]

**ស៖** តើពួកគាត់មកពីប្រទេសវៀតណាម ឬក៏ពួកគាត់គ្រាន់តែមកពីកន្លែងណាមួយនៃប្រទេសកម្ពុជាទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ គ្រាន់តែឃើញមក មិនដឹងមកពីណាវិញផង។

**ស៖** តើលោកស្រីបានដឹងអំពីការប្រព្រឹត្តទៅលើប្រជាជនវៀតណាមដែរទេ ក្រោយពេលរដ្ឋប្រហាររបស់ លន់ នល់? តើលោកស្រីដឹងថាប្រជាជនវៀតណាម ត្រូវបានគេប្រព្រឹត្តទៅលើពួកគាត់ហ្នឹងយ៉ាងដូចម្ដេចដែរ នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំអត់ដឹងទេលោកគ្រូ។ ត្រង់ណាមិនដឹង ខ្ញុំសូមអត់ឆ្លើយទេ ខ្ញុំអត់ដឹង។

**ស៖** មិនទេលោកស្រី។ ខ្ញុំមានសំណួរតិចតួចទៀតទេ ដែលត្រូវសួរទៅកាន់លោកស្រី។ តាមរយៈសក្ខីកម្មរបស់លោកស្រី គឺថាលោកស្រីធ្វើការនៅ ច្រូតកាត់នៅតាមវាលស្រែផង ហើយក៏ធ្វើការជីកដី រែកដី ជីកប្រឡាយផងដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែនលោកគ្រូ។ ចុះបើគេប្រើ ធ្វើម៉េច ចេះតែទៅហើយ ទាំងចាស់ទាំងក្មេង។

**ស៖** លោកស្រីនឹកឃើញទេ ថាគេចាត់តាំងឲ្យលោកស្រីទៅជីកប្រឡាយនៅក្នុងស្រុករបស់លោកស្រីហ្នឹងនៅពេលណាដែរ?

**ឆ៖** មិនដឹងឆ្នាំប៉ុន្មានទេលោកគ្រូ ប្រឡាយនៅតែនៅរាល់ថ្ងៃ ខាងកើតផ្ទះខ្ញុំនោះ រែកចង់ងាប់ហើយ។

**ស៖** លោកស្រីនៅចាំទេ លោកស្រីជីកប្រឡាយលើកទំនប់ហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំទៅហ្នឹងទៅក្រោយគេ បានជិតមួយឆ្នាំដែរលោកគ្រូ ទាល់តែឈឺបានគេឲ្យមកវិញ។

[១៥:៤១:៣០]

**ស៖** តើប្តីរបស់លោកស្រីទៅជីកប្រឡាយនុ៎ងជាមួយលោកស្រីដែរទេ?

**ឆ៖** អត់ទៅជាមួយទេ ប្តីខ្ញុំគេឲ្យទៅជីកឯកើតស្វាយរៀងនោះ ហើយខ្ញុំនៅជីកនៅនឹងស្រុកឯងខាងកើតផ្ទះខ្ញុំ។

**ស៖** នៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីបានឆ្លើយអំពីពេលម៉ោងការងារ។ លោកស្រីនៅចាំទេ នៅក្នុងស្រុករបស់លោកស្រីហ្នឹង គេឲ្យធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

**ឆ៖** ពីម៉ោងប្រាំពីរដល់ម៉ោងដប់មួយ លោកគ្រូ។ ដល់ពេលឈប់ម៉ោងដប់មួយហ្នឹង ជំនាន់នោះគេឲ្យប្រជុំ ប្រជុំហើយបានគេឲ្យបាយហូប។ ហូបហើយសម្រាកតែមួយបន្តិចទេ គេឲ្យធ្វើការទៀតហើយ។

**ស៖** ហើយបន្ទាប់ពីហូបបាយថ្ងៃត្រង់ហើយ លោកស្រីត្រូវចាប់ផ្តើមធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានទៀត?

**ឆ៖** ពីម៉ោងមួយដល់ម៉ោងប្រាំ លោកគ្រូ។

**ស៖** ចុះលោកស្រីមានត្រូវធ្វើការនៅពេលយប់ដែរទេ? គេឲ្យលោកស្រីធ្វើការនៅពេលយប់បន្ថែមទៀតទេ?

**ឆ៖** អត់មានធ្វើទេពេលយប់។ ខ្ញុំចាស់ដែរហើយ ធ្វើម៉េចគេឲ្យធ្វើ។ អាយុច្រើនដែរហើយកាលនុ៎ង។

**ស៖** នៅពេលនោះ គឺក្រោយឆ្នាំ១៩៧៥ តើលោកស្រីផ្ទាល់ជាប្រជាជនថ្មី ឬក៏ជាអ្នកមូលដ្ឋាន?

**ឆ៖** ខ្ញុំអ្នកមូលដ្ឋាននៅស្រុកកំណើតខ្ញុំនៅនុ៎ងតែម្តង មិនមែនប្រជាជនថ្មីទេលោកគ្រូ។ គេហៅថាប្រជាជនចាស់។

[១៥:៤៤:២៥]

**ស៖** តើមានប្រជាជនថ្មីរស់នៅក្នុងភូមិលោកស្រី ឬក៏នៅក្នុងកងជាមួយលោកស្រីដែរទេ?

**ឆ៖** មានលោកគ្រូ មាននៅប្រជាជនថ្មី ដល់មកជម្លៀសទៅពីភ្នំពេញពីអីអឹចឹងទៅ គេយកទៅឲ្យធ្វើជាគ្នាទៅ ប្រជាជនថ្មីប្រជាជនចាស់ជាមួយគ្នាហ្នឹង។

**ស៖** តើប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីត្រូវធ្វើការដូចគ្នាដែរឬទេ ទាំងចំនួនម៉ោងការងារហ្នឹង គឺពីម៉ោងប្រាំពីរ ទៅដល់ម៉ោងដប់មួយ រួចហើយបាយ បាយហើយពីម៉ោងមួយទៅដល់ម៉ោងប្រាំ ធ្វើការអីចឹងដូចគ្នា ឬក៏អត់ទេ ទាំងមូលដ្ឋាន ទាំងអ្នកថ្មីហ្នឹង?

**ឆ៖** ធ្វើដូចគ្នាហ្នឹងលោកគ្រូ ពីម៉ោងប្រាំពីរទៅដល់ម៉ោងដប់មួយ ពីម៉ោងមួយដល់ម៉ោងប្រាំដូចតែគ្នាហ្នឹង ធ្វើការចូលតែគ្នា។

**ស៖** ដូច្នេះនៅក្នុងស្រុករបស់លោកស្រី គឺនៅភូមិ និងកងរបស់លោកស្រីហ្នឹង គេមិនបានបែងចែកឲ្យខុសគ្នារវាងអ្នកមូលដ្ឋាន និងអ្នកថ្មីទេក្នុងការធ្វើការងារ អីចឹងមែនទេ?

**ឆ៖** ចាស ធ្វើដូចគ្នា។ គេមិនបែងចែកថាថ្មី ថាចាស់ទេ។

**ស៖** ចុះរបបអាហារវិញ នៅក្នុងភូមិរបស់លោកស្រី ឬនៅក្នុងកងរបស់លោកស្រី ប្រជាជនថ្មី និងអ្នកមូលដ្ឋានទទួលបានរបបអាហារហ្នឹងដូចៗគ្នាទេ?

**ឆ៖** បានដូចៗគ្នាហ្នឹងលោកគ្រូ មួយៗកូនចានដូចតែគ្នាហ្នឹង ថ្មីចាស់អី។

**ស៖** ចុះប្រសិនបើប្រជាជនថ្មី ធ្លាក់ខ្លួនឈឺ ឬក៏ប្រជាជនមូលដ្ឋានហ្នឹងធ្លាក់ខ្លួនឈឺ តើអ្នកទាំងពីរប្រភេទនេះទទួលបានការព្យាបាលហ្នឹងដូចគ្នាទេ?

**ឆ៖** ព្យាបាលដូចតែគ្នា លោកគ្រូ ទៅដេកពេទ្យដូចតែគ្នា។

**ស៖** តើត្រឹមត្រូវដែរទេ បើសិនជាខ្ញុំនិយាយថា នៅក្នុងភូមិរបស់លោកស្រី ក៏ដូចជានៅក្នុងកងរបស់លោកស្រី គឺថាគេប្រព្រឹត្តមកលើប្រជាជនថ្មី និងអ្នកមូលដ្ឋានដូចៗគ្នា បើខ្ញុំនិយាយអីចឹងតើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:៤៨:០៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំគិតថា នេះជាការជំទាស់មួយ។ មេធាវីគាត់ទាញសេចក្ដីសន្និដ្ឋានពាក់ព័ន្ធទៅនឹងបរិមាណការងារ របបអាហារ និងការព្យាបាល។ ឥឡូវនេះគាត់ -- អ្វីដែលគាត់សួរនោះ ដូចខ្ញុំមិនសូវយល់ពីអ្វីដែលគាត់ចង់បាន។ គាត់សួរពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះប្រជាជន ដោយផ្អែកទៅលើរបបអាហារ របបការងារ ហើយនិងការព្យាបាល ឬក៏ការឲ្យថ្នាំសង្កូវ។ ដូច្នេះ ខ្ញុំគិតថា គាត់គួរតែរៀបចំសំណួរឡើងវិញដើម្បីកុំឲ្យទាញជាការសន្និដ្ឋានទូទៅ ដោយផ្អែកទៅលើព័ត៌មានដែលសាក្សីគាត់មិនទាន់បានឆ្លើយ។ ហើយគាត់សួរហ្នឹង គួរតែឲ្យសាក្សីគាត់យល់បានស្រួលផង។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំគិតថាខ្ញុំបានជ្រើសរើសប្រធានបទបីសំខាន់ៗ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើប្រជាជននេះ។ ប៉ុន្តែមិនថ្វីទេ ខ្ញុំរីករាយក្នុងការរៀបចំសំណួរនេះឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកស្រីសាក្សី លោកស្រីមានបានកត់សម្គាល់ឃើញថា មានការប្រព្រឹត្តខុសគ្នាណាមួយទេ ទៅលើប្រជាជននៅក្នុងភូមិ ក៏ដូចក្នុងកងរបស់លោកស្រី រវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន? តើលោកស្រីមានបានកត់សម្គាល់ឃើញថា គេប្រព្រឹត្តខុសគ្នាក្នុងពេលណាមួយអីដែរទេ?

[១៥:៤៩:៤៨]

**លោកស្រី អ៊ុង សំអ៊ាន៖**

**ឆ៖** មានខុសគ្នាអីទេ លោកគ្រូ ដូចតែគ្នាហ្នឹង ថ្មីចាស់អី។

**ស៖** តើខ្ញុំស្ដាប់លោកស្រីបានត្រឹមត្រូវដែរទេព្រឹកមិញនេះ ក្រែងលោច្រឡំ គឺថាអ្នកភូមិទាំងអស់ សមាជិកនៃកងចល័តទាំងអស់នៅក្នុងស្រុករបស់លោកស្រី គឺថាស្លៀកពាក់ខោអាវខ្មៅដូចៗគ្នា។ អ៊ីចឹងមែនទេលោកស្រី?

**ឆ៖** ចាស ចុះបើគេឲ្យតែសំពត់ខ្មៅ អាវខ្មៅ គគីរអីហ្នឹងលោកគ្រូ អាវគគីរអីហ្នឹង សំពត់ខ្មៅអាសំពត់អាចម៍ជ្រូក គ្រើមៗនោះ។

**ស៖** តើលោកស្រីនៅចាំបានទេ លោកស្រីស្លៀកពាក់ខោអាវខ្មៅហ្នឹងចាប់ពីពេលណាមកដែរ? តាំងពីដើមដំបូងនៃរបបនោះរហូត មកដល់ចុងបញ្ចប់នៃរបបហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** តាំងតែពីដើមដំបូងមកហ្នឹងលោកគ្រូ មានអីមានអ៊ីចឹង មានតែខោអាវខ្មៅ គេបើកឲ្យនោះ

គ្រើមៗនោះ។ គេមានបើកក្រណាត់ល្អឯណាឲ្យយើង ទៅរកទិញឯណាបើលែងមានផ្សារមានផ្សោ ហើយ លែងចាយលុយហើយ។

**ស៖** លោកស្រីនៅចាំបានទេ ថាឆ្នាំណាដែរដែលគេបានបង្កើតសហករណ៍? ហើយលោកស្រីចាំដែរថាអ្នកភូមិ ក៏ដូចជាសមាជិកនៃកងរបស់លោកស្រីហ្នឹងចាប់ផ្ដើមនាំគ្នាទៅហូបបាយនៅក្នុងសហ-ករណ៍ហ្នឹងនៅពេលណាដែរ ពីពេលណាមកដែរ?

[១៥:៥២:០៣]

**ឆ៖** មិនដឹងឆ្នាំប៉ុន្មានទេលោកគ្រូ អត់បានគិតដែរ។ មានទៅគិតស្អី យើងប្រជាជន ចេះតែគេប្រើទៅណេះទៅណោះ ចេះតែដើរធ្វើការងារទៅ មិនបានគិតផង។

**ស៖** បាទ ខ្ញុំយល់ហើយ ប៉ុន្តែខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកស្រីបន្តិច។ ឯកសារ E3/7796 ថាក្នុងឆ្នាំ១៩៧៦ ប្រជាជនបានហូបបាយនៅក្នុងសហករណ៍ និងដេករួមគ្នា។ តើត្រឹមត្រូវដែរទេថា នៅក្នុងស្រុករបស់លោកស្រីនេះ គឺប្រជាជនចាប់ផ្ដើមហូបបាយរួមហ្នឹងគឺនៅក្នុងឆ្នាំ១៩៧៦?

**ឆ៖** ដូចគេថាអ៊ីចឹងលោកគ្រូ ព្រោះខ្ញុំអត់សូវបានចេះគិតគូរអីនឹងគេផង។ ពីឆ្នាំនុងមែនហើយលោកគ្រូ។

**ស៖** ហើយតើលោកស្រីនៅចាំបានទេ ការហូបបាយរួមនៅក្នុងសហករណ៍ហ្នឹង ហូបតាំងពីដើមដំបូង រហូតដល់ដំណាច់របបហ្នឹងរហូតដល់ចុងបញ្ចប់នៃរបបហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** តាំងពីឆ្នាំហ្នឹងរហូតមកទាល់ដល់៧៩ហ្នឹងលោកគ្រូ ទាល់តែបែកហ្នឹង ហូបបាយតាមផ្ទះទៅ។

**ស៖** នៅពេលរសៀលមុនពេលឈប់សម្រាកនេះ លោកស្រីនិយាយអំពីរូបសំណាកព្រះពុទ្ធ ហើយលោកថាព្រះពុទ្ធរូបទាំងអស់នោះត្រូវបានកម្ទេចចោល។ តើលោកស្រីធ្លាប់បានឃើញកងទ័ព ឬក៏កម្លាំងប្រដាប់អាវុធណាមួយ ឬក៏អ្នកណាមួយមកកម្ទេចពុទ្ធរូបទាំងអស់នេះដែរទេ ឬក៏ការកម្ទេចពុទ្ធរូបនេះគឺថាលោកស្រីគ្រាន់តែបានឮពីគេមកទេ?

[១៥:៥៤:៣៧]

**ឆ៖** កម្ទេចខ្ញុំឃើញ តែមិនដឹងពួកណាគេអ្នកកម្ទេច ខ្ញុំគ្រាន់តែទៅ ខ្ញុំឃើញ។ ព្រះពុទ្ធរូបវិញគេយកថ្នាំយកអីទៅលុបចោលនៅក្នុងវិហារក្នុងអីនោះ តែដឹងពួកណាគេទៅលុប ខ្ញុំអត់ដឹងផង។ ខ្ញុំឃើញបានខ្ញុំហ៊ានថា បើខ្ញុំមិនឃើញ ខ្ញុំមិនហ៊ានថាទេ។

**ស៖** តើបើខ្ញុំស្តាប់មិនច្រឡំទេ លោកស្រីប្រើពាក្យជាភាសាខ្មែរថា "កម្ទេច" ដើម្បីរៀបរាប់អំពីការបំផ្លាញនូវពុទ្ធរូបនេះ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ដូចខ្ញុំថាអ៊ីចឹង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំសុំសួរលោកស្រី អំពីសង្គ្រាមជាមួយវៀតណាម។ ខ្ញុំបានសួរដែលហើយថា លោកស្រីមានដឹងថាមានជនរងគ្រោះណាមួយ ដោយសារសង្គ្រាមទេ។ តើប្អូនរបស់លោកស្រីឈ្មោះ ហាស គឿង -- ប្អូនថ្លៃប្រុសឈ្មោះ ហាស់ ភួង នេះ តើគាត់មានជោគវាសនាយ៉ាងម៉េចដែរ? មានអ្វីកើតឡើងចំពោះប្អូនថ្លៃប្រុសរបស់លោកស្រីនេះ?

**ឆ៖** វាទៅឯទល់ដែនឯកើតនោះ លោកគ្រូ ហើយដល់ហើយគេបាញ់មិនដឹង វាត្រូវស្អី គ្រាប់អីមិនដឹងទេ។ ខ្ញុំឃើញគេសែងមកពីកើតវិញមក តាមមុខផ្ទះខ្ញុំនោះ សែងមកពីកើត។ ខ្ញុំឃើញ។

**ស៖** លោកស្រីឃើញគេសែងគាត់នៅក្នុងអង្រឹងហ្នឹង ដោយសារតែគាត់ត្រូវ គាត់ស្លាប់នៅក្នុងពេលប្រយុទ្ធ ឬក៏យ៉ាងណា?

[១៥:៥៧:០១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាដោយសារបញ្ហាបកប្រែហើយ គឺថាគេនិយាយថាគេសែងគាត់មកវិញ។ គេមិនមែនសែងគាត់ដាក់គាត់នៅក្នុងថង់ ក្នុងបាវអីអ៊ីចឹងទេ។ នេះខ្ញុំសួរទៅអ្នកបកប្រែខាងក្រោយខ្នងខ្ញុំ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងខ្ញុំសូមដកសំណួរនេះចេញទៅចុះលោកស្រី។

**ស៖** លោកស្រីសាក្សី លោកស្រីចងនិយាយថាម៉េច ថានៅពេលដែលឃើញគេយកត្រឡប់មកវិញហ្នឹង បញ្ជាក់ចំណុចនេះបន្តិចមើល។

**ឆ៖** គេដាក់ក្នុងអង្រឹងសែងមក លោកគ្រូ។ គេសែងមកហើយ គេដាក់ឡានទៅ មិនដឹងគេដាក់ទៅណាវិញ មិនដឹងគេយកទៅកប់នៅឯណាទេ ប្រហែលក្រោលគោឯណាទេ។ ខ្ញុំអត់ដឹងផង។ ខ្ញុំសុំគេកប់នៅវត្តចន្ទ្រីនោះ គេអត់ឲ្យផង។ ខ្ញុំមកតាមសុំគេដល់ខាងត្បូងស្ពានហ្នឹង។

**ស៖** ក្នុងចម្លើយរបស់លោកស្រី លោកស្រីឆ្លើយថា គាត់គឺជាកងទ័ពរបស់ខេត្តស្វាយរៀង។ តើលោកស្រីមានបានឮពីយុទ្ធមិត្តរួមអាវុធរបស់ប្អូនថ្លៃលោកស្រីហ្នឹងថា ម៉េចបានជាគាត់ទទួល ម៉េចបានជាគាត់រងរបួសហ្នឹង?

**ឆ៖** គ្មានអ្នកណាមកវិញសួរ លោកគ្រូ ទទេ។ គ្មានទាហានណាមកវិញមួយផង។ បងៗប្អូនឯងជិតៗនុ៎ង វាបាត់អស់ទៅ មិនដឹងវាទៅឯណាអស់។

[១៥:៥៨:៤៨]

**ស៖** លោកស្រីចង់និយាយថា យុទ្ធជនរួមអាវុធរបស់ប្អូនថ្លៃលោកស្រី គឺថាទាំងអស់គ្នាហ្នឹងស្លាប់នៅក្នុងពេលប្រយុទ្ធអស់ហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** មិនស្លាប់អស់ទេ លោកគ្រូ ប៉ុន្តែដល់ហើយគេបញ្ជូនទៅ មិនដឹងទៅឯណាទៅឯណីទៅ សុទ្ធតែបងប្អូនដែរ នៅក្នុងភូមិក្របាម-ក សុទ្ធតែទាហាននិងកងទ័ព គរគោកគរដីដែរ លោកគ្រូ។ ទៅអត់ឃើញមានមកផ្ទះវិញ។ ឃើញតែប្អូនខ្ញុំនុ៎ង ងាប់គេសែងមកនុ៎ង ឃើញតែអានុ៎ងមួយហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អញ្ជើញៗ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានតែមួយសំណួរទៀតទេ ចប់ហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើត្រឹមត្រូវដែរទេ លោកស្រីប្អូនថ្លៃរបស់លោកស្រី ហាស ភួង ហ្នឹងគឺថាស្លាប់នៅពាក់កណ្តាលឆ្នាំ១៩៧៨ អ៊ីចឹងមែនទេ?

**លោកស្រី អ៊ុំង សំអ៊ាន៖**

**ឆ៖** ចាស ស្លាប់នៅឆ្នាំនុ៎ងមែន លោកគ្រូ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រី។ សូមអរគុណលោកប្រធាន អស់សំណួរហើយ។

[១៦:០០:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគ្រាន់តែជម្រាបជូនអង្គជំនុំជម្រះថា ខ្ញុំគ្មានសំណួរទេ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ចុះលោកមេធាវី វ៉ិចទ័រ កូប៉េ អស់សំណួរ អត់មានសួរអីទៀតទេ?

បាទ ហើយការស្ដាប់សក្ខីកម្មសាក្សី អ៊ុំង សំអ៊ាន ដល់ពេលនេះបានដល់ទីបញ្ចប់ហើយ។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី អ៊ុំង សំអ៊ាន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃមកនេះ។ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ ហើយសូមលោកស្រីជួបតែសំណាងល្អ មានសេចក្ដីសុខ សេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី អ៊ុំង សំអ៊ាន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៤ ខែធ្នូ ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក ហើយសូមភាគីជ្រាប។ ហើយសវនាការនៅថ្ងៃចន្ទហ្នឹង គឺអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-820។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃចន្ទ ទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*